**BMI0193**

# សម្ភាសន៍ជាមួយឈ្មោះ ឈិត យឿក ភេទប្រុស អាយុ៦៨ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម "ប្រធានមន្ទីរសេដ្ឋកិច្ច"

## ស្រុកកំណើតនៅភូមិចារលើ ឃុំទឹកជោ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## រស់នៅភូមិសូរិយា ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០២:៤១:៥០

## ៦៨ ទំព័រ

ដានី : ពូ!ពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកសរសេរសៀវភៅពីរឿងរ៉ាវប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់៧៩ ហើយយើងមានបោះពុម្ពជាទស្សនាវដ្ដីចងក្រងទុកជាឯកសារសំរាប់ក្មេងៗជំនាន់ក្រោយ សំរាប់អ្នកសិក្សាស្រាវជ្រាវ ហើយខ្ញុំមកព្រហនេត្រព្រះនេះខ្ញុំចង់សរសេរពីរឿងរ៉ាវទាក់ទងនឹងអាងត្រពាំងថ្ម ហើយមួយអាទិត្យនេះខ្ញុំបានជួបពូ មីងច្រើនប្រហែលចិតសិបនាក់ហើយមកដល់ពេលនេះខ្ញុំបានជួបពូល្មុត ពូសេង ពូឈួង ។

យឿក : ហ្អស!តា ឈួងនៅជូនប្រែង ។

ដានី : បាទ!ហើយពូ សួយ...

យឿក : បាទ!

ដានី : បាទ!យើងបានជួបគ្នាច្រើន ហើយពូ សួយចង់ឲ្យខ្ញុំមកជួបលោកពូព្រោះលោកពូដឹងរឿងច្រើន នៅចាំច្រើនជាងគាត់ ។ លោកពូនៅខាងភស្តុភាហ្អី? ខាងសេដ្ឋកិច្ចហ្អី?

យឿក : បាទ!ខ្ញុំនៅខាងសេដ្ឋកិច្ច ប៉ុន្ដែអីចេះ ពីដើមឡើយហ្នឹងខ្ញុំគេដកចេញដែរ រែកដីលេខមួយ មិនដឹងខុសអីដែរ ដល់គេដកចេញទៅ ដល់ខាងនិរតីគេចុះមកខ្ញុំទៅប្រមូលសំបកប៉ោតសំបកអីឲ្យខាងសេដ្ឋកិច្ចគេព្រោះខាងសេដ្ឋកិច្ចមិនសូវចេះអក្សរទេ ហេតុនេះយើងចេះតិចតួចចេហតែជួយទៅ ។

ដានី : បាទ!អញ្ចឹងលោកពូខ្ញុំចង់ចាប់ផ្ដើមតែម្ដង?

យឿក : បាទ!ចឹងក៏បានដែរ ។

ដានី : លោកពូ ដំបូងខ្ញុំចង់ដឹងឈ្មោះលោកពូឈ្មោះពេញ ឈ្មោះអីដែរ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

យឿក ៖ ខ្ញុំឈ្មោះ ឈិត យឿក ។

ដានី ៖ ឈិតហ្អឺ?

យឿក ៖ ឈិត យឿក ។

ដានី ៖ ហើយសព្វថ្ងៃលោកពូអាយុប៉ុន្មានហើយ?

យឿក ៖ ខ្ញុំ៦៨ហើយ ។

ដានី ៖ អាយុ៦៨ ។ ស្រុកកំណើតកើតជានៅទីណាដែរ?

យឿក ៖ ខ្ញុំនៅភូមិចារលើ ឃុំដោលើពីដើមមិញណាស!

ដានី ៖ ឃុំទឹកដោ នៅស្រុកណាដែរ?

យឿក ៖ ស្រុកព្រះនេត្រព្រះ ។

ដានី ៖ ស្រុកព្រះនេត្រព្រះ ។

យឿក ៖ ប៉ុន្តែវានៅនឹងស៊ីងក្រឡាញ់ណាសកាលនោះ ។

ដានី ៖ បាទ!នៅខេត្តអីដែរកាលពីដើម?

យឿក ៖ ខេត្តបាត់ដំបង ។

ដានី ៖ ខេត្តបាត់ដំបង!ហើយសព្វថ្ងៃនេះពូរស់នៅក្នុងភូមិ ឃុំ ស្រុកអីដែរ?

យឿក ៖ សព្វថ្ងៃនេះរស់នៅភូមិសូរិយា ។

ដានី ៖ ឃុំ?

យឿក ៖ ឃុំកូប!

ដានី ៖ កប?

យឿក ៖ កូប!

ដានី ៖ គប?

យឿក ៖ កូប!កដាក់ស្រៈអូនឹងប ។

ដានី ៖ ស្រុកអីដែរ?

យឿក ៖ ស្រុកអូរជ្រៅ ។

ដានី ៖ ខេត្ត?

យឿក ៖ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ខេត្តបន្ទាយមានជ័យយើង បាទ! ចុះប្រពន្ធលោកពូឈ្មោះអីដែរ?

យឿក ៖ ឈ្មោះ វង់ រី ។

ដានី ៖ វង់ វី ។ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

យឿក ៖ អាយុ៤៨ ។

ដានី ៖ គាត់អ្នកស្រុកណាដែរ?

យឿក ៖ ហ្អូស ចាំមើលនិយាយសិន!កំណើតកើតជានៅតាកែវ ភ្នំពេញឯណោះ ប៉ុន្តែពីសង្គមឪគាត់ធ្វើគ្រូបង្រៀនណាស!ដល់ពេលផ្លាស់មកនៅបរិលនេះ បានន័យថាប្រពន្ធខ្ញុំនៅតូចៗក៏នៅបរិលនេះទៅ ។

ដានី ៖ បាទ!លោកពូមានកូនប៉ុន្មាននាក់ដែរ?

យឿក ៖ ខ្ញុំកូនបី ។

ដានី ៖ កូនបីនាក់ហ្អី? ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

យឿក ៖ ស្រីពីរ ប្រុសមួយ ។

ដានី ៖ ស្រីពីរ ប្រុសមួយ!ធំៗហើយហ្អី?

យឿក ៖ នេះ អាមួយនេះរៀនបរិញ្ញានៅស្វាយ ។

ដានី ៖ ស្រីពីរ ប្រុសមួយហ្អី? លោកពូសព្វថ្ងៃប្រកបមុខរបរអីដែរ?

យឿក ៖ ខ្ញុំធ្វើស្រែទេតើ!

ដានី ៖ ធ្វើស្រែហើយធ្វើអីទៀត?

យឿក ៖ ធ្វើស្រែហើយខ្ញុំទៅយាមផ្ទះឲ្យគេ ។

ដានី ៖ ផ្ទះអ្នកណាគេ?

យឿក ៖ ផ្ទះអង្គការ អង្គការ ភី អែហ្វ ឌី ។

ដានី ៖ អង្គការអីគេ?

យឿក ៖ ភី អែហ្វ ឌី ។

ដានី ៖ ភី អែសឌី?

យឿក ៖ ភី អែហ្វ ឌី ។

ដានី ៖ អង្គការអីគេអាហ្នឹង?

យឿក ៖ អង្គការអភិវឌ្ឍន៍ជនក្រីក្រ ។

ដានី ៖ លោកពូ ឪពុកលោកពូគាត់ឈ្មោះអីដែរ?

យឿក ៖ ឈ្មោះជាម ឪពុកខ្ញុំ ។

ដានី ៖ គាម?

យឿក ៖ ជាម ជដាក់ស្រះអ៊ាទីងម ។

ឈុនលីៈ ត្រកូលអីគេ?

យឿក ៖ ត្រកូលអីទេ...វាលែងចង់ចាំហើយ បើចាំចាំតាវិញ តា ឈិត ដល់តាមួយទៀតជីលួតទៅ ភ្លេចអស់ ។

ដានី ៖ បាទ!ឥឡូវគាត់នៅរស់ឬស្លាប់ហើយ?

យឿក ៖ ស្លាប់ហើយ ។

ដានី ៖ បាទ!ចុះម្ដាយលោកពូ?

យឿក ៖ ម្ដាយខ្ញុំឈ្មោះវើន ។

ដានី ៖ ឈ្មោះវើន ។

យឿក ៖ គាត់ស្លាប់ហើយ ។

ដានី ៖ ស្លាប់ហើយ!ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

យឿក ៖ ពីរនាក់ ។

ដានី ៖ ពីនាក់?

យឿក ៖ ស្រី បង ។

ដានី ៖ បងស្រីមួយទៀត?

យឿក ៖ បាទ!

ដានី ៖ បងស្រីឈ្មោះអីដែរ?

យឿក ៖ ឈ្មោះនែក ឈិត យឿន ។

ដានី ៖ សព្វថ្ងៃគាត់នៅឯណាដែរ?

យឿក ៖ នៅភូមិកំណើត ភូមិចារលើ ។

ដានី ៖ នៅភូមិចារលើ ភូមិកំណើត!ចុះកាលពីក្មេងៗលោកពូបានរៀនដល់ថ្នាក់ណាដែរ?

យឿក ៖ ខ្ញុំ បើនិយាយទៅរៀនចប់បឋមសិក្សាទៅ យើងប្រលងជាប់វាអត់មានលុយទៅរៀនទៀត ទៅខ្ញុំត្រូវរត់ទៅបួស បួសហើយរៀនបានតិចតួចទៀតទៅបានទៅរៀនគរុកោសល្យបាន មកបង្ហាត់ក្មេង ចាប់ពីនោះមកខ្ញុំចេះតែព្យាយាមណាស!រៀនរហូតនៅជំរុំក៏រៀនទៀត ចេះ តែរៀនទៅណាស ។

ដានី ៖ ចឹងពូថារៀនចប់បឋមសិក្សាហ្នឹងនៅសាលាណាដែរ?

យឿក ៖ នៅសាលាទឹកដោ ។

ដានី :  សាលាទឹកដោហ្អី?  បឋមសិក្សារៀនដល់ថ្នាក់ណាទៅ?

យឿក :  ថ្នាក់ទី៧ ។

ដានី :  រៀនចប់ថ្នាក់ទី៧ពូប្រលង?

យឿក :  ប្រលងជាប់ទៅយើងមានលុយឯណាទៅរៀន  ស្រុកស្រែឆ្ងាយផង  ចាំមើលខ្ញុំប្រាប់ណាស! សាលាអនុវិទ្យាល័យមានតែបាត់ដំបង  ហើយទីរួមស្រុកមួយហើយនឹងក្រឡាញ់ ។  យើងចង់ទៅរៀនមួយណាក៏បានដែរប៉ុន្តែម៉ែឪយើងមិនចង់ឲ្យយើងរៀនប៉ុន្មានទេ ។

ដានី :  ឆ្នាំណាដែលលោកពូប្រលងជាប់ហ្នឹង?

យឿក :  ១៩៥៨!

ដានី :  ១៩៥៨ហ្អី?

យឿក :  បាទ!ដល់ពេលប្រលងជាប់ទៅគ្រួសារអត់មានលុយក៏ឈប់ទៅ?

ដានី :  បាទ!  ឈប់ទៅឆ្នាម៥៨ហ្នឹងលោកពូទៅបួសហ្អី?

យឿក :  ក្រោយទៀតបានខ្ញុំទៅបួស ។

ដានី :  ទៅបួសឆ្នាំណា?

យឿក :  ឆ្នាំ៦២ ។

ដានី :  ឆ្នាំ៦២ហ្អី?

យឿក :  បាទ!

ដានី :  លោកពូទៅបួសនៅឆ្នាំ២៦!បួសនៅវត្តណា?

យឿក :  នៅវត្តចារលើ ។

ដានី :  វត្តចារលើហ្អី?

យឿក :  បាទ!

ដានី :  បួសបានប៉ុន្មានឆ្នាំ?

យឿក :  បានបីឆ្នាំ ។

ដានី :  បួសហ្នឹងយើងបួសភិក្ខុក៏បួសនេន?

យឿក :  បួសភិក្ខុ ។

ដានី :  បួសភិក្ខុ  ចឹងយើងអត់បានធ្វើចៅអធិការអីទេ?

យឿក :  អត់ទេ!សឹកបណ្ដោយបើនៅក៏បាន ។

ដានី : ចឹងពូសឹកឆ្នាំណា?

យឿក : ប្រហែល៦៥ ។

ដានី : បាទ!ចុះលោកពូពេលសឹកពីបួសពូធ្វើអីទៅ?

យឿក : ខ្ញុំសឹកពីបួសមកនាយកសាលានៅតំបន់នោះឲ្យបង្រៀនក្មេង ។

ដានី : ពូបង្រៀនក្មេងចាប់ពីឆ្នាំណា?

យឿក : និយាយរួមទៅ មើលចាប់ពីឆ្នាំ៦៥ ។

ដានី : ៦៥ សឹកភ្លាមហ្នឹង?

យឿក : នែ!បង្ហាត់បានមួយឆ្នាំរួចសឹក សឹកហើយគេរកគ្រូអត់ទាន់បានគេឲ្យបង្ហាត់ចឹងទាល់តែយើងរ៉ាប់រងជួយគេមួយឆ្នាំរួចបានសុំគេចេញមក ។

ដានី : ចឹងកាលពូនៅបួសជាលោកហ្នឹងពូហាបង្ហាត់រួចហើយ?

យឿក : បាទ!

ដានី : ដល់ពេលសឹកហើយនៅបង្ហាត់បានមួយឆ្នាំទៀត?

យឿក : មួយឆ្នាំ ។

ដានី : បង្ហាត់នៅសាលាណា?

យឿក : សាលាចារលើ ។

ដានី : សាលាចារលើ!បង្ហាត់កូនសិស្សថ្នាក់ទីប៉ុន្មាន?

យឿក : ខ្ញុំបង្ហាត់ថ្នាក់ទី១០ ទី១១ ។

ដានី : ទី១០ ទី១១នៅសាលាបឋមសិក្សាចារលើ?

យឿក : បាទ!

ដានី : ពូ! ចាំមើលបង្រៀនកាលបួសជាលោកមួយឆ្នាំដល់ពេលសឹកហើយបង្រៀនប៉ុន្មានឆ្នាំទៀត?

យឿក : មួយឆ្នាំទៀត ។

ដានី : មួយឆ្នាំទៀត ចឹងបន្ទាប់ពីបង្រៀនកូនសិស្សហើយយ៉ាងម៉េចទៀតពូ?

យឿក : ខ្ញុំសឹកមក នៅឆ្នាំចិតតត់មានបញ្ហា ស្រុកយើងជនបទវាទៅតាមនោះហើយ ខាងខ្មែរក្រហមនោះណាស!

ដានី : ចឹងដល់ពេលរដ្ឋប្រហារឆ្នាំ៧០ហ្នឹង ពូដូចថាមានចលនាអីខ្លះបានពូចូលទៅខាងខ្មែរក្រហម?

យឿក ៖ បើនិយាយទៅ ការដែលចេញដំណើរនោះគេចង់និយាយថា ពីព្រោះយើងត្រូវរំដោះវណ្ណៈសក្តិភូមិ នាយទុនអីចឹងណាសកុំឲ្យមានការជិះជាន់ ប៉ុន្តែហេតុអីក៏គេមកខាងណោះទាន់? អ្នកដែលមកមិនទាន់ហ្នឹងដូចថាមេភូមិគេមកពីមុខហើយទៅណាអត់រួច ។

ដានី ៖ ចឹងនៅខាងស្រុកភូមិពូមានគេចូលមកឃោសនាអីបានជាលោកពូចូលជាមួយគេ?

យឿក ៖ គេមកតើ ខាងខ្មែរក្រហមគេមក ចេញចូលរាល់ថ្ងៃហេតុនេះចង់និយាយថាខ្មែរក្រហមដប់ថ្ងៃទាហានមួយថ្ងៃ ។

ដានី ៖ ចឹងលោកពូដូចថាលោកពូមានចាំឈ្មោះខ្មែរក្រហមដែលចូលមកឃោសនាទេ?

យឿក ៖ ជីមិនចាំតែឥឡូវស្លាប់អស់ហើយ ។

ដានី ៖ គាត់ឈ្មោះអីខ្លះទៅ?

យឿក ៖ ឈ្មោះតាំង យឹន ។

ដានី ៖ តាំង យឹន ហ្អឺ? ឈ្មោះអីទៀត?

យឿក ៖ ឈ្មោះ លាវ ហូវ ។

ដានី ៖ គាត់មកកាលនោះមានតួនាទីអីខ្លះទៅ?

យឿក ៖ មេទ័ព ។

ដានី ៖ មេទ័ពនៅឯណាទៅ?

យឿក ៖ នៅសៀមរាបព្រោះតំបន់ពីដើមវានៅសៀមរាបទាំងអស់ ។ បានន័យថាសៀមរាបជាកន្លែងសំរាប់លាក់ខ្លួនដើម្បីធ្វើសង្គ្រាមអីណាស!

ដានី ៖ បាទ!

យឿក ៖ ប៉ុន្តែបំបែកគ្នាមកនេះ ចុះមិនដឹងធ្វើមេ៉ចគ្រូបង្រៀនក៏ដោយស្អីក៏ដោយ ។

ដានី ៖ ចុះពូចាំខែទេពេលឆ្នាំ៧០ ដែលពូចូលទៅជាមួយខ្មែរក្រហមហ្នឹង?

យឿក ៖ ប្រហែលជាចុងឆ្នាំ៧០ ។

ដានី ៖ ចុងឆ្នាំហ្អឺ?

យឿក ៖ ប៉ុន្តែអាគេឃោសនាចលនាអីចាប់ពី៧០មក ។

ដានី ៖ ចាប់ពី៧០មក? ប៉ុន្តែពេលដែលពូចូលទៅនៅជាមួយគេតែម្តងនៅចុងឆ្នាំ៧០ ហ្អឺ?

យឿក ៖ បាទ!

ដានី ៖ លោកពូអាចរៀបរាប់ពីកន្លែងដែលលោកពូចូលទៅជាមួយខ្មែរក្រហមហ្នឹងលោកពូទៅនៅកន្លែងណា? ធ្វើអី?

យៀក:	អត់ទេព្រោះខ្ញុំមិនបានទៅនៅច្រើនកន្លែងទេ ។ ចាំមើលណាសដូចខ្ញុំទៅចឹងនៅហ្នឹងព្រៃគេហៅថាព្រៃគង់ពុត រស់នៅក្នុងស្រុកក្រឡាញ់អត់ទាន់ដល់ស្រីស្នំទេ ។

ដានី : កាលនោះយើងរស់នៅក្នុងព្រៃយើងធ្វើអីទៅ? ហើយនៅគ្នាប៉ុន្មាននាក់?

យៀក : ទេ ច្រើន!ប្រជាជនច្រើន តែពួកខ្ញុំយុវជនអីធ្វើឈ្លប ។

ដានី : ឈ្លបហ្អី? កាលនោះពូធ្វើឈ្លប?

យៀក : បាទ!ឈ្លបផង ធ្វើទ័ពផង ។

ដានី : កាលនោះយើងធ្វើឈ្លបនៅក្នុងព្រៃ តួនាតីរបស់ឈ្លបធ្វើអីខ្លះទៅ?

យៀក : តួនាទីរបស់ឈ្លបចង់និយាយថាទីមួយគឺជញ្ជូនសម្ភារៈឲ្យកងទ័ព ។ ទីពីរនោះមាននាទីទៅត្រៀមជាមួយទ័ពដែរ វ៉ៃហ្នឹងណាស!

ដានី : ចុះលោកពូកាលនោះឈ្លបមានគ្នាប៉ុន្មាននាក់ទៅ?

យៀក : ទេ ច្រើន!ខ្ញុំគិតទៅជិត២០០នាក់ ។

ដានី : ជិត២០០នាក់ មួយឃុំហ្អី?

យៀក : មួយឃុំ ។

ដានី : គេហៅឃុំអី?

យៀក : ហ្អស ពីដើមមិញអត់មានភូមិទេ គេដាក់ឈ្លបនៅសង្កាត់១២ សង្កាត់១៣ចឹងទៅណាស ។

ដានី : ចុះពូនៅសង្កាត់ប៉ុន្មាន?

យៀក : នៅសង្កាត់១២ ។

ដានី : សង្កាត់១២ ចុះនៅស្រុកអីគេ?

យៀក : វានៅក្នុងស្រុកក្រឡាញ់តែដល់តំបន់ខ្មែរក្រហមមិនដឹងដាក់ស្រុកអីទេ ។

ដានី : បាទ!ចឹងកាលនោះអ្នកណាជាអ្នកគ្រប់គ្រងឈ្លប?

យៀក : នែ!ឈ្មោះដេង ។

ដានី : ឈ្មោះដេង!បាទ ចុះពូមានតួនាទីអីខ្លះកាលនៅជាឈ្លប?

យៀក : ក្រោយមកគេបោះឆ្នោត ដល់បោះទៅខ្ញុំជាប់ជាប្រធានឈ្លបពិសេស ។

ដានី : ប្រធានឈ្លបពិសេស ពូក្តាប់២០០នាក់ហ្នឹងហ្អី?

យៀក : បាទ!

ដានី : ពូចាប់ផ្តើមគេបោះឆ្នោតឲ្យពូធ្វើប្រធានឈ្លបនៅឆ្នាំណាដែរ?

យៀក : ឆ្នាំប្រហែលជា៧៣ហើយ ។

ដានី ៖ ឆ្នាំ៧៣ហ្អី? ចឹងពូជាប្រធានឈ្លបពិសេសធ្វើកិច្ចការអីខ្លះទៅ?

យឿក ៖ ឧទាហរណ៍ថាគេទៅវ៉ៃសំរោង បទបញ្ជាគេថាត្រូវការ៣០នាក់ឬ២០នាក់ព្រោះថាដោះដូរគ្នាណាស ដូចថាក្រុមឯងខ្ញុំឲ្យទៅ២០នាក់ចឹងពេលឯងមកឪឲ្យក្រុមនោះទៅម្តង ដូរគ្នាម្តងម្នាក់ ។

ដានី ៖ ហ្អស! បានន័យថាពេលទៅវ៉ៃនៅសមរភូមិចឹងយើងយក៣០នាក់ហ្នឹងទៅវ៉ៃទៅ?

យឿក ៖ បាទ! ទៅជាមួយទ័ព ។

ដានី ៖ ទៅជាមួយទ័ពហ្អី?

យឿក ៖ បាទ!

ដានី ៖ ហើយទៅកន្លែងណា១០ ២០នាក់ទៀតក៏ទៅៗ?

យឿក ៖ បាទ!

ដានី ៖ ចុះមានធ្វើការអីផ្សេងទៀតក្រៅពីវ៉ៃ?

យឿក ៖ មានលើកថ្នល់ លើកទំនប់ ។

ដានី ៖ ឆ្នាំ៧៣យើងមានលើកថ្នល់លើកទំនប់ដែរ?

យឿក ៖ លើក អត់មានឈប់ទេ ។

ដានី ៖ ទំនប់នៅឯណាទៅ?

យឿក ៖ ទំនប់នៅភូមិគន់ពុត ឧបមាថាកន្លែងណាដែលត្រូវទប់ទឹកចឹងមនុស្សទៅ ទៅលើកហ្នឹងណាស!

ដានី ៖ ប៉ុន្តែលោកពូមានប្រសាសន៍មិញហ្នឹងកងឈ្លបដែលខាងប្រជាជនហ្នឹងនៅក្នុងព្រៃតើហ្អី?

យឿក ៖ នៅក្នុងព្រៃ ។

ដានី ៖ នៅក្នុងព្រៃហ្នឹងយើងមានលើកតំនប់លើកថ្នល់ដែរ?

យឿក ៖ លើក ដាំដំឡូងមី ដំឡូងគអី ប៉ុន្តែយើងរស់នៅក្នុងព្រៃដូចថាយើងធ្វើផ្ទះអីនៅក្រោមដើមឈើគ្របចឹងយើងទៅធ្វើក្រោមនោះទៅណាស ព្រោះខ្លាចកប៉ាល់ហោះ ។

ដានី ៖ ខ្លាចកប៉ាល់ហោះ! ចុះកាលនោះយើងមានរៀបចំឲ្យប្រជាជននៅយ៉ាងម៉េចពេលមានប្រជាជនទៅនៅក្នុងព្រៃចឹងយើងរៀបជាសហករណ៍បាយរួមអីយ៉ាងម៉េច?

យឿក ៖ អត់ អត់មានហូបរួមទេ ហូបរួមតែតាមអង្គភាពគេទេណាស ដូចថាទ័ពគេមកពីមុខចឹងហូបនៅទីនោះខ្លះ ហើយអ្នកណាដែលមានផ្ទះសំបែងអីថាមកលេងផ្ទះក៏បានដែរ ។

ដានី ៖ ចុះលោកពូដូចយើងឈ្លបចឹងមានតួនាទីគ្រប់គ្រងឈ្លបយ៉ាងម៉េចដែរ?

យឿក ៖ អត់ទេ អត់មានគ្រប់គ្រងប្រជាជនទេ បើនិយាយរួមដូចសន្តិសុខចឹងនៅក្នុងភូមិ ព្រោះយើងមានតួនាទីដូចថា ខ្លួចមានទាហានខាងនេះប្រាស់ទៅយ៉ាងម៉េចនោះយើងមាន ។

ដានី ៖ បាទ! យើងដូចថាសន្តិសុខនៅក្នុងភូមិដើរមើលក្រែងលមានខ្មាំងនៅក្នុងភូមិឬថាមានសមាសភាពអីចឹងយើងធ្វើការរឿងហ្នឹងហ្អី?

យឿក ៖ បាទ!

ដានី ៖ ចុះចាប់ពីឆ្នាំ៧៣មកយើងមានសមាសភាពដូចនៅក្នុងប្រជាជនចឹងយើងធ្វើយ៉ាងម៉េចដែរដូចយើងចាប់ឬយកទៅណាដែរ?

យឿក ៖ អានេះបើយើងឃើញមានអ្នកណាមកកាទេកាទើអីយើងអត់ហ៊ានទេ ស្រេចតែទ័ពព្រោះអី? ព្រោះយើងអត់បានដឹងរឿង ដោយសារអ្នកដែលយើង មិនស្គាល់មកដួនកាលប្រៀបដូចថាចារកម្មមកយកការចឹងណាសយើងអត់មាននេះទេ ឲ្យទៅខាងទ័ព ។

ដានី ៖ ឲ្យទៅខាងទ័ព ។ យើងអ្នករាយការណ៍ឲ្យទៅទ័ពហ្អី?

យឿក ៖ បាទ! នៅក្នុងភូមិយើងរាយការណ៍ឲ្យទ័ព ។

ដានី ៖ ចុះយើងមានដែលចាប់ឲ្យទ័ពដែរអត់?

យឿក ៖ អត់ ជំនាន់នោះដូចខ្ញុំអត់ដែលបានចាប់ទេ ព្រោះវាអញ្ចេះផង អាការចាប់មិនចាប់ហ្នឹងសំរេចនៅលើប្រធានដួនកាលប្រធានគេតឹងតែងអីចឹង តែខ្ញុំមិនតឹងអីទេ ។

ដានី ៖ បាទ! ចឹងអាស្រ័យលើប្រធានទេ ហើយពូធ្វើប្រធានដែរតែពូមិនសូវតឹងតែង?

យឿក ៖ មិនសូវតឹងទេ ។

ដានី ៖ ពូកាលនោះគេហៅឈ្លបពិសេសហ្នឹងយើងក្តាប់មួយស្រុកឬយ៉ាងម៉េច?

យឿក ៖ មួយឃុំ ។

ដានី ៖ មួយឃុំ ដូចពូមានប្រសាសន៍ថាសង្កាត់១២ហ្នឹង?

យឿក ៖ បាទ!

ដានី ៖ ហ្អីក៏មានឃុំអីផ្សេងទៀត?

យឿក ៖ មានតើ មានឃុំ១២ សង្កាត់១៣អីចឹងទៅណាស តែយើងមិនសូវចាប់អារម្មណ៍ទៅលើសង្កាត់ផ្សេងៗទេ ហើយជាពិសេសយើងមិនសូវបាននៅក្នុងភូមិ ។

ដានី ៖ ចុះកាលនោះគណៈស្រុកឈ្មោះអីទៅដូចជាអ្នកដែលគ្រប់គ្រងសង្កាត់អីចឹង?

យឿក ៖ បើនិយាយទៅគណៈស្រុកសម័យនោះ...ព្រោះតំបន់នេះគេហៅតំបន់៥ បានន័យថាតមបន់៥នេះមិនមែនស្ថិតក្នុងទឹកដីនោះទេ នៅខាងបាត់ដំបង ហេតុនេះបានន័យថាយើងទៅផ្ញើរខ្លួននៅតំបន់៤៥ ខាងសៀបរាម ។

ដានី ៖ ខាងសៀមរាប បាទ!

យឿក ៖ ៣៥ ៤៥...

ដានី ៖ តំបន់៣៥ បាទ!

យឿក ៖ តំបន់៣៥ចឹងទៅចៅហ្វាយស្រុកអីនៅខាងគេនោះហទៅ ។

ដានី ៖ បាទ!កាលនោះពូស្គាល់ទេកាលនោះ?

យឿក ៖ ខ្ញុំស្គាល់ឈ្មោះតា សម តា ដុះ ។ ឈ្មោះសម និង ដុះ មិនមែននាមត្រកូលនាមខ្លួនអីទេណាស!

ដានី ៖ បាទ!ពីរនាក់ចឹង តា សម និង តា ដុះ?

យឿក ៖ ពីរនាក់ ។

ដានី ៖ គាត់ហ្នឹងគណៈស្រុក?

យឿក ៖ បាទ!

ដានី ៖ ស្រុកអីគេអាហ្នឹង?

យឿក ៖ ស្រុកស្រីស្នំ ។

ដានី ៖ ស្រុកស្រីស្នំ?

យឿក ៖ បាទ!

ដានី ៖ ចឹងពូធ្វើកងទ័ពហ្នឹងនៅក្នុងទឹកដីស្រុកស្រីស្នំ?

យឿក ៖ ស្រុកស្រីស្នំ ។

ដានី ៖ មិនមែនស្រុកក្រឡាញ់ទេ?

យឿក ៖ អត់បានទេ អានោះគេចាត់ចូលស្រុកស្រីស្នំ ។ កាលនោះវាដូចជាទឹកដីស្រុកក្រឡាញ់ដែរបើតាមខ្ញុំមើលព្រោះគ្រាប់ផ្លោងដល់ ។

ដានី ៖ ចុះគណៈតំបន់គេអីអ្នកណាទៅកាលនោះ?

យឿក ៖ ទេ គណៈតំបន់ តា ហ៊ីង ។

ដានី ៖ ចុះក្រែងកាលនោះតំបន់៣៥ តើហ្អី?

យឿក ៖ តំបន់៣៥ នោះផ្សេង តែតំបន់៥ តា ហ៊ីង ។

ដានី ៖ តែតាំងពីឆ្នាំ៧៣ហ្នឹងមក តា ហ៊ីង គាត់គ្រប់គ្រងហើយហ្អី?

យឿក ៖ បាទ!តំបន់នោះ ។ ប៉ុន្តែគាត់គ្រប់គ្រងមួយរយៈក្រោយយមកមិនដឹងថាគាត់ខុសអី គេយកទៅកិនស្រូវយូរណាស់ណា៎ ដល់យើងជិត៧៩បាន តា ហ៊ីង ចេញមកវិញ ។

ដានី ៖ ចឹងគេយកគាត់ទៅកិនស្រូវដែរ?

យឿក ៖ បាទ!កិនស្រូវ លីសែងអីចឹងទៅណាស ចុះអ្នកខុសគេធ្វើចឹង ។

ដានី ៖ ចុះលោកពូតាំងពីឆ្នាំ៧១ ៧១ ៧២ ៧៣ ៧៤ ៧៥ហ្នឹងតា ហ៊ីង គាត់នៅកន្លែងណា?

យឿក ៖ តា ហ៊ីងនៅខាងសៀមរាបដែរ ។

ដានី ៖ នៅសៀមរាបដែរ?

យឿក ៖ បាទ!ប៉ុន្តែមុខសញ្ញាគាត់នៅខាងបាត់ដំបង បន្ទាយមានជ័យយើងថ្មពួកនេះ គាត់ចុះវៃណាស!

ដានី ៖ បាទ!កាលនោះគាត់ធ្វើអី?

យឿក ៖ គាត់តំបន់ផង ហើយគ្រប់គ្រងទ័ពផង របៀបដូចចៅហ្វាយខេត្តចឹងណាស ។ទ័ពដែលនៅក្នុងខេត្តទាល់តែចៅហ្វាយខេត្តគ្រប់គ្រងដែរ ។

ដានី ៖ កាលនោះគ្នាប៉ុន្មាននាក់ដែលគ្រប់គ្រងជាមួយតា ហ៊ីង?

យឿក ៖ ខ្ញុំស្គាល់តែ តា ហ៊ីងមួយ ។

ដានី ៖ ស្គាល់តែ តា ហ៊ីង!ធ្លាប់ធ្វើការជាមួយគាត់ដែរពេលនោះ?

យឿក ៖ អត់ទេ!សឹងតែមិនដែលបានជួបផង ។

ដានី ៖ អត់ដែលបានជួបគាត់ទេ ពេល៧៣ហ្នឹង?

យឿក ៖ មិនងាយបានជួបទេព្រោះយូរៗបានគេមកម្តង មកម្តងក៏យើងមិនសូវបានទៅ ព្រោះយើងចង់និយាយថាការងារអ៊ីដែលគេមិនអនុញ្ញាតឲ្យទៅជួប ទាល់តែអ្នកដែលគេឲ្យទៅជួបបានទៅបាន ។

ដានី ៖ ចុះពេលមានប្រជុំម្តងៗពេលនោះមាន តា ហ៊ីង មកប្រជុំដែរអត់ទេ?

យឿក ៖ ខ្ញុំច្រើនតែបានទៅចូលរួមជាមួយឃុំ ព្រោះយើងឈប់ក្រោមការគ្រប់គ្រងរបស់ឃុំ ។

ដានី ៖ បាទ!ឃុំហ្នឹងឈ្មោះអីទេ?

យឿក ៖ ទេ!តា ផេងហ្នឹង តែក្រោយមកគាត់ធ្វើគណៈស្រុកភ្នំស្រុក ។

ដានី ៖ តា ផេង ហ្នឹងគណៈស្រុកភ្នំស្រុក?

យឿក ៖ ទេ ក្រោយមក ។

ដានី ៖ ប៉ុន្តែកាលនោះតា ហ៊ឹងមកធ្វើការដល់កន្លែងពូដែរ?

យឿក ៖ មកតើ ឡានស៊ីបគេបើកមកពីសៀមរាបមកដូចថាគេចុះបញ្ជាទ័ពផ្ទាល់នោះណាស ។ ឧបមាថាគេត្រូវទៅវៃថ្មពួកកមទេចបន្ទាយអី ចុះកបណ្ដោយ ។

ដានី ៖ គាត់ចុះមក?

យឿក ៖ បាទ! ពេទ្យវះកាត់អីចុះមកទាំងអស់ ។

ដានី ៖ ចុះលោកពូនៅក្នុងព្រៃហ្នឹងដល់ឆ្នាំណាទៅបានចេញទៅណាទៀត ។

យឿក ៖ ៧៥ ។

ដានី ៖ ដល់៧៥ហ្នឹងហ្អី?

យឿក ៖ ៧៥ចប់សង្គ្រាមចេញមកបណ្ដោយ ។

ដានី ៖ ឆ្នាំ៧៥បានចេញមក?

យឿក ៖ បាទ!

ដានី ៖ ពូចឹងពេលដែលយើងបែកភ្នំពេញឆ្នាំ៧៥មកយ៉ាងម៉េចទៀតទៅមានការប្រែប្រួល ហើយពូទទួលមុខនាទីអី?

យឿក ៖ អត់ទេ ក្រោយមកពេលដែលចប់ហើយព្រឹប ឈ្លបត្រូវទាញមកនៅតាមភូមិយើងដែល លន់ នល់ កាន់កាប់នោះណាស ចេញពីព្រៃមក ហេតុនេះហើយបានគេជម្លៀសប្រជាជន ចេញ ។

ដានី ៖ បាទ!

យឿក ៖ អាភូមិខ្ញុំ ម៉ែឪខ្ញុំក៏ជម្លៀសចេញមកដែរ ។ ចេញទាំងអស់ បានន័យថាគេមិនឲ្យយើងនៅ ភូមិដដែល មិនបានអីដូរពី កទៅខ ។

ដានី ៖ បាទ!

យឿក ៖ ខ្ញុំធ្វើឈ្លបដែរតែសេដ្ឋកិច្ចឲ្យយើងមើលពីនេះទៅស្វាយចឹង មើលតែពីនេះទៅស្វាយ ។

ដានី ៖ កាលនោះពេលដែលយើងបែក៧៥ហើយ យើងជម្លៀសប្រជាជនមិនចឹងហ្អីពូ?

យឿក ៖ បាទ!

ដានី ៖ កាលនោះពូអ្នកជម្លៀសឬក៏មានគេបញ្ជាឲ្យពូជម្លៀស?

យឿក ៖ ពីលើគេមក ពីស្រុកគេជម្លៀសចេញមក ហើយយើងឈប់អត់មានតួនាទីអីទេ មានតួនាទីថាមើលប្រជាជន ព្រោះពេលខ្លះទ័ពវាពកើ្កតពក្ើនចង់ធ្វើបាប វាយធាក់អីណាស! ម្លៀសៗធម្មតា ។

ដានី ៖ ជម្លៀសធម្មតា! លោកពូកាលនោះពូនៅស្រុកណា?

យឿក ៖ ខ្ញុំនៅស្រុកព្រះនេត្រព្រះ ដែលមកៗនៅស្រុកព្រះនេត្រព្រះ ។

ដានី ៖ បាទ!ចឹងពូកាន់ឈប់ហ្នឹងមកឈប់ស្រុកបរិញហើយហ្អី?

យឿក ៖ អត់ទេ ដល់មកនៅនៅឃុំទឹកជោរ ដល់ក្រោយមកខ្ញុំនេះត្រូវគេជ្រើសរើសព្រោះអានោះបំបែកគ្នាទៅធ្វើទ័ពធ្វើអីទៅណាស!ដល់មួយចំនួនទៅធ្វើទ័ពទៅ ដល់ខ្ញុំនេះអាយុច្រើនជាងគេដែរ សាមលើសហើយម្ល៉េះហើយគេយកឲ្យមកនៅមន្ទីរស្រុកព្រះនេត្រព្រះ ។

ដានី ៖ បាទ!ឆ្នាំណាដែលគេចាប់ផ្ដើមជ្រើសរើស?

យឿក ៖ កាលនោះឆ្នាំ៧៥ ។

ដានី ៖ ខែណាដែរដែលគេជ្រើសរើស?

យឿក ៖ កាលនោះខែវស្សាដែរ ប្រហែលជាខែ៨ខែ៩ ។

ដានី ៖ ខែ៨ ខែ៩ឆ្នាំ៧៥ហ្អី

យឿក ៖ បាទ!

ដានី ៖ កាលនោះអ្នកណាអ្នកជ្រើសរើសឲ្យពូនៅមន្ទីរស្រុកហ្នឹង?

យឿក ៖ បើនិយាយទៅខាងស្រុកគេទៅធ្វើប្រវត្តរូប ឈ្មោះលឿម ។

ដានី ៖ លឿមហ្អី?

យឿក ៖ បងលឿម!

ដានី ៖ លឿមហ្នឹងហ្អីដែលធ្វើប្រវត្តិរូបឲ្យពូ?

យឿក ៖ បាទ!

ដានី ៖ ដល់ធ្វើហើយគេយកពូមកនៅមន្ទីរស្រុក?

យឿក ៖ មក គេរើសក្នុងនោះឯង គេរើសក្នុងឈប់ ឧបមាថាយើងគួរយកពីណាខ្លះមកនៅមន្ទីរស្រុកព្រោះវាត្រូវការពារការអី ។

ដានី ៖ ចុះកាលនោះពេលពូទៅមន្ទីរស្រុកតួនាទីពូទៅជាអីវិញ?

យឿក ៖ នៅកាន់មន្ទីរស្រុកនេះតែម្ដង ។

ដានី ៖ កាន់មន្ទីរស្រុក?

យឿក ៖ បាទ!កានកាប់នៅស្រុក ស្រុកព្រះនេត្រព្រះ ។

ដានី ៖ កាលនោះជាគណៈស្រុកប្លុយ៉ាងម៉េច?

យឿក ៖ អត់ទេ គណៈស្រុកផ្សេង ។

ដានី ៖ គណៈស្រុកឈ្មោះអីខ្លះ?

យឿក ៖ ឈ្មោះលឿម តា សំអាត ឈ្មោះខូ ហើយដល់ក្រោយមកបងលឿម គេផ្លាស់ចេញ ។ បងលឿមប្តូរទៅភូមិភាគបានឈ្មោះ តា ម៉ោង ។ តា ម៉ោង គាត់ធ្វើគណៈស្រុក ។

ដានី ៖ ចឹងតា លឿមហ្នឹងគាត់ធ្វើគណៈស្រុក?

យឿក ៖ បាទ!

ដានី ៖ គណៈស្រុក ហើយអនុគាត់ឈ្មោះតា សំអាត ។

យឿក ៖ តា សំអាត ។

ដានី ៖ ឈ្មោះថូមួយទៀត?

យឿក ៖ ទេ ខូហ្នឹងខាងសន្តិសុខ ខូ!

ដានី ៖ ខូ ហ្នឹងទទួលបន្ទុកខាងសន្តិសុខ?

យឿក ៖ បាទ!នៅខាងទ័ពខាងអីណាស!

ដានី ៖ ចឹងខូ ហ្នឹងគាត់នៅរស់ហ្អី?

យឿក ៖ គាត់នៅឯណា?

ដានី ៖ នៅបន្ទាយឆ្មារ ។ ភូមិ ឃុំអីដែរនៅបន្ទាយឆ្មារ?

យឿក ៖ នៅធ្លក ភូមិធ្លក ។

ដានី ៖ ភូមិធ្លក?

យឿក ៖ ភូមិធ្លក ។

ដានី ៖ ឃុំបន្ទាយឆ្មារ ។ ឥឡូវឈ្មោះគាត់ឈ្មោះដដែល តើហ្អី?

យឿក ៖ បាទ!

ដានី ៖ ប្រពន្ធគាត់ឈ្មោះអីដែរ?

យឿក ៖ ប្រពន្ធគាត់ស្លាប់ហើយ ឈ្មោះសាយ ។

ដានី ៖ ប្រពន្ធឈ្មោះសាយស្លាប់ហើយហ្អី?

យឿក ៖ បាទ!

ដានី ៖ ចឹងគាត់ទទួលខាងសន្តិសុខស្រុក?

យឿក ៖ ប្រពន្ធក្រោយឈ្មោះរ៉េត ចែរ៉េត ។

ដានី ៖ លោកពូចឹងពូមកធ្វើជាប្រធានមន្ទីរស្រុកហ្នឹងហ្អី?

យឿក ៖ បាទ! នៅហ្នឹងមន្ទីរស្រុក ។

ដានី ៖ ប្រធានមន្ទីរស្រុកធ្វើអីខ្លះទៅ?

យឿក ៖ បើនិយាយទៅបានន័យថា ឥវ៉ាន់ដែលធ្លាក់ពីតំបន់ ភូមិភាគអីទៅគឺយើងអ្នកចាត់ចែង ស្ថិតិនៅលើយើង ប្រជាជនមួយស្រុកឃុំណាប៉ុន្មានពាន់នាក់ប៉ុន្មានម៉ឺននាក់នៅទីនោះ ហើយគេចែកប៉ុន្មានភាគរយៗត្រូវចែកឲ្យស្មើៗគ្នា ។

ដានី ៖ ចែកទៅណា?

យឿក ៖ ចែកទៅតាមឃុំណាស! ឧបមាថាឃុំប្អូនឯងមាន៣០០០ ឃុំនោះមាន៦០០០ របស់មានប៉ុន្មានត្រូវចែកប៉ុណ្ណាឲ្យបានត្រឹមត្រូវ ។

ដានី ៖ ចុះលោកពូកាលនៅព្រះនេត្រព្រះហ្នឹងមានប៉ុន្មានឃុំ?

យឿក ៖ មើល...ឃុំព្រះនេត្រព្រះ ឃុំទឹកជោ ឃុំប្រាសាទ ឃុំរហាល ឃុំទានកម្ម

ដានី ៖ ឃុំអី?

យឿក ៖ ទានកម្ម ។

ដានី ៖ ឃុំទានកម្ម ប្រាំឃុំ?

យឿក ៖ ទឹកជោរ ប្រាសាទ ហួស! ភ្នំលាប ។

ដានី ៖ ភ្នំលាបមួយទៀត?

យឿក ៖ ភ្នំលាបមួយទៀត ។

ដានី ៖ ចឹងប្រាំមួយឃុំហ្អី?

យឿក ៖ ប្រាំមួយឃុំ ។ ដល់ក្រោយមកគេបំបែកទៀត ។

ដានី ៖ គេបំបែក តែកាលជំនាន់ ប៉ុល ពត មានតែប្រាំមួយទេ ។ ចុះពូ តា លឿម គាត់ផ្លាស់ទៅភូមិភាគឆ្នាំណា?

យឿក ៖ នែ! ៧៦

ដានី ៖ ៧៦ហ្អី?

យឿក ៖ បាទ!

ដានី ៖ ខែប៉ុន្មានដែលគាត់ផ្លាស់ទៅមានចាំខែទេ? ខែហ្នឹងដូចជាខែយើងធ្វើស្រែ ខែវស្សា?

យឿក ៖ ទេខ្វង់ខែវស្សា គាត់ខុសសីលធម៌ ។

ដានី ៖ គាត់ខុសសីលធម៌ ខុសយ៉ាងម៉េចអាហ្នឹង?

យឿក ៖ ស្រលាញ់គ្នា តែគាត់អត់ប្រពន្ធទេ ស្រីហ្នឹងក៏អត់មានប្ដីដែរ ក្រមុំកំលោះទេ។ តែគាត់កំលោះចាស់ហើយអាយុ៩០ហើយ ។

ដានី ៖ អាយុប៉ុន្មាន?

យឿក ៖ ជិត៩០ហើយអត់ដែលមានប្រពន្ធផង តែខាងលើគេអនុគ្រោះដោយសារគាត់អត់ប្រពន្ធមែនម្ទោះហើយគេយកទៅបញ្ជូរជើងនៅភូមិភាគទៅ ព្រោះគាត់បក្សគេធំណាស់ គាត់នៅតែជុំខៀវ សំផនអីណោះ រួចហើយបញ្ចេញមកណាស ។ ដូចប្អូនឯងចៅហ្វាយស្រុកចង់ឲ្យអ្នកនេះទៅធ្វើប៉ូលីសនៅនេះអីចឹងទៅណាសដល់ម្ទោះហើយវាមិនងាយដែរ ។

ដានី ៖ ចុះពូថាគាត់ខុសសីលធម៌ជាមួយនារីណា? គាត់អ្នកនៅនេះឬអ្នកមកពីភ្នំពេញ?

យឿក ៖ នារីនៅក្នុងជួរដូចគ្នាដែរហ្នឹងណាស បានន័យថានារីនោះក៏ធ្វើការក្នុងជួររដ្ឋដែរ ។

ដានី ៖ នៅស្រុកហ្នឹងដែរ?

យឿក ៖ បាទ! នៅស្រុកព្រះនេត្រព្រះនេះ ។

ដានី ៖ ឈ្មោះអីទៅនារីនោះ?

យឿក ៖ ហួស! ភ្លេចឈ្មោះហ្នង ។ ភ្លេចឈ្មោះទៅណាស ។

ដានី ៖ នារីហ្នឹងធ្វើខាងអីកាលនោះ?

យឿក ៖ នារីនៅជួយមើលនេះមើលនោះនៅក្នុងស្រុកដូចថាអ្នកនៅដាំបាយដាំទឹកអីទៅនៅជុំគ្នាក៏ស្រឡាញ់គ្នាទៅ ។

ដានី ៖ ចុះតា លឿមផ្លាស់ទៅភូមិភាគធ្វើអីទៅ?

យឿក ៖ ទៅភូមិភាគបានប្រហែល២ខែស្រាប់តែមកវិញជិះឡានត្រាភូមិភាគតែម្ដង បានន័យថាកាលគេចាប់គាត់ទៅស្មានតែគាត់បាត់បង់អីអស់...វាទៅជាកាន់ទ័ពនៅភូមិភាគចវិញ ។

ដានី ៖ គាត់ជិះឡានមកវិញ...

យឿក ៖ គាត់ចុះមកធ្វើការនៅតាមតំបន់ ។

ដានី ៖ គាត់បើកឡានមកវិញគាត់បើកឡានកងទ័ព?

យឿក ៖ បាទ! កងទ័ព ។

ដានី ៖ រួចកាលនោះគាត់មានតួនាទីអីកងទ័ព?

យឿក ៖ កាលនោះដូចលំបាកដែរព្រោះមិនសូវហ៊ានសាកសួរតែបើតាមខ្ញុំស្មាន យ៉ាងកំសុយក៏វីរៈសេនាធំដែរ ។

ដានី ៖ នៅភូមិភាគហ្នឹង?

យឿក ៖ បាទ!

ដានី ៖ ចុះកាលគាត់ទៅឆ្នាំ៧៦ពូអត់ចាំថាខែណាទេ?

យឿក ៖ ប្រហែលខែ៧ ខែ៨ហ្នឹង ។

ដានី ៖ ចឹងដល់ពេលគាត់ផ្លាស់ទៅគេឲ្យពីណាមកជំនួសគាត់ ។

យឿក គាម៉ោង ។

ដានី ៖ គាម៉ោងហ្អី?

យឿក ៖ បាទ!គាម៉ោងគណៈស្រុក ។

ដានី ៖ គាម៉ោងហ្នឹងគាត់មកពីណាដែរមុនពេលជំនួសគាហ៊ុង?

យឿក ៖ ពីមុនគាត់នៅប្រធានយោធា ។

ដានី ៖ ប្រធានយោធា ។

យឿក ៖ ប្រធានយោធាមកប្រចាំការនៅស្រុកព្រះនេត្រព្រះកាលមុនគាត់មិនមែនប្រធានយោធាទេណាស យោធាដូចថាយោធាភូមិភាគ យោធាក្នុងតំបន់ណាស ដល់ក្រោយមកគេប្តូរគាត់មកធ្វើគណៈស្រុក ។

ដានី ៖ ចឹងពីដំបូងគាត់យោធាតំបន់មកប្រចាំនៅព្រះនេត្រព្រះហ្អី?

យឿក ៖ អត់ទេ យោធាតំបន់ ។

ដានី ៖ យោធាតំបន់ហ្អី? យោធាតំបន់៥ យើងហ្នឹង?

យឿក ៖ បាទ!

ដានី ៖ តែគាត់មកប្រចាំនៅព្រះនេត្រព្រះ?

យឿក ៖ បាទ!

ដានី ៖ ចឹងពេលគា លឿមគេផ្លាស់ទៅ គា ម៉ោង មកធ្វើជាគណៈស្រុក?

យឿក ៖ បាទ!

ដានី ៖ ចុះលោកពូយ៉ាងម៉េចដែរ?

យឿក ៖ ខ្ញុំ ដល់ពេលក្រោយមកគេរៀបចំបាននិយថាកាលនៅមន្ទីរស្រុកទាំងសេដ្ឋកិច្ចអីនៅលើយើងទាំងអស់ណាស ដល់ក្រោយមកគេត្រូវរើសឲ្យមានពាណិជ្ជ គេហៅពាណិជ្ជហ្នឹងគឺឥវ៉ាន់ទាំងអស់ចូលនៅក្នុងពាណិជ្ជ ។ ខ្ញុំគេឲ្យទៅនៅចល័ត ។

ដានី ៖ ទៅនៅចល័ត?

យឿក ៖ បាទ! ទៅនៅចល័តស្រុក ។

ដានី ៖ ឆ្នាំណាដែលគេដូរតួនាទី?

យឿក ៖ ប្រហែលជាដើមឆ្នាំ៧៦ ។

ដានី ៖ ដើមឆ្នាំ៧៦?

យឿក ៖ បាទ!

ដានី ៖ ដើមឆ្នាំ៧៦ ហ្នឹងអ្នកណាអ្នកផ្លាស់ពូទៅចល័តស្រុក?

យឿក ៖ ពីតំបន់ ។

ដានី ៖ ពីតំបន់?

យឿក ៖ ពីតំបន់៥ តាហ៊ីង ។

ដានី ៖ តាហ៊ីង?

យឿក ៖ បាទ!

ដានី ៖ តំបន់៥ ហ្នឹងតា ហ៊ីងគណៈតំបន់ហ្នឹ?

យឿក ៖ គណៈតំបន់ ។

ដានី ៖ ចុះក្រៅពីតា ហ៊ីងមានអ្នកណាទៀត?

យឿក ៖ ទេ មានតែខ្ញុំអត់ស្គាល់ទេ ស្គាល់តែអ្នកណាដែលចុះទៅជាប់ព្រោះពីដើមគណៈតំបន់អត់មានពេលមកផ្ទះទេចុះទៅដេកនឹងភក់នឹងជ្រាំជាមួយយើងដែរ ។

ដានី ៖ ចឹងពូស្គាល់តែ តា ហ៊ីងទេ គណៈតំបន់?

យឿក ៖ បាទ!

ដានី ៖ អត់មានអ្នកណាផ្សេងទៀតដែលជាបន្ទាប់ៗគាត់ណាស ។

យឿក ៖ អត់ ។

ដានី ៖ ដូចជានៅស្រុកមាន តា ម៉េង តា សំអាត ។

យឿក ៖ បាទ!

ដានី ៖ តែដល់គាត់មានពីណាផ្សេងទៀត?

យឿក ៖ អត់ស្គាល់ទេ ព្រោះយ៉ាងម៉េចបើយើងចុះទៅនៅតែស្រែ ចំការ ។

ដានី ៖ ចុះពូពេលពូចុះទៅភ្ជាប់នៅចល័តស្រុក ពូភ្ជាប់នៅចល័តស្រុកព្រះនេត្រព្រះហ្នឹង?

យឿក ៖ បាទ! អានោះគេហៅថាទទួលខុសត្រូវអ្នកដែលនៅក្នុងទីរួមស្រុកដូចទីរួមខេត្តចឹងណាស ។ខាងណាដែលគេចែកថាខាងនេះទៅនេះឃុំ ត្រឹមនេះមកនេះស្រុក ។

ដានី ៖ អីចឹងពូប្រធានចល័តស្រុកព្រះនេត្រព្រះ?

យឿក ៖ បាទ!ខ្ញុំនៅទទួលខុសត្រូវយុវជននៅហ្នឹងចល័តស្រុកគេណាស ។

ដានី ៖ ចុះយុវជនចល័តរបស់លោកពូមានប៉ុន្មានទៅ ហើយអាយុប្រហែលជាប៉ុន្មាន?

យឿក ៖ ទេ!កាលនោះប្រហែលជាប្រាំ ប្រាំមួយរយ ។

ដានី ៖ ប្រាំ ប្រាំមួយរយ ។ អាយុចន្លោះប៉ុន្មានទៅកាលនោះ?

យឿក ៖ ទេ!ភាគច្រើនចាប់ពី២៥មក១៨នេះឯង ។

ដានី ៖ ពី១៨ទៅ២៥?មានស្រីមានប្រុស?

យឿក ៖ អត់ទេ!ខ្ញុំយុវជនមានតែយុវជន,

ដានី ៖ សុទ្ធតែបុរស?

យឿក ៖ បាទ!

ដានី ៖ យុវជនហ្នឹងយើងមានសមាសភាពដូចថាពួក១៧មេសា ប្រជាជនមូលដ្ឋានហ្នឹងនៅជាមួយគ្នាបុយ៉ាងម៉េច?

យឿក ៖ លាយគ្នា ព្រោះអ្នកជម្លៀសភ្នំពេញអីមក ក្មេងៗនៅក្នុងក្រុម ។

ដានី ៖ ហ្អស!នៅក្នុងក្រុម ។ ចុះយុវជនចល័តហ្នឹងយើងរើសម៉េចទៅ?

យឿក ៖ យុវជនចល័តអត់មានជ្រើសរើសទេ ប្រៀបធៀបដូចថាពេលដែលយើងមានកូនប្រុសហើយវាត្រូវតែទៅនៅចល័ត ព្រោះពីដើមគេចង់និយាយថាអ្នកដែលនៅសហករណ៍ច្រើនតែវ័យកណ្តាលឲ្យតែយុវជនគឺទៅមុខព្រោះចល័ត ។

ដានី ៖ ដូចនៅចល័តពូធ្វើការងារអីខ្លះទៅពូចាប់ពីពេលដែលពូទៅដើមឆ្នាំ៧៦ហ្នឹង?

យឿក ៖ លើកទំនប់ ជីកប្រឡាយតែម្តង ។

ដានី ៖ លើកទំបន់ ជីកប្រឡាយហ្នង?

យឿក ៖ បាទ!លើកទប់អាភ្លឺស្រែខ្វាត់ខ្វែងជាហិចតាៗអីទាំងអស់ ហើយអាផ្លូវដែលយើងដើរតាមថ្នល់ហ្នឹងរហូត ពីដើមមិញមានផ្លូវមួយខាងនេះថ្នល់រហូត ។

ដានី ៖ ចុះលោកពូកាលនោះមុខព្រួញចល័តរបស់លោកពូដំបូងនៅឯណាទៅ?

យឿក ៖ ខ្ញុំចាប់ពីដប់ទៅព្រៃមាន់ ព្រៃមាន់រហាល់ ។

ដានី ៖ មានអីខ្លះទៅព្រៃមាន់ រហាល់?

យឿក ៖ មានខែស្ទូងគឺស្ទូង ខែច្រូតគឺច្រូត ច្រូតយកស្រូវ ហើយបញ្ជូនយកស្រូវហើយដឹកស្រូវប្រមូលមកដាក់នៅឃ្លាំងស្រុកទាំងអស់ ។

ដានី ៖ ចល័តរបស់លោកពូមានស្ទួង ច្រូត ចាប់ពីជប់វ៉ារីទៅព្រៃមាន់ រហាល់?

យឿក ៖ បាទ!ព្រៃមាន់ រហាល់ ព្រោះស្រែជួនកាលខាងស្រុកគេឲ្យទៅធ្វើនៅរហាល់ យើងទៅៗ ។

ដានី ៖ បាទ!យើងមានស្រែធ្វើខ្លួយើងមានស្រែធ្វើខ្លួនយើងឬទៅជួយប្រជាជន?

យឿក ៖ អត់ទេ ពីព្រោះអានេះគេចង់និយាយថា ក្នុងអង្គភាពស្រុកត្រូវមានស្រូវប៉ុន្មានហិចតាត្រូវយកស្រូវនោះមកបោកបែនហើយទុកដាក់ខ្លួនយើង ផ្គត់ផ្គង់នៅក្នុងអង្គភាពទៅហើយសល់ប៉ុន្មានយើងទៅឲ្យប្រជាជន ។

ដានី ៖ ហួស ប៉ុន្មានទៅស្រូវដែលធ្វើនៅព្រៃមាន់?

យឿក ៖ បើគិតទៅខាងស្រុក ប៉ុន្តែក្រោយមកខ្ញុំដាច់ពីស្រុកទៅរដ្ឋតំបន់ ក្រោយពីស្រុកមកណាស ឥឡូវគេបំបែកឲ្យមានរដ្ឋតំបន់ ស្រុកមាននាទីតែស្រុកទេ ។

ដានី ៖ បាទ!

យឿក ៖ រដ្ឋតំបន់បានន័យថាអ្វីៗទទួលបញ្ញាពីតំបន់ទាំងអស់ អត់មានស្រុកទេ ស្រុកគ្រាន់តែពិភាក្សាអីបាន ។ ដល់នេះទៅខ្ញុំគេដីចាប់ពីរហាល់ទៅដល់ព្រៃមាន់ ស្រូវស្រែដែលយើងច្រូតណាស ។

ដានី ៖ បានន័យថាម៉េចបានន័យថាចល័តតំបន់ហ្អី?

យឿក ៖ បានន័យថាកសិដ្ឋានរដ្ឋ បានន័យថាកសិដ្ឋានតំបន់ ។

ដានី ៖ កសិដ្ឋានរបស់តំបន់?

យឿក ៖ បាទ!ព្រោះតំបន់គេចុះផ្ទាល់ អត់មានស្រុកទេ ។

ដានី ៖ បាទ ចឹងពូដូចថាចាប់ផ្តើមផ្លាស់ពូពីចល័តស្រុកទៅរដ្ឋតំបន់ពីពេលណា?

យឿក ៖ អាហ្នឹងពេល៧៦ ។

ដានី ៖ ៧៦ ប្រហែលជាខែណាដែរ?

យឿក ៖ ប្រហែលខែជប់ខែអីហ្នឹង ។

ដានី ៖ ខែជប់៧៦ហ្អី?

យឿក ៖ បាទ!

ដានី ៖ អាហ្នឹងបើនិយាយឲ្យច្បាស់ទៅទៅជាស្អីវិញរដ្ឋតំបន់?

យឿក ៖ បើនិយាយទៅ រដ្ឋតំបន់បានន័យថាក្នុងអង្គភាពរដ្ឋតំបន់ ខ្ញុំជាអនុគេទេ ។

ដានី ៖ អនុកសិដ្ឋានតំបន់៥ ចឹងកាលនោះប្រធានអ្នកណា?

យឿក ៖ កាលនោះ តា ឆាង ។

ដានី ៖ តា ឆាងហ្អី?

យឿក ៖ បាទ!តែឥឡូវគាត់ស្លាប់បាត់ទៅហើយគេយកទៅសំលាប់ ។

ដានី ៖ តាឆាង ហើយពូអនុ?

យឿក ៖ បាទ!ខ្ញុំអនុទេ ។

ដានី ៖ ហ្អូស!កាលនោះមានគ្នាច្រើនទេ?

យឿក ៖ ច្រើន បីសហករណ៍ ។

ដានី ៖ បីសហករណ៍?

យឿក ៖ មនុស្សប្រហែលជាខ្ទង់ប្រាំ ប្រាំមួយពាន់ ។

ដានី ៖ មនុស្សប្រហែលជាខ្ទង់ប្រាំ ប្រាំមួយពាន់ហ្អី?

យឿក ៖ បាទ!

ដានី ៖ សុទ្ធតែយុវជនដដែល...

យឿក ៖ អត់ទេ!មួងនេះមានវ័យកណ្តាល តែយុវជនយើងមានមួយឡែកហើយណាស ។ តែកាលនោះយើងគ្រប់គ្រងវ័យកណ្តាលអីផងទៅ ។

ដានី ៖ ប្រហែលប្រាំ ប្រាំមួយពាន់នាក់? ធ្វើអីខ្លះទៅ?

យឿក ៖ ទេធ្វើការតាមសហកណ៍ដដែល បានន័យថាខាងរដ្ឋតំបន់គេចែកជាបីសហកណ៍ ។ បីសហកណ៍នោះយើងមានដូចថាចាស់ៗគាត់មិននៅខាងចំការ?

ដានី ៖ បាទ!

យឿក ៖ យុវជននារីនៅខាងស្ទូង ទំបន់ប្រឡាយអីទៅ ច្រូតអីក៏យើងទៅយកអង្ករអីទុកដាក់ ។

ដានី ៖ ចឹងកន្លែងកសិដ្ឋានតំបន់របស់លោកពូដីចាប់ពីណា ពីរហាល់ទៅព្រៃមាន់?

យឿក ៖ ចាំមើលណាសដីរបស់...ព្រោះស្រុកប្រគល់ឲ្យដីជុំវិញជប់នោះគឺដីរបស់កសិដ្ឋានរដ្ឋតំបន់ តែគេឲ្យចាប់ពីរហាល់ទៅព្រៃមាន់ផង ។

ដានី ៖ បាទ!ប៉ុន្មានទៅ ដីប៉ុន្មានរាប់ហិចតាទៅ?

យឿក ៖ ពីរហាល់ទៅព្រៃមាន់ប្រហែល៤គីឡូ ៧គីឡូអីអស់ហើយ ។ អាពីវត្ត រហាល់ទៅអាផ្លូវបត់ទៅវត្តភ្នំស្រុកយើងនេះ

ដានី ៖ បាទ!ចឹងលោកពូ តា ឆាងប្រធាន លោកពូអនុ ហើយមានអ្នកណាទៀតគ្រប់គ្រងនៅកសិដ្ឋានរដ្ឋ?

យឿក ៖ កាលនោះមានតែពីរ ។

ដានី ៖ មានតែពីនាក់?

យឿក ៖ ព្រោះខ្ញុំខាងយុវជនមិនសូវបាននៅ ។

ដានី ៖ ចុះមានបីសហកណ៍?

យឿក ៖ បាទ!

ដានី ៖ ក្នុងហ្នឹងពីណាគេប្រធានសហករណ៍ទី១ ទី១ ទី៣?

យឿក ៖ ឈ្មោះណាំប្រធានសហកណ៍ ។

ដានី ៖ ឈ្មោះណាំ ចុះទី២?

យឿក ៖ ទី២នោះ នារីឈ្មោះម៉េត ។

ដានី ៖ នារីម៉េត?

យឿក ៖ បាទ!

ដានី ៖ ចុះទី៣?

យឿក ៖ ទីបី ពុកសែត ឈ្មោះសែតតែហៅគាត់តែពុកៗ ចុះកាលនោះយើងក្មេងដែរ អើ សាមលើស ។

ដានី ៖ គាត់នៅរស់ទេទាំងបីនាក់ឈ្មោះណាំ ឈ្មោះម៉េត ឈ្មោះសែត?

យឿក ៖ ស្លាប់អស់ហើយបើមិនដែលជួបផង ។

ដានី ៖ អត់ដែលជួបទេហ្ន?

យឿក ៖ ខ្ញុំដើរពេញវាលពេញកាលម៉ាបន្ទាយមានជ័យនេះអត់ដែលជួបផងអត់ដែលចន្លោះភូមិណាផង ។

ដានី ៖ កសិដ្ឋានរដ្ឋតំបន់យើងធ្វើស្រែវិយៗកណ្ដាល?

យឿក ៖ ធ្វើស្រែ បានន័យថាជាកន្លែងសំរាប់កសិកម្ម ។

ដានី ៖ ចឹងកសិដ្ឋានរដ្ឋពីណាគេគ្រប់គ្រង?

យឿក ៖ ពីតំបន់ ។

ដានី ៖ ពីតំបន់?

យឿក ៖ បាទ!

ដានី ៖ ពីតំបន់ប្រាំតាហ៊ុងហ្នឹងហ្មង?

យឿក ៖ បាទ!

ដានី ៖ អត់មានចំណុះស្រុកអីទេ?

យឿក ៖ អត់ទេ ប៉ុន្តែយើងអាចពិភាក្សាគ្នាបាន ព្រោះអីគេស្រុកចង់ធំជាងយើងដែរ ។

ដានី ៖ ចុះតា ឆាងគាត់នៅធ្វើប្រធាននៅហ្នឹងរហូតដែរ?

យឿក ៖ ឆ្នាំ៧៥ គេត្រូវរំលាយចេញ ។

ដានី ៖ ចុងឆ្នាំ៧៦?

យឿក ៖ បាទ!

ដានី ៖ ខែប៉ុន្មាន?

យឿក ៖ ដើមឆ្នាំ៧៧ គេរំលាយចេញតែម្ដង គេរំលាយយ៉ាងម៉េច? ភូមិនៅជិតនោគេរំលាយឲ្យទៅខាងសហករណ៍ទៅឃុំណាស!គេរំលាយចោលបានន័យថាខ្ញុំអត់ប្រពន្ធគេឲ្យទៅនៅចល័តតំបន់ អ្នកមានប្រពន្ធនៅតាមភូមិ អ្នកអត់ប្រពន្ធទៅនៅចល័តតំបន់បានឡើងដល់ត្រពាំងថ្ម ។

ដានី ៖ បាទ!លោកពូចឹងចុងឆ្នាំ៧៦ ដើម៧៧ហ្នឹងគេរំលាយរដ្ឋតំបន់?

យឿក ៖ បាទ!

ដានី ៖ ចុះតា ឆាងម៉េចគេរំលាយចេញ?

យឿក ៖ តា ឆាងគាត់ទៅខាងសាខាស្រុក សាខាបានន័យថាជំនួយការរបស់ស្រុក តែគាត់ទៅខាងប្រាសាទ ប្រាសាទ ទឹកជោរប៉ុន្មានឃុំ ។

ដានី ៖ ចុះមូលហេតុអីបានជាគេរំលាយកសិដ្ឋានរដ្ឋ?

យឿក ៖ គេហៅថាវាអាចមានបញ្ហាពេលដែលដោះស្រាយទៅវាចេះតែមានជំលោះដោយសារអីព្រោះកសិដ្ឋានរដ្ឋនេះធ្វើស្រែបានគ្រាស់ក្រែល ម្ល៉ោះហើយយើងស៊ីបបរគ្រប់គ្រាន់ ខាងសហករណ៍គ្នាអត់គ្រប់គ្រាន់ទេ ម្ល៉ោះហើយសម័យនោះគេចង់ឲ្យស្មើភាពគ្នា ខាងនោះរករឿងខាងនេះ ខាងនេះរករឿងខាងនោះ ខ្ញុំនៅទីនោះខ្ញុំដឹង ។ខាងឃុំគេចោទយើងថាមានហូបបបរចង់លាយបាយរឹង ខ្វះទេណាស!តែពេលប្រជុំក៏ខ្ញុំនិយាយដែរថា ការស៊ីចុកទៅតាមអ្វីដែលរកបាន មិនអញ្ចឹង?ខ្ញុំធ្វើស្រែបានរាប់ម៉ឺនបាវ រាប់ពាន់បាវខ្ញុំត្រូវតែគ្រប់គ្រងឲ្យកន្ទែងខ្ញុំស៊ីម៉ាគ្រប់ ត្រង់ខាងស្រុក តំបនអីមកស្នើយកទៅមានថាអី ។

ដានី ៖ ពូពេលពូជដែកមានទំនាស់រឿងហូបចុកហ្នឹងពូនិយាយជាមួយអ្នកណាខ្លះ?

យឿក ៖ របធំស្រុក ប្រជុំស្រុក ប្រជុំឃុំអីណាស ព្រោះបានន័យថាខាងឃុំគេចោទយើងថាការហូបចុកអីវាអត់ឯកភាពគ្នា ព្រោះតាមសហករណ៍គេស៊ីបបររាវ សហករណ៍យើងស៊ីបបរខាប់ម្ល៉ោះហើយវាទាក់ទងទៅលើអាស្រូវអង្ករហ្នឹងទៀត ។

ដានី ៖ ចុះពេលប្រជុំជាមួយតាហ៊ីង ជាមួយគណៈស្រុកអីគេលើកពីបញ្ហាហ្នឹងដែរ?

យឿក ៖ ទេ គេហៅទៅប្រជុំគេឲ្យដោះស្រាយណាស តែដោះស្រាយវាមិនចេះចប់មិនចេះហើយ ដល់ក្រោយមកគេឲ្យរំលាយរដ្ឋតំបន់ទៅ ។

ដានី ៖ រំលាយ តា ឆាងគាត់ទៅខាងសាខាស្រុក ឃុំប្រាសាទ?

យឿក ៖ បាទ!

ដានី ៖ ហើយអ្នកដែលរ៍យកណ្តាលមានប្តីប្រពន្ធចូលទៅខាងសហករណ៍ ចុះយុវជនយុវនារី?

យឿក ៖ ទៅតាមខ្ញុំ!

ដានី ៖ ទៅតាមលោកពូចឹងគ្នាប្រហែលជាប៉ុន្មានទៅ?

យឿក ៖ កាលនោះប្រហែល៣០០ ទាំងស្រីទាំងប្រុស ។

ដានី ៖ ទាំងស្រីទាំងប្រុស៣០០?

យឿក ៖ បាទ!

ដានី ៖ លោកពូមានប្រសាសន៍ថានៅកសិដ្ឋានរដ្ឋតំបន់មានដល់ទៅប្រាំ ប្រាំមួយពាន់នាក់?

យឿក ៖ បាទ!ប៉ុន្តែដោយសារអី ប្អូនឯងមានគ្រួសារមិននៅសហករណ៍?

ដានី ៖ បាទ!

យឿក ៖ ហេតុនេះកូនខ្វះក៏ទៅនៅខាងសហករណ៍ខ្វះទៅណាស!

ដានី ៖ បាទ!

យឿក ៖ ហេតុនេះយើងគឹងតែងពេកក៏មិនកើត ដូចអ្នកដែលសុំទៅតាមម៉ែហើយ ចុះយើងធ្វើម៉េច បើរំលាយព្រោងព្រាតហើយអ្នកណានៅប៉ុន្មាននៅទៅពីបាកអី ។

ដានី ៖ ចឹងអ្នកដែលទៅតាមពូប្រហែលជា៣០០ហ្អឺ?

យឿក ៖ ហ្នឹងហើយ ជាង៣០០ ។

ដានី ៖ ប្រហែលជា៣០០ ហើយពូទៅខាងចល័តតំបន់វិញ?

យឿក ៖ ចល័តតំបន់ ។

ដានី ៖ ចឹងពូទៅជាប្រធានចល័តតំបន់?

យឿក ៖ អត់ទេ ប្រធានចល័តតំបន់គាត់ឈ្មោះ វ៉ាល់ ។

ដានី ៖ តាវ៉ាល់ គាត់ប្រធានចល័តតំបន់?

យឿក ៖ បាទ!

ដានី ៖ ចុះអនុ?

យឿក ៖ ទេ អត់មានអនុទេ មានប្រធានគាត់មួយ យើងគណៈកម្មការចល័ត៧រូបទៀត ។

ដានី ៖ គណៈកម្មការចល័ត៧រូបហ្អី?

យឿក ៖ បាទ!ទាំងនារី ទាំងយុវជន ។

ដានី ៖ អ្នកណាខ្លះទៅ៧រូបហ្នឹង?

យឿក ៖ ដូចចាំមិនអស់ទេ!

ដានី ៖ ចុះពូមានចាំខ្លះទេ?

យឿក ៖ វាចាំខ្លះដែរ ។

ដានី ៖ ចឹងពូអាចរៀបរាប់បានទេ?

យឿក ៖ មានឈ្មោះសន សនហ្នឹងគេដកវាចេញពីអនុឃុំ ។ សន ហើយតាខូវ ឈ្មោះចាន់ ហើយអ្នក ណាទៀតទេ...ខ្ញុំដែរ ហើយមាននារី៣នាក់ អាហ្នឹងខាងនារីណាស!

ដានី ៖ បាទ!លោកពូមានចាំគាត់ទេ?

យឿក ៖ មួយឈ្មោះមិត...

ដានី ៖ បាទ!នារីមិត ។

យឿក ៖ ហើយមួយទៀតឈ្មោះរួម ។

ដានី ៖ ឈ្មោះរួម? ហើយមួយទៀត?

យឿក ៖ មួយទៀតឈ្មោះវ៉ាន ។

ដានី ៖ វ៉ានហ្អី?

យឿក ៖ បាទ!

ដានី ៖ មិត ឥឡូវគាត់នៅឯណាមិត?

យឿក ៖ ហួស នៅសៀមរាមនៅអីមិនដែលបានជួបទេ តែអ្នកនៅនេះថាទៅអាមេរិទៅអី ។

ដានី ៖ ចុះឈ្មោះវ៉ាន?

យឿក ៖ វ៉ាននោះអត់ដែលជួបទេខ្ញុំសព្វថ្ងៃមិនដឹងថាទៅនៅខាងណាខាងណីទេ ។

ដានី ៖ ចុះក្នុងចំណោះម៧នាក់ក្នុងគណៈកម្មការមាននៅរស់ប៉ុន្មាននាក់ទៅ?

យឿក ៖ ទេ សព្វថ្ងៃស្លាប់ច្រើនដែរបើតាមការពិតខ្ញុំមើលទៅ ថារស់ក៏មិនដឹងយ៉ាងម៉េចព្រោះអ្នក ដែលថារស់មានតាខូវ តាវនអី នៅកំបោរនេះ ប៉ុន្តែឥឡូវមិនដឹងយ៉ាងម៉េចបើបែកគ្នាយូរ ។

ដានី ៖ តា ខូវ ហើយតា វនហ្អី?

យឿក ៖ បាទ!

ដារ៉ា ៖ ចឹងតាវ៉ននៅក្នុងសមាជិក៧រូបហ្នឹងដែរពូ?

យឿក ៖ បាទ! នៅក្នុងដែរតែមិនមានទេ ព្រោះអានោះគេហៅថាក្ដាប់មុខព្រួញណាស!ឧបមាថាខាងសំណាង់ចឹងអ្នកណាគេទទួលខុសត្រូវចឹងណាសដោយឡែកទៅណាស ។ ដូចពួកខ្ញុំអីទៅដេកជុំជាមួយពួកនារី ពួកយុវជនយើងដេកនៅ ស៊ីអត់ស៊ីឃ្លានជុំគ្នាចឹងទៅ ។

ដារ៉ា ៖ ចុះពូក្នុងចំណោម៧រូបនៅក្នុងគណៈកម្មការហ្នឹងទទួលខុសត្រូវផ្សេងៗយ៉ាងម៉េចទៅ?

យឿកៈ បែកមុខសញ្ញាគ្នា ។

ដារ៉ា ៖ ឧបមាថា សំរាប់ពូផ្ទាល់មុខសញ្ញាពូសំរាប់ធ្វើអី?

យឿក ៖ ជួនកាលខ្ញុំគេឲ្យទៅនៅខាងទឹក ដូចតំបន់នេះប៉ុន្មានរយចឹងទៅដើរមើលទឹក ដូចថាកន្លែងណាដែលត្រូវធ្លាយត្រូវទប់យ៉ាងម៉េចគឺយកកំលាំងមកដាក់ ។ ហ្អ៊ុក!ខាងមួយនោះគេខាងប្រឡាយទំបន់អីចឹងទៅ ហើយអាខ្លះទៀតគេទៅខាងធ្វើលូធ្វើអីចឹងទៅណាស ។ មានមុខសញ្ញាផ្សេងៗគ្នា ប៉ុន្តែវាដូចតែគ្នាទេ ព្រោះពេលមកជុំគ្នាចេះតែលើកបទពិសោធន៍ទៅ ។ ដូចថាយើងធ្វើ ទិសដៅគេឲ្យធ្វើលូប៉ុន្មានខែប៉ុន្មានថ្ងៃឲ្យរួច បើមិនរួចមូលហេតុអីដូចប្អូនឯងមិនរួចចឹងមូលហេតុអី? ប្អូនឯងត្រូវប្រាប់គេតាមជាក់ស្ដែងដូចថាទីវាដោយសារភាគរួសមានជីងី ហេតុនេះវាស្ទះវាអសកម្មទៅ ។

ដានី ៖ ចឹងលោកពូ អាហ្នឹងនៅចុងឆ្នាំហ្អីដែលលោកពូទៅចល័តតំបន់ដែលមានគណៈតំបន់ គេមានតាំងពីមុនមកឬទើបតែមាន?

យឿក ៖ អត់ទេ!ទើបតែមានទេ ។

ដានី ៖ ចុងឆ្នាំ៧៦ពេលពូទៅគេរៀបចំឲ្យមាន?

យឿក ៖ ទៅគេរៀបចំតែម្ដង ពីព្រោះកាលមុនអត់មានទេព្រោះតា វ៉ាល់គាត់ប្រធានកងទ័ព ។

ដានី ៖ ប្រធានកងទ័ព?

យឿក ៖ បាទ!គេដកគាត់មក ។

ដានី ៖ ចឹងតាវ៉ាល់មុនពេលគាត់មកធ្វើប្រធានកងទ័ពនៅឯណាទៅ?

យឿក ៖ នៅតំបន់៥យើងនេះដែរ ។

ដានី ៖ តំបន់៥ហ្អី?

យឿក ៖ បាទ!

ដានី ៖ ចឹងបានន័យថាគាត់ប្រធានកងទ័ពតំបន់៥ពីមុនមក?

យឿក ៖ មិនមែនប្រធានយោធានៅតំបន់នោះទេដូចថាប្រធានកងវីរៈ ។

ដានី ៖ ហួស!ចុះកាលនោះប្រធានយោធាតំបន់៥ពីណាគេ?

យឿក ៖ តាចយ ឈ្មោះចយ ។

ដានី ៖ ឈ្មោះចយ? ចុះឈ្មោះភីធ្វើអីគេ?

យឿក ៖ ភីនោះក៏សាខាគេដែរ ។

ដានី ៖ ចឹងតាចយ ធំជាងហ្អី?

យឿក ៖ ទេ មិនដឹងអ្នកណាធំជាងទេព្រោះយើងអត់បានដឹង ។

ដានី ៖ បាទ!តែគ្រាន់តែដឹងថាតាវ៉ាល់ជាប្រធានយោធាតំបន់៥មុននឹងមកធ្វើប្រធានកងចល័ត ។

យឿក ៖ បាទ!

ដាវ៉ា ៖ គាត់ជាប្រធានវីរៈហ្នឹងវីរៈសេនាតូចឬវីរសេនាធំ?

យឿក ៖ ទេ!តាវ៉ាល់ ចាមើលខ្ញុំចង់និយាយថាដូចជាវិរៈសេនាធំ គ្រាន់តែប្រហាក់ប្រហែលទេព្រោះកាលនោះយើងមិនសូវដឹងដូចអូនឯងថាកងវីរៈ១ ហើយយើងមិនដឹងថាប្រើពាក្យអីត្រឹមណាត្រូវសក្តិប៉ុន្មានអីទេ ។

ដាវ៉ា ៖ បើសិនជាចំនួនទ័ពដែលគាត់ក្តាប់ប្រហែលប៉ុន្មាននាក់ដែរក្រោមការគ្រប់គ្រងរបស់តាវ៉ាល់?

យឿក ៖ ទេ ប្រហែលជា៤០០នាក់ ប៉ុន្តែដោយសារទ័ពវាអត់មានពេញលេញទេ ។

ដាវ៉ា ៖ ចឹងអាចថាវីរៈសេនាធំហើយ!

យឿក ៖ បាទ!ប្រហែលវីរៈសេនាធំហើយបានជាមានសិទ្ធិមកធ្វើប្រធានចល័តតំបន់ មិនមែនតូចឯណា ។ ក្នុងតំបន់៥នេះមានតែតា វ៉ាល់ហើយ អ្នកណាក៏ស្គាល់ដែរ ប្អូនឯងទៅតាមភូមិចឹងចំមើលទៅថាតា វ៉ាល់កាចណាស់ ។

ដានី ៖ តា វ៉ាល់កាចមែនហ្អី?

យឿក ៖ កាចមែន ។

ដានី ៖ ពូអាចរៀបរាប់ពីអត្តចិត រាងរៅអីគាត់យ៉ាងណាដែរ?

យឿក ៖ គាត់រាងស្តើង គាត់នៅកំពង់ចាមតាវ៉ាល់ ។

ដានី ៖ តាវ៉ាល់អ្នកកំពង់ចាម? គាត់រាងស្តើង? ចុះសំបុរសំបកយ៉ាងម៉េចដែរ?

យឿក ៖ រាងស្រអែម តែកាលនោះបើអាណាសកើតទៅស្រអែមហើយគ្មានអ្នកណាបានធ្វើអី លាបអីទេ!

ដានី ៖ ចុះសក់គាត់យ៉ាងម៉េចដែរ?

យឿក ៖ សក់ស្កូតធម្មតា ។

ដានី ៖ សក់ស្កូត សក់វែងសក់ខ្លី?

យឿក ៖ ទេ សក់ហ្នឹងកណ្តាលអត់មានខ្លីហួសអីទេ ព្រោះសក់ជំនាន់នោះគេនិយាយថា...ដែលគេធ្វើការទេណាសដល់ពេលអត្តភាពនោះគេចង់និយាយថា...ដែលគេធ្វើការទេណាស ។ ចង់និយាយថា គេហៅជាងកាត់សក់មកប្រាប់ថា ការកាត់សក់មិនមែនធ្វើតាមអ្នកឯងបានទេ ។ ឧទាហរណ៍ថាបើក្បាលវាទំពែកយើងទៅកាត់ឲ្យអស់យ៉ាងម៉េច? គេនិយាយចេះណាស!ទុកសិទ្ធិសេរីភាពឲ្យគេផង ។

ដានី ៖ បាទ!

យឿក ៖ បើក្បាលវាឆក កាត់ឲ្យមានគ្រប់ដណ្តប់អីខ្លះទៅ យើងកុំដាក់គ្រងិល នេះបិយាយការពិតណាស ។ គេធ្វើការចឹងហ្នង មិនមែនយើងជាងកាត់សក់ហើយទៅដល់ទៅ...

ដានី ៖ ចឹងតា វ៉ាល់សំដីសំដៅគាត់យ៉ាងម៉េច?

យឿក ៖ ទេ!សំដីម៉ាត់ៗតែម្តង ។

ដានី ៖ សំដីម៉ាត់ៗ?

យឿក ៖ ហើយអានេះបើតាមខ្ញុំមើលគំនិតផ្សំរបស់គាត់ខ្ញុំគ្រូបង្រៀនយ៉ាងតូចបំផុត ។

ដានី ៖ គ្រូបង្រៀនយ៉ាងតូចបំផុត?

យឿក ៖ បាទ!ពីព្រោះភាសាបារាំងអីដើរនិយាយគ្នាជាមួយតាហ៊ីងតាអី ព្រោះតា ហ៊ីងប្រូហ្វេស័រនៅភ្នំពេញ ។

ដានី ៖ បាទ!គាត់និយាយភាសាបារាំងពេលជួបតា ហ៊ីង?

យឿក ៖ បាទ!ជួបគ្នាដើរនិយាយភាសាបារាំង ។

ដានី ៖ ពូធ្លាប់ឮគាត់និយាយភាសាបារាំងជាមួយតា ហ៊ីងដែរឬយ៉ាងម៉េច?

យឿក ៖ ទេ!និយាយតើចុះយើងដើរពីក្រោយជូនកាលគេដើរមើលទំនប់ចឹងណាស អ៊ីដែលគេមិនចង់ឲ្យយើងស្តាប់បានគេនិយាយទៅ ដូចនិយាយលេងបួនដប់ម៉ាត់ចឹងទៅណាស ។

ដានី ៖ បាទ!កាលនោះវ័យគាត់យ៉ាងម៉េចដែរ ប្រហែលប៉ុន្មានដែរកាលពូជួបគាត់នៅចុងឆ្នាំ៧៦?

យឿក ៖ ប្រហែល៣៨ ៣៩ បើតាមខ្ញុំមើល ។

ដានី ៖ ចុះតា ហ៊ីង?

យឿក ៖ តា ហ៊ីងប្រហែលជាជាងសែ សែតូច ។

ដានី ៖ សែទាបហ្អី?

យឿក ៖ ទាប ព្រោះតា ហ៊ីងនោះគាត់មាឌតូចល្អិត ។

ដានី ៖ តូចល្អិត!

យឿក ៖ ខ្មៅ ។

ដានី ៖ តា ហ៊ីងអ្នកស្រុកណាដែរ?

យឿក ៖ ទេក្តាប់មិនបានទេតា ហ៊ីង ព្រោះគាត់ប្រូហ្វេស័រចេញមកពីភ្នំពេញមក ។

ដានី ៖ មកពីភ្នំពេញ? ចឹងតាវ៉ាល់គាត់អត្តចរិតគាត់យ៉ាងម៉េចដែរ?

យឿក ៖ អត្តចរិតគាត់នោះគាត់ចង់និយាយ ឲ្យអ្នកនិយាយឲ្យវើងពិត ។

ដានី ៖ និយាយពិត?

យឿក ៖ បាទ!មិនចង់ឲ្យម្តងដាប់ម្តងផ្ងារទេ នេះបើតាមខ្ញុំក្តាប់អត្តចរិតគាត់ណាស ហើយមិនចូលចិត្ត អ្នករដេបរណេមទៀត ដូចយើងទៅអីទទ្រេទទ្រេទអីអត់បានទេ រករឿងរាប់ ។

ដានី ៖ ករឿងយ៉ាងម៉េចទៅ?

យឿក ៖ រករឿង គេចង់និយាយថាគាត់សួរយើងថាពីសង្គមធ្វើអី ជាកូនទាហានគេទេដឹងព្រោះបាន ជាឃើញខ្ញុំមានឋានៈប៉ុណ្ណេះធ្វើទទ្រេទទ្រេទដូចយើងទាហានគោរពសក្តិពីរ សក្តិបីណាស់ ។ ព្រោះអានេះគេចង់និយាយថាគេរំលាយអស់ហើយមិនឲ្យមានគោរពមិនគោរព...មានចាប់ ដៃចាប់អីចឹងទៅ ។

ដានី ៖ ចុះដូចថាអ្នកដែលទទ្រេទទ្រេទទៅរណេបរណេបគាត់ហ្នឹងធ្វើអីដែរ?

យឿក ៖ មានដែរ អ្នកខ្លះធ្វើអាស៊ីដង់ ប្រាប់ត្រង់ ។

ដានី ៖ ដល់ធ្វើចឹងគាត់មានចាត់វិធានការណ៍ធ្វើយ៉ាងម៉េច?

យឿក ៖ អត់ទេអត់មាននិយាយអីផង ព្រោះគេចង់និយាយថាសម័យនោះវាទៅតាមតំបន់ទៅតាម កន្លែងណាស ហើយតំបន់ខ្លះទាហានក៏ដោយប៉ូលីសក៏ដោយតែគេដាក់ខ្លួនដាក់កាយហើយ បានន័យថាវាអស់ណាស តែយើងកុំទៅបន្តរឿង ។

ដានី ៖ ចឹងលោកពូគេចាប់ផ្តើមរៀបជាកងចល័តតំបន់ដែលមានគណៈកម្មការ៧រូបហ្នឹងនៅចុង ឆ្នាំ៧៦ ?

យឿក ៖ បាទ!

ដានី ៖ ហើយយ៉ាងម៉េចទៅបន្តការងាររបស់គណៈតំបន់?

យឿក ៖ គេប្រមូល ប្រមូលទៅទាំងអស់ទៅនៅតាមវាលស្រែវាលអីអ្នកណាត្រូវលើកទំនប់ ទៅជីក អាងធអី តែកាលនោះអត់ទាន់ចូលដល់ទំនប់ត្រពាំងថ្មទេ ។

ដានី ៖ បាទ!ចឹងលោកពូជួយរៀបរាប់តាំងពីដំបូងចាប់ផ្ដើមពីមានរចនាសម្ព័ន្ធ រួចហើយចាប់ផ្ដើមដំបូងយើងធ្វើការ នៅទីណាទៅចល័តទាំងអស់ហ្នឹង?

យឿក ៖ តំបន់កបើតាមខ្ញុំដឹងនៅស្រុកព្រះនេត្រព្រះហ្នឹងច្រើនជាងចល័តនៅតំបន់ផ្សេងៗទាំងអស់ពីព្រោះនោះគេហៅថាសំបូរទៅដោយវាលទំនាប ហើយដីវាច្រើនគេប្រមូលសំរុកទៅនោះទាំងអស់...

ដានី ៖ លោកពូខ្ញុំសុំកាត់បន្តិច ចល័តតំបន់ទាំងអស់មានគ្នាប៉ុន្មាននាក់ទៅចល័តទូទៅ?

យឿក ៖ បើខ្ញុំដឹង ប្រាំប៉ុលពាន់នាក់ដំបូង ។

ដានី ៖ ប្រាំប៉ុលពាន់ហ្នឹងហ្អី?

យឿក ៖ បាទ!អានេះនិយាយតែតំបន់ទេណាស!

ដានី ៖ ចុះ ប្រាំប៉ុលពាន់ហ្នឹងមានអាយុពីប៉ុន្មានទៅប៉ុន្មានទៅហើយស្រីប៉ុន្មានប្រុសប៉ុន្មានទៅ?

យឿក ៖ ទេ បើការពិតខ្ញុំអត់ប្រពន្ធក៏គេយកទៅនៅចល័ត ។

ដានី ៖ ចល័តតំបន់គឺអ្នកអត់ទាន់មានគ្រួសារអត់ទាន់មានប្ដីមានប្រពន្ធ?

យឿក ៖ បាទ!

ដានី ៖ ពូដឹងថាមានស្រីប៉ុន្មានប្រុសប៉ុន្មានដែរបើតាមពូស្មាន?

យឿក ៖ បើយើងគិតទៅស្រីច្រើនជាងប្រុស ។

ដានី ៖ ស្រីច្រើនជាងប្រុស?

យឿក ៖ ក្នុង ប្រាំប៉ុលពាន់នាក់មានស្រីបួនហើយប្រុសមានតែបីទេ ។

ដានី ៖ ចឹងពូដល់ពេលពូថាម៉េចស្រុកព្រះនេត្រព្រះមានវាលទំនាបច្រើនចឹងយើងចាប់ផ្ដើមដំបូងយើងធ្វើអីទៅ?

យឿក ៖ លើកទំនប់ លើកទំបន់ ជីកប្រឡាយតាមថ្នល់លើកកាត់អូរកាត់អីអត់និយាយថាឃុំណាស្រុកណាអីទេ ។ ដល់តំបន់នោះបានន័យថាអត់មានតួនាទីគេឲ្យទៅណាក៏បាន នេះមានមកនៅដល់សាលាក្រហមសាលាអីកាលនោះជំនាន់គាស្រួចហើយដល់ក្រោយមកបានគេដូរគាស្រួចចេញ ។ នៅសាលាក្រហមនៅតាគង់ពេញម៉ាតំបន់ ។

ដានី ៖ ពេញម៉ាតំបន់?

យឿក ៖ បាទ!

ដានី ៖ ចុះនៅខាងព្រះនេត្រព្រះពីដំបូងគេចាប់ផ្ដើមជីកទំនប់លើកប្រឡាយអីខ្លះទៅពូ?

យឿក ៖ ពីស្រែះទៅកំបោរ ។

ដានី ៖ ពីស្រែះទៅកំបោរ?

យឿក ៖ មានដែលទៅទេ? អាទំនប់...

ដានី ៖ ខ្ញុំទៅដល់ស្រែះ ។

យឿក ៖ ចេញពីស្រែះមុខវត្តទៅកើតចឹងទៅណាស ទៅកើតចេះទៅត្រង់ព្រិញទៅទល់ភ្នំ ដល់ស្ទឹងកំបោរ អាហ្នឹងហើយដែលគេហៅទំនប់កំបោរស្រែះ ។

ដានី ៖ បាទទំនប់កំបោរស្រែះ ។ លោកពូ មិញយើងដល់ទៅលើកទំបន់កំបោរស្រែះ ។

យឿក ៖ កំបោរស្រែះ ។

ដានី ៖ ទំនប់កំបោរស្រែះហ្នឹងពូបានចូលរួមដែរទេ?

យឿក ៖ ទំនប់កំបោរស្រែះហ្នឹងខ្ញុំអត់បានចូលរួមទេ កាលនោះខ្ញុំនៅខាងរដ្ឋតំបន់ហេតុនេះគា វ៉ាល់ម្នាក់ឯង ហើយមានបន្តបន្ទាប់វរៈសេនាធំសេនាតូចគេណាស្ស

ដានី ៖ ចឹងទំនប់កំបោរស្រែះហ្នឹងគេលើកតាំងពីពូនៅកសិដ្ឋានមកម្លេះ?

យឿក ៖ បាទ!

ដានី ៖ ចឹងតាំងពីមុនហ្នឹងទៀត?

យឿក ៖ បាទ!

ដានី ៖ បាទ!ចុះពូនិយាយពីបទពិសោធរបស់លោកពូវិញពេលដែលពូចូលដល់កន្លែងចល័តតំបន់នៅក្នុងគណៈកម្មការទាំង៧រូបណាស ចឹងយើងចាប់ផ្តើមយ៉ាងម៉េចទៅ?

យឿក ៖ គេចាប់ផ្តើមលើក ព្រោះកាលនោះគេចង់និយាយថា មុនពេលគេលើកទំនប់ណាមួយប្រវែងប៉ុន្មាន បាតប៉ុន្មាន កំពស់ប៉ុន្មាន ទទឹងប៉ុន្មាន ហើយត្រូវកំលាំងប៉ុន្មានធ្វើប៉ុន្មានថ្ងៃទើបរួច ហេតុនេះយើងគណៈកម្មការទៅស្តាប់គេឲ្យច្បាស់បានយើងទៅ ប្រជុំតាមកងទៀត ។ ហេតុនេះគេចង់និយាយថាទំនប់មួយមានប្រវែង...អានេះឧទាហរណ៍ទេណាស ទំនប់មួយប្រវែង៣០០០ម៉ែត្រ ក្នុងម្នាក់កន្លះម៉ែត្រអានេះឧទាហរណ៍ទេណាស បើសិនជាប្អូនឯងមានកំលាំង១០០នាក់ក្នុងកងត្រូវបានប្រវែងប៉ុន្មានម៉ែត្របើម្នាក់កន្លះ?

ដានី ៖ បាទលោកពូយើងចាប់ផ្តើមនិយាយពីត្រពាំងថ្មយើងចាប់ផ្តើមពេលណាហើយមានភ្លែនយ៉ាងម៉េចដែរ?

យឿក ៖ អានេះនិយាយដល់ត្រពាំងថ្មគេត្រូវប្រមូលចល័តនៅតាមស្រុកឲ្យអស់ទៅរួមជាមួយចល័តតំបន់ ។

ដានី ៖ ស្រុកណាខ្លះពូ?

យឿក ៖ ទាំងអស់ ចាំមើលថ្មពួក ភ្នំស្រុក អានេះយើងចង់និយាយសាដើមថាក្នុងគំរោងធ្វើអាងត្រពាំងថ្មនេះមានស្រុកថ្មពួក ភ្នំស្រុក ហើយសោរីសោភ័ណ្ឌ ហើយព្រះនេត្រព្រះ...ស្រុកណាទៀតទេ!

ដានី ៖ មង្គលបុរីដែរអត់?

យឿក ៖ អត់ទេ!ហួសភ្នំលាប អត់ទេភ្នំលាបឃុំ ចាំមើលជួយគិតគ្នាណាស!

ដានី ៖ បាទ!

យឿក ៖ ភ្នំស្រុក ថ្មពួក សោរីសោភ័ណ្ឌ ព្រះនេត្រព្រះ ស្វាយអត់ទេតែបួន...

ដានី ៖ មាន៤ស្រុកទេចឹងតំបន់៥មានតែ៤ស្រុកទេ?

យឿក ៖ ៤ស្រុក!

ដានី ៖ បាទ!ហើយ៤ស្រុកបូកជាមួយចល័តតំបន់?

យឿក ៖ បាទ!

ដានី ៖ ដំបូងខ្ញុំចង់ដឹងពីគំរោងចាប់ផ្តើមធ្វើគេមានប្រជុំអីយ៉ាងម៉េច ។

យឿក ៖ គេប្រជុំទីមួយគេប្រជុំរើសគំៈកម្មការវាស់វែង វាស់វែងថ្នល់ និងតំរង់ថ្នល់តែម្តងតំរង់ឲ្យវាត្រង់ណាស?

ដានី ៖ បាទ!

យឿក ៖ ហើយអ្នកដែលតំរង់ថ្នល់នោះគឺចាប់ពីដូនឧយនេះទៅទល់នឹងអន្លុងវែងបណ្តោយ ។

ដានី ៖ ដូនឧយទៅដល់អន្លុងវែង ដូនឧយអីព្រំដែនថៃណោះហ្នឹង?

យឿក ៖ ព្រំដែនថៃហ្នឹងថ្មពួកនោះ ពីព្រោះដូនឧយបានន័យថាអាផ្លូវពីដើមមកពីស្រុកថៃរហូតដល់អន្លុងវែងណោះ ។

ដានី ៖ លោកពូអាចជួយរៀបរាប់កន្លែងហ្នឹងឲ្យច្បាស់បន្តិចពីព្រោះខ្ញុំអត់ទាន់យល់ពីដំបូងអ្នកណាមកប្រជុំហើយមានផែនការអីយ៉ាងម៉េចពីដំបូងដែលមកធ្វើ?

យឿក ៖ តំបូងគេមានភូមិភាគ មានតំបន់ មានស្រុកហើយប្រធានចល័តតំបន់ គាវ៉ាល់ គេទៅប្រជុំដើម្បីរៀបគំរោង ។

ដានី ៖ ប្រជុំនៅឯណាទៅ?

យឿក ៖ ប្រជុំនៅស្វាយ ។

ដានី ៖ ប្រជុំនៅស្វាយ តំបន់៥ ។ ពូប្រជុំខែណា ឆ្នាំណាដែលមកពីភូមិភាគតំបន់ស្រុកអីដែលមកប្រជុំហ្នឹង?

យឿក ៖ មិនដឹងពេលណាទេមិនសូវចាំទេ...

ដានី ៖ អាចថាខែ?

យឿក ៖ ពីព្រោះអាងត្រពាំងថ្មចាប់ផ្ដើមធ្វើនៅខែ២ ប៉ុន្តែយើងយកឆ្នាំសិន ប្រហែលជា៧៧ ។

ដានី ៖ ៧៧ ខែ២ ។

យឿក ៖ តែគេប្រជុំមុនប្រហែលមួយខែ ហួស២ខែ ប៉ុន្តែគំរោងគេតាំងពីប៉ុន្មានខែមុនឯណោះគេទៅមើលដូចភូមិភាគអីតំបន់ទៅមើលថាគេត្រូវធ្វើត្រង់ណាៗអីណាសរួចបានគេសំរេចថាធ្វើនៅហ្នឹងអាងត្រពាំងថ្មហ្នឹងទៅរើសគណៈកម្មការវាស់វែងទាំងអស់ ។

ដានី ៖ បាទលោកពូពេលភូមិភាគដែលមកប្រជុំហ្នឹងឈ្មោះអីគេខ្លះ?

យឿក ៖ តាញឹម ។

ដានី ៖ តាញឹម ។ ចុះខាងពីភ្នំពេញខាងមជ្ឈឹមបក្សអីមានមកដែរអត់?

យឿក ៖ មកតែមិនបានស្គាល់ទេ ។

ដានី ៖ គេមកដែរ?

យឿក ៖ មក ។

ដានី ៖ ចឹងគំរោងធ្វើទំនប់ហ្នឹងគំរោងមកពីខាងមជ្ឈឹមបក្សដែរ មកពីខាងភ្នំពេញដែរ?

យឿក ៖ បាទមកដែរ ប៉ុន្តែបានន័យថាដូចអូនឯងនៅសាលាក្រហម ខ្ញុំថាឲ្យរកមើលភូមិសាស្ត្រណាដែលត្រូវហើយសំខាន់គឺអាផ្លូវបុរាណហ្នឹងធ្វើអាងនៅជាប់ហ្នឹងដើម្បីបានអាផ្លូវហ្នឹងទៅអង្គរវត្ត ។ ដល់នេះទៅអ្នកនៅខាងតំបន់៥ គេចាប់ផ្ដើមរាវរកហើយដល់វាវរកឃើញទៅបានគេចាប់ផ្ដើម ។

ដានី ៖ ពូខ្ញុំចង់បញ្ជាក់តិចទៀតអាកន្លែងប្រជុំណាស ចឹងពូថាអ្នកមកពីខាងមជ្ឈឹមបក្ស ខាងភ្នំពេញហ្នឹងពូអត់ស្គាល់ទេហ្អី?

យឿក ៖ អត់ទេ ។

ដានី ៖ ប៉ុន្តែមានមកដែរអត់?

យឿក ៖ មក ។

ដានី ៖ បាទហើយតា ញឹម គាត់ប្រជុំដែរ?

យឿក ៖ ប្រជុំ ។

ដានី ៖ តា ញឹមគាត់តួនាទីអីដែរ?

យឿក ៖ គាត់ប្រធានភូមិភាគ?

ដានី ៖ ភូមិភាគណា?

យឿក ៖ ពាយ័ព្យ ។

ដានី ៖ បាទ! ហើយពីណាទៀត?

យឿក ៖ ទេ ខ្ញុំស្គាល់តែតា ញឹមមួយទេ ។

ដានី ៖ បាទ!កាលនោះមានមកប្រជុំមានមកពីមជ្ឈិមហើយមានពីណា?

យឿក ៖ តំបន់!

ដានី ៖ តំបន់ ពីណាគេតំបន់?

យឿក ៖ តំបន់តា ហ៊ឹងនេះឯង ។

ដានី ៖ តា ហ៊ឹង

យឿក ៖ គណៈស្រុកទាំងអស់ ។

ដានី ៖ គណៈស្រុកទាំងអស់?

យឿក ៖ បាទ!

ដានី ៖ ហើយចល័តទៀត?

យឿក ៖ ប្រធានចល័ត ។

ដានី ៖ អ្នកណាគេប្រធានចល័ត?

យឿក ៖ តាវ៉ាល់ ។

ដានី ៖ តាវ៉ាល់ ។ កាលនោះគេមកប្រជុំនៅឯណា?

យឿក ៖ កាលនោះទី១គេប្រជុំ នៅស្វាយហើយទី២ទៅប្រជុំនៅត្រពាំងថ្ម ។

ដានី ៖ ពូបានចូលរួមប្រជុំដែរអត់?

យឿក ៖ អត់ទេ ។

ដានី ៖ ចុះម៉េចពូដឹងដូចពូបានរៀបរាប់មានមកពីមជ្ឈិមមានមកពីភូមិភាគ?

យឿក ៖ ហ្អស យើងម៉េចមិនដឹងបើគេប្រាប់ថាស្អែកទៅប្រជុំមកតាំងពីមជ្ឈិម ស្រុក តំបន់ភូមិភាគ អីណាស!

ដានី ៖ បាទ!

យឿក ៖ ថាវាត្រូវកំលាំងប៉ុន្មាន ប្រវែងប៉ុន្មាន កំពស់ប៉ុន្មានម៉ែត្រ ។ បើតាមខ្ញុំគិតវាបាត៦០គំរោងគេនោះណាស!

ដានី ៖ បាទ!

យឿក ៖ បាត៦០ខ្នង២០ កំពស់១២ម៉ែត្រឯណោះ ។

ដានី ៖ កំពស់១២ម៉ែត្រ?

យឿក ៖ បាទ!អានេះនិយាយពីគោលបំណងវាណាស ដល់ធ្វើដូចអត់បានចប់ទេ ។

ដានី ៖ ចឹងគោលដៅគោលបំណងហ្នឹងមានបួនមានអីត្រឹមត្រូវដែរអត់?

យឿក ៖ មាន បួនគេតាំងពីនេះទៅមានប្រឡាយធ្លាក់ទៅស៊ីងក្រឡាញ់ មានស្គាល់អាស្ពានីយបូមទឹកគេមួយទេ? នៅចារលើណាស អាផ្លូវគេចូលទៅក្នុងស្រុកចឹងដល់រំចេកមានផ្លូវមួយធំទៅកើត អានោះគេលើយកកាត់ស៊ីងមួយទៀត កាត់ស៊ីងស្វាច់ អាស្វាច់ពរចារយើងនោះមិនកាត់ស៊ីង គឺអានេះបើអាងមិនអាចស្រោចស្របគ្រប់ទេ គេបូមយកពីស៊ីងក្រឡាញ់មកទៀតអាងប៉ុនណាណី ។

ដានី ៖ ចុះលោកពូថាបួនចឹងលោកពូបានឃើញមើលបួនហ្នឹងដែរអត់?

យឿក ៖ បួនបើតាមការពិតមិនបានមើលទេ ។

ដានី ៖ អត់បានមើលទេ?

យឿក ៖ បាទ!យើងដឹងតែចាត់ចែងកំលាំងព្រោះបួនគេមានតែខាងស្រុកខាងតំបន់គេណាស ។

ដានី ៖ ចុះពូម៉េចដឹងថាមិញបាតក្រោម៦០ខ្នង២០?

យឿក ៖ ហ្អស!អានោះគេមកប្រជុំខាងក្រោមដែរគ្រាប់តែគេអ្នកគ្រប់គ្រងដូចតាវ៉ាល់ចឹងគាត់មកប្រជុំព្រោះបាតប៉ុណ្ណោះ កំពស់ប៉ុណ្ណោះ ។

ដានី ៖ ចុះបណ្ដោយ?

យឿក ៖ បណ្ដោយយើងគិតពីស្ពានទី១មកខាងលិចចេះវា៩គីឡូ ហើយអាលើសពីនោះគេអត់ទាន់ពូនិយាយ ។

ដានី ៖ ចឹងអាបួនហ្នឹងពូអត់បានឃើញជាក្រដាសជាអីទេ?

យឿក ៖ អត់ឃើញទេ ។

ដានី ៖ តែអាហ្នឹងពូតាមតា វ៉ាល់មកប្រជុំ?

យឿក ៖ បាទ!គេប្រជុំណាស១!

ដានី ៖ ចុះពូដែលគេលើកគំរោងដំបូងគោលបំណងគេចង់ដើម្បីអី?

យឿក ៖ បើខ្ញុំគិតឲ្យដល់ទៅគឺគំរោងរបស់គេទី២សំខាន់គឺទប់ទឹកដើម្បីធ្វើស្រែប្រាំងរាប់ពាន់ហិតតាតែម្ដង ។

ដានី ៖ រាប់ពាន់ហិចតាស្រុកណាខ្លះ?

យឿក ៖ ស្រុកភ្នំស្រុក ព្រះនេត្រព្រះមានពីរស្រុក ពីព្រោះអាព្រែកជីកដែលយើងបរឡានទៅភ្នំស្រុកនេះរហូតឆ្ងាយទៅក្រោមទៀតធ្លាក់ស្ទឹងកំបោរ ។ តពីស្ទឹងកំបោរមកអាទំនប់នោះវាទៅនោះទៀត ខ្ញុំគាត់ខ្មែរថាទឹកនោះបើសិនណាធ្វើឲ្យស្រួលបួលទឹកនេះពេញណាពេញណី ពីព្រោះអាព្រែកជីកខាងកើតភ្នំលាបវាឆ្ងាយទៅទន្លេឯណោះដល់នេះទឹកខែវស្សាវាហូរអាតាមនេះដូចស្ទឹង ។

ដានី ៖ ចឹងលោកពូគោលបំណងយើងទី១ទប់ទឹកធ្វើស្រែប្រាំង? ចុះទី២?

យឿក ៖ ទី២នោះគេចង់និយាយថាផលប្រយោជន៍បានន័យថាត្រី សត្វអីៗវាអាចជ្រកនៅក្នុងអាងនោះណាស ។ មានដូចជាសត្វព្រៃ សត្វស្វាបអីបើខែប្រាំងគោអីផ្ទើល វាជីវក បើនិយាយទៅសត្វហ្នឹងណាសវាមានជីវក ។ ត្រីថ្នាក់ត្រីក្រោយមកមានច្រើនមាន២១គីឡូ...

ដានី ៖ តែលោកពូពេលយើងមកប្រជុំដូចខាងតាវ៉ាល់ ខាងភូមិភាគអីមកប្រជុំពូដែលបានចូលរួមពូមានដែលឮគាត់និយាយថាគំរោងដែលយើងធ្វើក្នុងការធ្វើអាងទឹកត្រពាំងថ្មហ្នឹងដើម្បីគោលបំណងអីទី១យ៉ាងម៉េច ទី២យ៉ាងម៉េច ទី៣យ៉ាងម៉េចមានដែលឮអត់?

យឿក ៖ គេមកប្រជុំប្រាប់យើងដែរថាបញ្ហាទឹកនេះសំរាប់ស្រោចស្រពស្រែប្រាំងទាំងប្រជាជនទាំងប៉ុន្មានពីរស្រុកនោះ ហេតុនេះគេចង់និយាយថាថ្ងៃអនាគតគេគិតតែពីរឿងកសិកម្មដើម្បីយកស្រូវទៅដោះដូរគ្រឿងម៉ាស៊ីនអីអានេះគេចង់និយាយចឹងណាស ឲ្យវាកើនខ្លាំងមែនទែនណាសព្រោះគេចង់ឲ្យបានបីដងស្រែនោះ ។

ដារ៉ា៖ លោកពូខ្ញុំចង់សួរមួយទាក់ទងនឹងគំរោងដែលគេចុះមកផ្សព្វផ្សាយថាខ្នងទំនប់នេះ២០ម៉ែត្រចឹងហ្អីលោកពូ?

យឿក ៖ បាទ!

ដារ៉ា ៖ ហើយប្រវែង៦០ហើយកំពស់១២ម៉ែត្រ?

យឿក ៖ ១២ម៉ែត្រ ។

ដារ៉ា៖ ចុះដល់ពេលហ្នឹងមានដឹងទេថាគំរោងនោះត្រូវការមនុស្សប៉ុន្មាននាក់ទៅលើកសំរេចហើយរយៈពេលប៉ុន្មាន?

យឿក ៖ បាទ!តាមពិតចល័តមួយស្រុកបួនពាន់ក្នុងម៉ាស្រុកគេយក បួនពាន់ហើយរួមទាំងចល័តតំបន់ប្រាំបុិលពាន់ទៀត អាហ្នឹងលើកទី១ទេណាស!

ដានី ៖ បាទ!ស្រុកបួនពាន់ហើយតំបន់ ប្រាំបុិលពាន់? ដើម្បីលើកសំរេចផែនការរយៈពេលប៉ុន្មាន?

យឿក ៖ កាលនោះគេចង់និយាយថាបីខែឲ្យហើយ ប៉ុន្តែវាមិនបានហើយដោយសាររដូវភ្លៀង ចូលដល់រដូវភ្លៀង ។ អានេះទី១ទេណាស ទី១តាវ៉ាល់ តាវ៉ាល់ តាហ៊ីងគណៈតំបន់ធ្វើណាស ។ ដល់ទី២គេចាប់ពួកនោះអស់បានខាងភូមិភាគនិរតីមកធ្វើក្រោយទៀត ។

ដានី ៖ បាទ!ខ្ញុំចង់បញ្ជាក់ពូឲ្យច្បាស់ទាក់ទងពីគំរោងសិន ។

យឿក ៖ បាទ!

ដានី ៖ លោកពូគំរោងហ្នឹងអាពេលដែលប្រជុំមកជាមួយថ្នាក់ក្រោមហ្នឹងខាងភូមិភាគឬខាងមជ្ឈិមដែលចុះមកនិយាយពីរឿងគំរោងហ្នឹង?

យឿក ៖ បើនិយាយទៅខាងលើគេធ្វើការរួចស្រេចបានបន្តបន្ទាប់មកយកមកប្រជុំផ្សព្វផ្សាយណាស អានេះគេចង់និយាយថាបើប្រជុំនៅស្រុកចេះវាមានវរៈសេណាធំអីទៅប្រជុំដល់មកវិញយើងត្រូវប្រាប់ ប្រជុំបើកប្រជុំនៅតាមនេះទាំងអស់ ។

ដានី ៖ បាទ!

យឿក ៖ ព្រោះគេត្រូវប្តេជ្ញាថាប៉ុន្មានខែឲ្យចប់ចឹងទៅ ។

ដានី ៖ ចុះលោកពូពីណាគេអ្នកមកប្រជុំផ្សព្វផ្សាយដល់ក្រុមលោកពូ?

យឿក ៖ ដែរ បើនិយាយរួមតាវ៉ាល់ បានពួកខ្ញុំយកទៅប្រជុំតទៀត ។

ដានី ៖ បាទ!កាលតាវ៉ាល់គាត់មកប្រជុំប្រាប់លោកពូគាត់ថាម៉េចខ្លះទៅបើតាមពូចាំ?

យឿក ៖ តាវ៉ាល់មកប្រជុំគេនិយាយរឿងផែនការតែម្តងលែងនិយាយរឿងគំរោងហើយ គេនិយាយថាផែនការថាមុខសញ្ញារបស់ចល័តផ្ទាល់នោះមានប្រវែងប៉ុនណេះម៉ែត្រប៉ុនណេះគីឡូហេតុនេះគឺត្រូវយកទៅចែកតាមកងតាមវរៈទៀត ។ ឧបមាថាបីគីឡូនេះក្នុងចល័តតំបន់មានប៉ុន្មានទៀតដូចថាមានប្រាំប៉ុលពាន់ គេយកទៅអង្គន់ចែកគ្នារួចបានគេយកទៅគុណរកតាមកងហ្នឹងឧបមាថាម្នាក់កន្លះម៉ែត្រកងប្អូនឯងមាន៣០នាក់៣០គុណនឹងកន្លះម៉ែត្រវាស់ឲ្យត្រឹមត្រូវគណៈកម្មការគេវាស់ឲ្យ ។ ហេតុនេះគេចង់និយាយថាចែកគ្នាដាច់ៗអត់មាន... បើមិនរួចត្រូវប្រជុំគ្នារកពិសោធ ដូចកងប្អូនឯងរួចមុនចឹងយ៉ាងម៉េចបានរួចមុនគេកងខ្ញុំយ៉ាងម៉េចបានមិនរួច អានេះបើនិយាយទៅប្រៀបដូចអង្គការគេចុះមកអភិវឌ្ឍចឹងណាសគេចង់និយាយថាថ្ងល់នេះប៉ុន្មានខែប៉ុន្មានថ្ងៃបានរួចដូចតែគ្នាចឹង ។

ដានី ៖ លោកពូដូចលោកពូមានប្រសាសន៍ពីដំបូងថាដំបូងបំផុតគេចាប់ផ្តើមវាស់វែងដូចថាគេតំរង់ណាស គេតំរង់ពីកន្លែងណាទៅកន្លែងណាហើយអ្នកណាគេអ្នកតំរង់?

យឿក ៖ តំរង់មានគណៈកម្មការគេខ្ញុំស្គាល់តែ គាខូវទេ ។ តំរង់ហ្នឹងជិតបីខែមុនណោះប៉ះព្រៃកាប់ព្រៃ តំរង់ព្រិញតែម៉ង់សឹងតែ១០គីឡូម៉ែត្រក៏មើលឃើញដែរ ។

ដានី ៖ តំរង់ពីត្រឹមណាទៅត្រឹមណា?

យឿក ៖ តំរង់ពីមួយផ្លូវផ្លូវបូរាណគេពីដូនទយទៅទល់នឹងអន្លុវវត្ត ។

ដានី ៖ ហ្អាក!យើងធ្វើទំនប់ត្រពាំងថ្មនៅនេះម៉េចក៏តំរង់ទៅដល់ខាងព្រំដែនណោះ ពីដូនទយមិនព្រំដែនថៃហ្អី?

យឿក ៖ ព្រំដែនថៃតែពីផ្លូវបុរាណចាប់ពីនេះទៅដល់អន្លុវវត្តណាស ហេតុនេះអាអាងត្រពាំងថ្មត្រូវផ្អែកលើថ្នល់នោះហេតុនេះគេត្រូវកាត់ យល់ទេ?

ដានី ៖ នៅលើថ្នល់បុរាណនេះ?

យឿក ៖ បាទ!ហេតុនេះគេត្រូវកាត់ ប៉ុន្តែអាថ្នល់បុរាណនេះគេត្រូវឆ្ការឲ្យត្រង់ព្រិញហើយអាអាងហ្នឹងគេចាប់ធ្វើ ។

ដានី ៖ បាទ!គេតំរង់ពីដូនទយមកកាត់តាមអាងត្រពាំងថ្មនេះហើយបានទៅអន្លុវវត្តទៀត?

យឿក ៖ បាទ!ទៅស្ពានស្រែងដាច់ទៅអន្លុវវត្តបណ្តោយ ។

ដានី ៖ មូលហេតុអីបានជាយើងធ្វើនៅត្រពាំងថ្មទេតែទៅវាស់ពីដូនទយព្រំដែនថៃហើយកាត់ពីដូនទយទៅអន្លុវវត្តទៀត?

យឿក ៖ អានេះបើតាមយើងដឹងគេយកតាមផ្លូវចាស់ដើម្បីប្រើប្រាស់តែធ្វើវាមិនបាន ។ធំណាស់ណាបើឃើញគេធ្វើអាផ្លូវទៅចុងកាល់នេះយើងទៅដល់កំបោរឃើញហើយទាំងទ្វារទឹកអីធំល្មឹង ។

ដានី ៖ ហ្អស!ខ្ញុំយល់ហើយ ចឹងបានន័យថាគេចង់ធ្វើថ្នល់ពីដូនទយនឹងកាត់លើខ្នងទំនប់ហ្នឹងជាផ្លូវដែរ ហើយយើងធ្វើថ្នល់ចាក់ទៅអន្លុវវត្ត?

យឿក ៖ បាទ បាទ!ហើយអាថ្នល់លើខ្នងទំនប់នោះជាថ្នល់បុរាណចាស់ បើគនិយាយឲ្យខ្វីទៅអាថ្នល់បុរាណចាស់ហ្នឹងមានស្ពាន មានថ្មធ្វើពីថ្មធ្វើពីអីតែគេរំលាយចោលអស់ហើយគេទាញចោលដាក់នឹងដីអស់ហើយ ។

ដានី ៖ បាទ!អាហ្នឹងពេលគេវាស់អីហ្នឹងបីខែមុនពេលចាប់ផ្តើមធ្វើ?

យឿក ៖ បីខែ ។

ដានី ៖ បីខែ?

យឿក ៖ បាទ!

ដានី ៖ មានអ្នកដែលគណៈកម្មការវាស់មានគាខូវ ចុះពូឈួងមានចូលរួមដែរទេ?

យឿក :	ហ្អស!តាឈួន កាលនោះតាឈួនដែរ ។

ដានី :	តាឈួន កាលនោះគាត់មានតួនាទីគាត់អីដែរ?

យឿក :	គាត់ខាងវាស់វែងហ្នឹងឯងកាលនោះតាឈួន ។

ដានី :	គាត់អត់មានឈ្មោះចូលទៅក្នុងគណៈកម្មការនឹងគេទេ?

យឿក :	អត់ តាឈួនគាត់អត់បានចូលបែបមានឈ្មោះនៅខាងវាស់វែងហើយកាលនោះខ្ញុំក្មេចទៅព្រោះអត់សូវបានជួបមុខគ្នាមុខសញ្ញាវាទៅផ្សេង ឆ្ងាយគ្នាដែរនោះអាខ្លះទៅៗដល់កូនខ្វែងមានដឹងរឿងអាអ្នកនៅនេះអី ។

ដានី :	ចឹងយើងវាស់វែងហ្នឹងវាស់វែងបានរយៈពេលបីខែបានៗសង់?

យឿក :	បាទ!

ដានី :	ចុះចាប់ផ្តើមសង់ពូមានប្រសាសថានៅខែប៉ុន្មានឆ្នាំ៧៧?

យឿក :	ខែ២ ពីព្រោះច្រូតហើយគេប្រមូលកំលាំងទៅបណ្តោយ បានន័យថាច្រូតរួចវាមិនខែ២យើងនិយាយថាខែ២ចឹងទៅ ។

ដានី :	បាទ!ចឹងខែ២យើងចាប់ផ្តើមទំនប់ត្រពាំងថ្មហ្នឹង?

យឿក :	បាទ!

ដានី :	ចឹងក្នុងហ្នឹងអ្នកដែលទទួលគ្រប់គ្រងតែម្តងពីណាគេ?

យឿក :	បើគ្រប់គ្រងរួម តាវ៉ាល់ ប៉ុន្តែក្នុងនោះគេចែកតាមស្រុកទៀតដូចថាចល័តនៅស្រុកសេរីសោភ័ណ្ឌគឺក្នុងស្រុកនោះឲ្យទៅអ្នកណាដែលចុះទៅជាប់ហើយក្នុងប្រវែងប៉ុន្មានកាត់កង់ចែកគ្នាស្រេចអត់មានទាក់ទាមគ្នាអីទេ ។

ដានី :	ចឹង តាវ៉ាល់ គាត់គ្រប់គ្រងរួម?

យឿក :	គ្រប់គ្រងរួមផងមាន តាវ៉ាល់ គេចង់និយាយចេះ តំបន់គាត់រួមប៉ុន្តែគាត់មានជំនួយការដូចស្រុកទាំងអស់ជាជំនួយការក្នុងការលើកអាងទាំងអស់ហ្នឹងណាស ។

ដានី :	បាទ!

យឿក :	មិនមែនថា តាវ៉ាល់ ដាច់អត់ទេគឺត្រូវពិភាក្សាគ្នាថាត្រូវធ្វើយ៉ាងម៉េចៗ ។

ដានី :	ស្រុកជាជំនួយបស់គាត់ ចឹង តាវ៉ាល់ គាត់ខាងគ្រប់គ្រង?

យឿក :	បាទ!ចល័តតំបន់គាត់អ្នកគ្រប់គ្រង ។

ដានី :	ចុះអ្នកបន្ទាប់ៗគាត់ទៀត?

យឿក ៖ អត់ ជំនាន់នោះមានតែគាត់ហើយមានគណៈកម្មការដែលខ្ញុំប្រាប់ហ្នឹង ៧រូបហ្នឹងមាននារីមានយុវជន ។

ដានី ៖ ចុះលោកពូកាលនោះមាននាទីអីដែរ?

យឿក ៖ ខ្ញុំចុះជាប់ដែរ ជាប់គណៈកម្មការគេដែរតែខបមាថានារីនោះមួយ ខ្ញុំមួយមាននារី៣០០ ខ្ញុំនេះយុវជន៦០០ពីរនាក់ចឹងពីត្រឹមណាទៅត្រឹមណាធ្វើទៅ ។

ដារ៉ា ៖ បើកំលាំងរបស់លោកពូតែម្តងលើកដំបូងពីចំនុចណាទៅ?

យឿក ៖ ដំបូងខ្ញុំទៅនៅលើកទំនប់ស្ពាច់ ស្ពាច់ពរចារអាផ្លូវយើងទៅភ្នំស្រុកចេះទៅដល់កណ្តាលវាលចេះវាមិនមានភូមិរំចេកវាមានផ្លូវទៅចេះទៅលើកកាត់ស្ទឹងតែម្តង ។

ដារ៉ា ៖ អាហ្នឹងជាផ្នែកនៃត្រពាំងថ្មហ្អី?

យឿក ៖ បាទ!អានោះវាខ្សែទាក់ទងមកពីនោះតែគេលើកដើម្បីយកប្រឡាយទ្វារទឹក អានោះទ្វារទឹកធំណាស់ដូចគ្នាពីព្រោះទឹកមកពីនោះដែរ ដល់ក្រោយមកបានអាងត្រពាំងថ្ម ។ អាងត្រពាំងថ្មនោះចាំមើលខ្ញុំនិយាយ ពេលរដូវវស្សាចល័តវាត្រូវបែកគ្នាហើយណាស មិនមែនបែកទៅផ្ទះទេណាសគ្រាន់តែមុខសញ្ញាខ្ញុំនេះបែកទៅខាងស្ពាច់ទៅ មុខសញ្ញាប្អូនឯងនេះទៅនៅធ្វើបង្គីរអាបង្គីរលើកដីហ្នឹងណាស បង្គីរឡានដឹករាប់ពាន់ រាប់ម៉ឺន ។

ដានី ៖ អត់ទេលោកពូខ្ញុំចង់ដឹងពីអាងត្រពាំងថ្មសិន ត្រពាំងថ្មហ្នឹងចាប់ផ្តើមដំបូងមុខព្រួញរបស់លោកពូដែលថាក្នុងគណៈកម្មការ៧នាក់ហ្នឹងលោកពូត្រូវបានគេបែងចែកឲ្យនៅចន្លោះណា?

យឿក ៖ ខ្ញុំអាងត្រពាំងថ្មខ្ញុំអត់បានទទួលមុខនាទីអីទេ ពីព្រោះខ្ញុំគេដកមុន ព្រោះខបមាថាមុននឹងរៀបចល័តត្រពាំងថ្មគេត្រូវរៀបចល័តតំបន់ ដល់យើងវាមិនទាន់បាននេះគេដកចេញទៅ ដកខ្ញុំចេញ ។

ដានី ៖ ដកទៅណា?

យឿក ៖ ដកវែកដីលេខ១ ។

ដានី ៖ កាលនោះក្រែងពូអត់មានកាន់ខាងសេដ្ឋកិច្ចទេ?

យឿក ៖ ខ្ញុំចាំមើលណា គេដកខ្ញុំទៅវាអត់មានកងមានក្រុមអីទេម្ល៉ោះហើយដូចប្អូនឯងធ្វើសេដ្ឋកិច្ចមិនស្គាល់ខ្ញុំចឹងក៏ហៅខ្ញុំទៅហូបបានយ ខ្ញុំក៏ហូបទៅដល់ហូបយូរៗទៅអ្នកដែលកាន់សេដ្ឋកិច្ចហ្នឹងអត់ចេះអក្សរទេ ប៉ុន្តែប្រវត្តិតស៊ូគេពី៧០ណាមកជាមួយ គាញឹម ភូមិភាគហ្នឹងណាសម្ល៉ោះហើយសូម្បីតែយោធាក៏មិនហ៊ាននឹងគាត់ដែរ ម្ល៉ោះហើយខ្ញុំក៏អែបៗនឹងគាត់ទៅហាក!កត់មើលកងនេះប៉ុន្មានអីប៉ុន្មានចុះយើងចេះអក្សរខ្លះជួយទៅស៊ីបាយស៊ីទឹកហ្នឹងទៅ

អត់មាននេះទេ ។ ដល់ក្រោយមកបាន តាវ៉ាល់ នេះឲ្យខ្ញុំចាំងស្មៀតចបអាស្មៀតយើងចប យើងកាប់ដីនោះណាស អូនឯងសណ្ដក នាងនេះសណ្ដកយកមកខ្ញុំអ្នកវៃអ្នកនេះស្រាប់ អត់មានពិបាកអីទេ ។

ដានី : ចឹងលោកពូពេលធ្វើទំនប់ត្រពាំងថ្មលោកពូអត់បានចូលរួមទេ?

យឿក : ខ្ញុំមិនបានដាកងជាក្រុមអីទេព្រោះគេដកខ្ញុំមុន ។

ដានី : ចឹងលោកពូដកពីកាល?

យឿក : ខ្ញុំដកមុន បើនិយាយរួមទៅគេចង់និយាយថាប្រហែលជាចុងឆ្នាំ៧៦ ។

ដានី : ចុងឆ្នាំ៧៦ហ្នឹងគេដកចេញ?

យឿក : បាទ!ដកច្រើនណាស់មិនមែនដកតែខ្ញុំទេ ។

ដានី : ដកពីណាខ្លះ?

យឿក : ដកបីបួននាក់ នារីក៏គេដកដែរ ។

ដានី : បាទ! លោកពូអាចជួយរៀបរាប់ឈ្មោះកបានទេ?

យឿក : ឈ្មោះចាន់ មួយក៏គេដកដែរ អានោះគេឲ្យទៅនៅពុសខសនៅមន្ទីរពេទ្យ ។

ដានី : មន្ទីរពេទ្យណា?

យឿក : នៅអន្លង់សារ ឃុំភ្នំលាប ។

ដានី : មន្ទីរពេទ្យតំបន់ហ្អី? ចល័តតំបន់ហ្អី?

យឿក : បាទចល័តតំបន់ ។

ដានី : មន្ទីរពេទ្យរបស់ចល័តតំបន់នៅអន្លង់សា?

យឿក : បាទ!ខ្ញុំពីរនាក់នារីរួម នោះខាងដីលេខ១ ។

ដានី : ពីរនាក់ពូនឹង នារីរួម គេឲ្យទៅខាង...

យឿក : ដីលេខ១ ។

ដានី : ដីលេខ១នៅឯណាទៅ?

យឿក : ដើរប្រមូលតាមចល័តទៅណាស អាណាជុះដាក់ត្រង់ណាត្រង់ណីយើងដើរប្រមូលដាក់ រណ្ដៅទៅណាស ។

ដានី : ចុះកាលនោះមូលហេតុអីគេដកដូចលោកពូបានរៀបរាប់?

យឿក : វាពិបាកណាស់អូន ពីព្រោះអីអ៊ីៗដែលយើងខុសមើលវាមិនឃើញ ហើយម្យ៉ាងទៀត ជំនាន់នោះជួនកាលក្នុងជួរគណៈកម្មការជួនកាលគេនឹកឃើញថាវាយការណ៍ទៅលើអ្នកណា

ម្នាក់ព្រោះបើទុកខ្លាចយើងវាធំជាងគេអីចឹងទៅណាស មិនដឹងយ៉ាងម៉េចដែរទេ ដល់គេហៅទៅប្រជុំរួមធំណាស់ ចល័តតំបន់គេប្រកាសតែម្តង តែគេប្រកាសនោះក៏មិនមែនធំដុំអីដែរ គេនិយាយថាមិត្តទៅទទួលខាងដីលេខ១ មិត្តនោះទៅទទួលខុសត្រូវខាងខសខាងអ្វីសេដ្ឋកិច្ចនៅពេទ្យ មួយនោះគេដកឲ្យទៅខាងទន្លេសាបធ្វើត្រី ធ្វើអី ។

ដានី ៖ អ្នកណាគេដកទៅខាងទន្លេសាប?

យឿក ៖ កាលនោះ ថាវ ឈ្មោះថាវ ។

ដានី ៖ ចុះអ្នកណាគេអ្នកប្រកាសហ្នឹងដូចពូទៅខាងដីលេខ១ អ្នកណាអ្នកប្រកាស?

យឿក ៖ តាវ៉ាល់ ។

ដានី ៖ តាវ៉ាល់ ។

យឿក ៖ បែកគ្នាអស់ទៅ ។

ដានី ៖ បាទ!ចុះពូម៉េចពេលគេធ្វើទំនប់ពូមកចាំងចបអីវិញ?

យឿក ៖ ទេ ដល់គេដកហ្នឹងមិនមែនដកចេញពីចល័តទេណាគ្រាន់តែដកមុខនាទីយើង ក្នុងចល័តហ្នឹងគេអាចប្រើឲ្យយើងទៅរកត្រីក៏បានធ្វើអីក៏បានស្រេចតែគេ ដល់មើលទៅវាស្ទះកងខ្លះទៅគេថារែកមិនបានហើយ២ម៉ែត្រគីបនេះដោយសារចបវសណ្តកវាអីរវល់តែទៅចាំង ទៅវៃដល់ហើយឲ្យខ្ញុំទទួលខុសត្រូវខាងស្នៀតចបបណ្តោយ ។

ដានី ៖ ចឹងពេលដំបូងបំផុតពូមានដឹងថាដូចថាក្នុងអ្នករែកដីហ្នឹងគេមានដាក់ផែនការថាម្នាក់រែកមួយថ្ងៃប៉ុន្មានហូបចុកអីប៉ុន្មានពូដឹងទេ?

យឿក ៖ រែកគឺម្នាក់២ម៉ែត្រគីប ។

ដានី ៖ ម្នាក់២ម៉ែត្រគីប?

យឿក ៖ បាទ!ហើយហូបចុកម្នាក់បាយ៣កំប៉ុង ។

ដានី ៖ មួយថ្ងៃ៣កំប៉ុង?

យឿក ៖ បាទ!

ដានី ៖ ចុះអាហ្នឹងពូដឹងតាមរយៈពីណាគេដូចថាមួយថ្ងៃ៣កំប៉ុង?

យឿក ៖ ខ្ញុំតែម្តង ក្រោយមកខ្ញុំគេឲ្យទៅទទួលសេដ្ឋកិច្ចនោះណាស បីកំប៉ុង បីកំប៉ុងបើតាមខ្ញុំគិតទៅកងមានសល់ដល់៦ ៧បាវឯណោះស៊ីមិនអស់ ម៉េចនឹងអស់បើលេងបីរាល់តែថ្ងៃ ។

ដានី ៖ ហូបអត់អស់ហ្អី? ចឹងកងមិននៅសល់ស្រូវ?

យឿក ៖ អត់អស់ ។

ដានី ៖ សល់អង្ករហ្អី?

យឿក ៖ កន្លះវាទៅសល់អង្ករ ប៉ុន្តែក្នុងនោះបានតែចល័តទេណាស បានតែកំលាំងទី១ទេណាស ។ ដល់កំលាំងទី១នោះបានតែពេលដែលប្រយុទ្ធខ្លាំងទេ ដល់ចប់ផែនការទៅសល់តែមួយកំប៉ុង កន្លះទៅកន្លះកំប៉ុង ប៉ុនយ៉ាងកំសុយក៏កន្លះកំប៉ុងដែរ ។

ដានី ៖ មួយថ្ងៃហ្អី?

យឿក ៖ បាទ!ខ្ញុំអ្នកដើរដឹកអង្ករដឹកអីឲ្យគេ អានោះចុងក្រោយគេ ។

ដានី ៖ បាទ!ចុះលោកពូជួយរៀបរាប់ដំណើរដូចលោកពូថាទៅខាងដីលេខ១ រួចហើយមកចាំង ស្មៀតរួចហើយបានមកសេដ្ឋកិច្ចវិញ?

យឿក ៖ អញ្ចេះ ខ្ញុំចង់និយាយថាពេលដែលគេចាប់ពួក តាវ៉ាល់ តាហ៊ីង គេមិនចាប់?ភូមិភាគអី មិនចាប់គេមិនដូរខាងភាគនិរតីនោះមក?ដល់មកអ្នកដែលមានមុខនាទីអីគ្មានហ៊ាននិយាយទេ គេចាប់ដែរនោះ ម្ខោះហើយម្នាក់ៗស្ងៀមៗគ្មានហ៊ាននិយាយអី ហើយខ្ញុំនេះទៅប្រមូល សំបកប៉ោត សំបកខ្ញាញ់អីមកសេដ្ឋកិច្ចគេ ប៉ុន្តែខ្ញុំអ្នកធ្វើស្ថិតិខ្ញុំដឹងព្រោះគាត់មិនចេះអក្សរ អីណា កងអូនឯង១០០ ខ្ញុំដាក់១០០ កងណា២០០ដាក់២០០ដល់នេះខ្ញុំបូក ។ កាល នោះសភាពការណ៍គេប្រែប្រួលទៅខាងនិរតីគេមិនមក តារិន គាត់មកកាន់ខាងតំបន់នៅក្នុង តំបន់៥ហ្នឹង ។ ដល់រួចទៅមកកាន់តំបន់៥នេះវារាងប្រែប្រួលអស់ វាចង់រប៉ាត់រប៉ាយ ហើយព្រោះ តាវ៉ាល់ អីគេចាប់ខ្លួនអស់ហើយ ។

ដានី ៖ ចឹងលោកពូដឹបូងគេចាប់ធ្វើទំនប់ហ្នឹងនៅខែ២ឆ្នាំ៧៧?

យឿក ៖ បាទ!

ដានី ៖ បាទ!ហើយអ្នកកាន់សេដ្ឋកិច្ចហ្នឹងមិនមែនពូទេ?

យឿក ៖ អត់ទេ!

ដានី ៖ ពីណាគេអ្នកកាន់សេដ្ឋកិច្ច?

យឿក ៖ តាពើង!

ដានី ៖ ឈ្មោះ តាពើង កាន់សេដ្ឋកិច្ច?

យឿក ៖ បាទ!ពីយោធាតំបន់ ។

ដានី ៖ អ្នកនៅខាងយោធាតំបន់?

យឿក ៖ បាទ!មុនហ្នឹងខ្ញុំមិនបានកាន់ទេ ។

ដានី ៖ បាទ!ចុះ តាវ៉ាល់ គាត់អ្នកទទួលខុសត្រូវប្រធានចល័តតំបន់៥ ចឹងអ្នកដែលជាគណៈកម្មការទាំង៧មានមកធ្វើនៅហ្នឹងដែរឬក៏អត់ទេ ៧នាក់ដែលពូរៀបរាប់តាំងពីដំបូងណាស?

យឿក ៖ អ្នកដែលគេមិនបានដកចេញគេនៅធ្វើទេតើ ។

ដានី ៖ អ្នកដែលមិនដកចេញដូចពូមានប្រសាសន៍មិញ...

យឿក ៖ អ្នកដែលគេដកចេញទៅវែកដីទៅវែកដីមានដីវែកមិនមានអាហ្នឹងស្រេចនឹងយើង ។

ដានី ៖ បាទ!ចឹងតែពូមានប្រសាសន៍មិញអ្នកដែលគេដកចេញនៅតែធ្វើការនៅចល័តដដែល?

យឿក ៖ បាទ!គ្រាន់តែដកមុខនាទី ។

ដានី ៖ ដកមុខនាទីតែពូនៅត្រពាំងថ្មដែរ?

យឿក ៖ បាទ!

ដានី ៖ ត្រពាំងថ្មហ្នឹង តែពូទទួលខាងដីលេខ១ដូចនៅតាមចល័តគេដុះអីចឹងយើងទៅកើប?

យឿក ៖ ទៅចូកយកមកដាក់នៅរណ្ដៅ ។

ដានី ៖ ដាក់នៅរណ្ដៅ? មានគ្នាប៉ុន្មាននាក់ដែលធ្វើខាងដីលេខ១ហ្នឹង?

យឿក ៖ មានពីរនាក់ ។

ដានី ៖ ពីរនាក់តែអ្នកចូកប៉ុន្មាននាក់?

យឿក ៖ អ្នកចូកហ្នឹងនៅតាមកងទេតើ ។ ឧបមាថាល្ងាចនេះខ្ញុំចុះមកកងអូនឯង សួរថាចូកដីបានប៉ុន្មាន ត្រូវធ្វើយ៉ាងម៉េច ។ អានេះខ្ញុំគ្រាន់តែដើរទទួលខុសត្រូវទេណាស មិនមែន...អើយើងចូកខ្លួនឯងខ្លះ ។

ដានី ៖ បាទ!ខ្ញុំយល់ហើយ ។ ចុះលោកពូពេលហ្នឹងអ្នកដែលធ្វើទំនប់ចាប់ពីខែ២ហើយ តាវ៉ាល់គាត់ដាក់ផែនការយ៉ាងម៉េចដំបូង ដូចដាក់មកខាងប្រធានវរៈប្រធានកងអីមិនមកទទួលផែនការពី តាវ៉ាល់?

យឿក ៖ បាទ!

ដានី ៖ ចឹងពេលប្រជុំហ្នឹង តាវ៉ាល់ គាត់ដាក់ផែនការយ៉ាងម៉េចយើងត្រូវលើកទំនប់ក្នុងម្នាក់ប៉ុន្មានហើយផែនការរយៈពេលប៉ុន្មានបានយើងធ្វើហើយទំនប់នោះ?

យឿក ៖ អានោះគំរោងគេដាក់ច្បាស់លាស់ណាស់ណា ប៉ុន្តែថាជួនកាលធ្វើទៅវាអត់បានសំរេច ។

ដានី ៖ កាលនោះគាត់ដាក់ផែនការយ៉ាងម៉េច?

យឿក ៖ ដាក់ផែនការចែកគ្នាតាមកង ត្រូវប្រវែងប៉ុន្មានទៅតាមកំលាំង អាហ្នឹងចែកទៅតាមកំលាំង បើយើងគិតទៅណាស ជួនកាលកំលាំងអូនឯងមានដល់១៣០នាក់ កំលាំងខ្ញុំមានដល់

១០០បែកទៅតាមនោះ ព្រោះចល័តតំបន់នេះចាប់ផ្ដើមមិនមែនទៅអានត្រពាំងថ្ម បណ្ដោយទេ នេះចំការកប្បាសកងវ៉ាអីសុទ្ធតែចល័តកាប់ហើយ ។ ពីមុនសុទ្ធតែព្រៃបន្ទាស្អិតណែនប៉េះ ប៉ុន្ដែកាប់ចំការនោះទទឹងមួយម៉ែត្រ បណ្ដោយមួយរយម៉ាំងឲ្យហើយ ។ ព្រៃណែនយ៉ាងម៉េចក៏ដោយទាំងដុតទាំងអីឲ្យហើយ ។

ដានី : ទៅកាប់នៅហ្នឹងទាំងអស់?

យឿក : បាទ!

ដានី : ប៉ុន្ដែខ្ញុំចង់ដឹងអាពេលទៅធ្វើត្រពាំងថ្មហ្នឹងទទួលផែនការអីគាត់មានបញ្ជាក់ច្បាស់ថាម្នាក់ត្រូវតែឲ្យរួចប៉ុន្មានម៉ែត្រគីប ហើយរបបហូបចុកប៉ុន្មាន រយៈពេលប៉ុន្មានត្រូវធ្វើឲ្យហើយអានត្រពាំងថ្មដូចពូមានប្រសាសន៍មិញថាបាតក្រោម៦០ កំពស់១២ ខ្នង២០អីហ្នឹងណាស! ចឹងគាត់ដាក់ផែនការក្នុងម្នាក់ត្រូវលើកប៉ុន្មាន ឧបមាថារយៈពេលប៉ុន្មានឲ្យហើយផែនការ?

យឿក : បើតាមនេះគេគិត ខ្ញុំមិនបានដឹងទេព្រោះខ្ញុំអត់បានទៅប្រជុំតែខ្ញុំអាចដឹងព្រោះគេត្រូវគិតពីសាច់ដីនឹងកំលាំងមនុស្សច្បាស់លាស់គេបែកគ្នា ។ អានេះបានន័យថា ឧទាហរណ៍ថាម្នាក់មុខមួយម៉ែត្រ ទទឹងមួយម៉ែត្រឡើងទៅលើចឹង ហួស!កន្លះម៉ែត្រ ប៉ុន្ដែធ្វើម៉េចឲ្យហើយបាន២ម៉ែត្រគីបព្រោះគេទូទាត់ទៅវាត្រូវម្នាក់២ម៉ែត្រគីបក្នុងប៉ុន្មានខែ ប៉ុន្មានម៉ែត្រគីបបានគ្រប់ ។

ដានី : ចឹងធ្វើទំនប់បានប៉ុន្មានខែបាន តាវ៉ាល់ អីត្រូវគេចាប់?

យឿក : ទំនប់នោះបើតាមខ្ញុំមើលប្រហែលជាបានសាមសិបភាគរយបានគេចាប់ តាវ៉ាល់ ។

ដានី : សាមសិបភាគរយ?

យឿក : បាទ!ហើយអាទំនប់មួយពីស្ពានទី៣មកទល់ស្ពានទី១នោះហើយនឹងកាច់ទៅនោះបានមួយចំនួនដែរដល់នេះទៅដល់រដូវវស្សា ។

ដានី : ដល់រដូវវស្សា?

យឿក : បាទ!

ដានី : ខែប៉ុន្មានដែលគេចាប់តាវ៉ាល់?

យឿក : ទេ ចាប់ តាវ៉ាល់មិនដឹងជាខែប៉ុន្មានទេវ៉ី!ចាប់ តាវ៉ាល់ ហើយបានគេរើសយោធានិរតីឲ្យនៅម្ដុំ តាវ៉ាល់ ចាប់ប្រហែលជិតដល់រដូវភ្លៀងខែ៦អីនេះឯង ។

ដានី : ខែ៦?

យឿក : បាទ!ប្រហែលខែ៦ ។

ដានី ៖ ខែ៦ ៧៧ហ្នឹង?

យឿក ៖ បាទៗ

ដានី ៖ ពេលគេចាប់តាវ៉ាល់ហ្នឹងពួកនិរតីមកហើយនៅ?

យឿក ៖ មកហើយ មកមួយៗហើយ ។

ដានី ៖ មកមួយៗ?

យឿក ៖ អើវាមិនទាន់បានចុះតាមនេះដល់ក្រោយមកបានគេឲ្យចុះ អស់តាវ៉ាល់ទៅបានពួកនិរតីមក ។

ដានី ៖ បាទ!ចឹងអ្នកដែលនេះហ្នឹងមកតែពីខាងនិរតីទេអត់មានមកពីណាផ្សេងទេ?

យឿក ៖ ទេ ដំបូងមកពីបូពា មកពីបូពាគេចាប់បូពាហ្នឹងម៉ាលើកទៀត ។ និយាយទៅវាមានច្រើនគន្ទាក់ណាស់ណាស មកពីបូពាខ្ញុំភ្លេចឈ្មោះគាត់ទៅ មកទទួលរួមនៅចល័តតំបន់នេះហើយមានជំនួយការគេបាក់ឌុបបាក់អីពីសង្គមណាសគេចេះគេដឹងណាស ក្មេងដែរដល់ក្រោយមកស្រាប់តែគេសគាស់យ៉ាងម៉េចក៏ស្រាប់តែបាត់ពួកនោះអស់ ។ ទេ!ដូចជាឈ្មោះ បងទុយ បងទុយមកពីភូមិភាគគាត់ទទួលរួម អើដឹងចាប់ឬមិនចាប់បើសូន្យទៅហើយដឹងស្អី ។ ដល់ក្រោយមកទៀតបានភូមិភាគនិរតីមក មកដើងជាប់នៅហ្នឹងបណ្តោយ ។

ដានី ៖ ចឹងកាលចាប់ តាវ៉ាល់ ហ្នឹងខាងភូមិភាគណាអ្នកចាប់?

យឿក ៖ បើ តាវ៉ាល់ ប្រហែលភូមិភាគយើងនេះឯងចាប់ព្រោះចាប់ តាវ៉ាល់ រួចបានគេចាប់ភូមិភាគព្រោះគេបញ្ជាឲ្យភូមិភាគហ្នឹងចាប់ ចាប់រួចអស់អាក្រោមគេមកចាប់ តាញឹម ។

ដានី ៖ បាទ!ចឹងអ្នកដែលចាប់ តាវ៉ាល់ គឺខាងភូមិភាគពាយ័ព្យហ្នឹងទេ?

យឿក ៖ បាទ!

ដានី ៖ ពីណាអ្នកមកចាប់?

យឿក ៖ និយាយទៅគឺថាខាងសន្តិសុខនៅពាយ័ព្យមកចាប់តែម្តង ព្រោះឡានសរមកណាស ។

ដានី ៖ ឡានសហ្អី?

យឿក ៖ បាទ!តែឃើញឡានសរហើយញាក់សាច់ដែរអ្នកណាមានមុខ...

ដានី ៖ ឡានសរបៀបយ៉ាងម៉េច?

យឿក ៖ ទេ!ឡាននោះពណ៌សរវាចង់តែម៉ាកចេះដែរហ្នឹងណាស ។

ដានី ៖ ស្រដៀងអាស៊ីបនេះដែរហ្អី?

យឿក ៖ បាទ!

ដានី ៖ ចុះពូកាលនោះអ្នកដែលមកចាប់ហ្នឹងកាលនោះ ជាល អីមកហើយនៅ?

យៀក ៖ តាជាល ហ្អស?

ដានី ៖ បាទ!

យៀក ៖ តាជាល គាត់ចុះមកតាមតំបន់ដែរ តាជាល ។

ដានី ៖ គាត់ចុះមកតំបន់ណា?

យៀក ៖ តំបន់៥ ហ្នឹងខ្វាំងជាងគេហ្នង?

ដានី ៖ ខ្វាំងជាងគេ?

យៀក ៖ បាទ!

ដានី ៖ គាត់ធ្វើអី?

យៀក ៖ តាជាល នោះបើនិយាយរួមទៅនៅខាងភូមិភាគនោះឯង ប៉ុន្តែដូចកូនគាត់ គាត់មានមុខ នាទីមិនដឹងថាស្អីទេ ។

ដានី ៖ គាត់កូន តាញឹម ហ្អីតាជាល?

យៀក ៖ បាទ!កូន តាញឹម ។

ដានី ៖ គាត់នៅតំបន់៥ ហ្នឹងដែរ?

យៀក ៖ អត់មានមកនៅទេ មកម្តងៗ ។

ដានី ៖ មកម្តងៗ?

យៀក ៖ ប៉ុន្តែក៏ញាប់ដែរ ។

ដានី ៖ ប៉ុន្តែពេលចាប់ តាវ៉ាល់ ហ្នឹងជាលហ្នឹងគាត់មកចាប់ឬក៏អត់ទេ?

យៀក ៖ អត់ទេ មានទ័ពគេមកចាប់ ។ បើការពិតវាចេះ តែចាប់នោះវាទ័ពហើយ ប៉ុន្តែនយោបាយ គេនោះ តាជាល តាញឹម ហ្នឹងហើយព្រោះគេហៅទៅរៀន ។

ដានី ៖ តាជាល តាញឹម ហ្នឹងអ្នកហៅ តាវ៉ាល់ទៅ?

យៀក ៖ បាទ!

ដានី ៖ ចុះហ៊ីង?

យៀក ៖ តាហ៊ីងហ្នឹងគេចាប់ ចាប់ តាហ៊ីង មុន តាវ៉ាល់ ទៀត ។

ដានី ៖ ខែណាគេចាប់ តាហ៊ីង ខែណា?

យៀក ៖ ទេ!៧៧ហើយតែមិនដឹងជា...

ដានី ៖ ពូមានប្រសាសន៍ថាចាប់ តាវ៉ាល់ ប្រហែលខែ៦ ឆ្នាំ៧៧!

យឿក ៖ ហ្នឹងហើយប្រហែលប្រហាក់ប្រហែលគ្នាហ្នឹងហើយតែចាប់ តាហ៊ីង មុន ។

ដានី ៖ បាទ!ចាប់ តាហ៊ីង មុនប៉ុន្តែក្នុងខែតែមួយហ្នឹង?

យឿក ៖ បាទ!ក្នុងខែតែមួយ ។

ដានី ៖ គេចាប់គេប្រាប់ថាម៉េចពួមានដឹងហេតុការណ៍ហ្នឹងទេ?

យឿក ៖ គេអត់មាននិយាយអីទេ គេចង់និយាយថាពីព្រោះគេចាប់ទៅគឺថាបានន័យថាគេសើរើ ។

ដានី ៖ សើរើ?

យឿក ៖ បាទ!ពីព្រោះបើកាលណាគេទុកនឹងរើបក្សកុម្មុនីសអីយ៉ាងម៉េចខ្ញុំមិនដឹងដែរហ្នឹងណាសដឹង
តែគេចាប់យកទៅ ។

ដានី ៖ កាលហ្នឹងគេចាប់តែពីរនាក់ទេនៅក្នុងតំបន់ហ្នឹងតែ តាហ៊ីង និង តាវ៉ាល់?

យឿក ៖ តាហ៊ីង តាវ៉ាល់ ហើយតាមស្រុកនានាចាប់ទៅចង់អស់ ។

ដានី ៖ ចាប់តាមស្រុកដែរ?

យឿក ៖ បាទ!គេចាប់បណ្ដើរៗ?គណៈស្រុកណាខ្លះដែលគេចាប់?

យឿក ៖ ចាំមើលថ្មពួកក៏គណៈស្រុកគេចាប់ដែរ...

ដានី ៖ គណៈស្រុកថ្មពួកឈ្មោះអី?

យឿក ៖ ខ្ញុំមិនដឹងថាក្រោយឬមុនទេអត់បានចាំ ។

ដានី ៖ បាទ?

យឿក ៖ ថ្មពួក!ភ្នំស្រុកក៏គេចាប់ដែរ ។

ដានី ៖ ភ្នំស្រុកឈ្មោះអីទៅ?

យឿក ៖ តាហាត់ ។

ដានី ៖ ហាត់ ហ្អី ហាត់គេចាប់ដែរ?

យឿក ៖ ហាត់ តាដេង មិញហ្នឹងក៏គេចាប់ដែរ ។

ដានី ៖ តាដេង គាត់គណៈស្រុកអី?

យឿក ៖ អន្ទុ!

ដានី ៖ អន្ទុស្រុកភ្នំស្រុក?

យឿក ៖ ភ្នំស្រុក ។

ដានី ៖ បាទ!

យឿក ៖ ហើយព្រះនេត្រព្រះហ្នឹងមាន តាសំអាត...

ដានី :	តាម៉ោង!

យឿក :	តាម៉ោង ស្លាប់អស់ហើយរហូតទៅតាមឃុំទៀត ។ បើនិយាយរួមទៅគេនិយាយខ្សែណាស់

ដានី :	បាទ!

យឿក :	តែចាប់ប្អូនឯងហើយ ប្អូនឯងមិនឆ្លើយ ។

ដានី :	ចុះគណៈស្រុកថ្មពួកអត់ស្គាល់ទេពូ?

យឿក :	អត់ទេ!អត់បានស្គាល់ ។

ដានី :	ចុះគណៈស្រុកសេរីសោភ័ណ្ឌ?

យឿក :	សេរីសោភ័ណ្ឌពួក តាសុត ឈ្មោះ តាសុត ។

ដានី :	តាសុត គេចាប់ដែរ?

យឿក :	គេចាប់ ។

ដានី :	ចឹងខាងតំបន់គេចាប់ តាហ៊ីង ចុះខាងកងទ័ពអត់មានចាប់អីទេ?

យឿក :	កងទ័ពមិនដឹង មិនដឹងថាចាប់ឬអត់ ខ្ញុំដល់ទៅនៅចល័តទៅវាអត់ទាក់ខ្នាណាស ។ មើលកងទ័ពកាលមុន តាចយ ចាប់តាចយហ្នឹងបានពួក បងរាម អីមក ។ ដល់គេចាប់នោះមុនហ្នឹងចាប់ភូមិភាគនិរតីមកហើយ គេមកមុន ហើយនៅនេះចល័តតំបន់នោះគេយកមកដាក់ទទួលរួមមុនហើយ ប៉ុន្តែគេមិនទាន់ចាប់ ។ ដូចថាគេមកក្នុងល្អអីមករួមសុខរួមទុក្ខដល់ក្រោយមកស្រាប់តែបាត់ប្អូនឯងទៅវាឃើញឯណោះទៅ ។

ដានី :	ប៉ុន្តែចល័តតំបន់គេចាប់តែ តាវ៉ាល់ម្នាក់ទេ?

យឿក :	បាទ!ចាប់តែ តាវ៉ាល់ ។

ដានី :	អ្នកផ្សេងៗទៀតគេមានចាប់ដែរ?

យឿក :	ហ្អស!ចាប់តាមកងដែរតែខ្ញុំចាំមិនអស់ ។

ដានី :	បាទ ចាប់តាមកងដែរ!

យឿក :	មានកងខ្លះគេចាប់ អាកងដែលសាហាវព្រៃផ្សៃអីគេចាប់តើ ពួកនិរតីមកចាប់ច្រើនណាស់ ។

ដានី :	ចុះកាលនោះពេលដែលចាប់ តាវ៉ាល់ ខែ៦ហ្នឹងគេតែងតាំងអ្នកណាជំនួស?

យឿក :	ដល់ក្រោយមកចល័តតំបន់មានឈ្មោះ បងយឿន...

ដានី :	ឈ្មោះយាន់?

យឿក :	យាន់ ហើយតាពាល់ ។

ដានី ៖ យាន់ ហើយ តាពាល់?

យឿក ៖ បាទ!តាពាល់ អ្នកណាក៏ស្គាល់គាត់ដែរ ។

ដានី ៖ តាពាល់ ហ្នឹងគាត់អ្នកនៅឯណា?

យឿក ៖ អ្នកនិរតីដែរ!

ដានី ៖ អ្នកនិរតីដែរ?

យឿក ៖ បាទ!តែតំបន់ បង់រិន ។

ដានី ៖ ដល់ពេលគេចាប់ តាហ៊ឹង ទៅគេដាក់ឈ្មោះ រិន?

យឿក ៖ បង់រិន មក ។

ដានី ៖ តារិន ហ្នឹងអ្នកនិរតីដែរ?

យឿក ៖ អ្នកនិរតី ។

ដានី ៖ ចុះខាងយោធាពីណា?

យឿក ៖ យោធានៅតំបន់៥យើង ហួស!នៅស្រុកភ្នំស្រុកមាន តាឆន ឈឿង ។

ដានី ៖ ចុះយោធាធំ?

យឿក ៖ យោធាធំនៅហ្នឹងឈ្មោះ...

ដានី ៖ ឈ្មោះរាម ហ្អី?

យឿក ៖ តារាម!

ដានី ៖ តារាម ហ្នឹងគាត់នៅកងពលតែគាត់មកតំបន់៥ហ្នឹង?

យឿក ៖ បើតាមពិតវាមិនសូវដឹងរឿងច្រើនទេព្រោះផ្នែកទ័ព ។

ដានី ៖ ចឹងនៅតាមស្រុកមានអ្នកណាមកជំនួសដូចពួមានប្រសាសមិញហ្នឹង?

យឿក ៖ តាមស្រុកខ្ញុំភ្ជាប់បានតែស្រុកព្រះនេត្រព្រះមួយ ។

ដានី ៖ ស្រុកព្រះនេត្រព្រះពីណាគេ?

យឿក ៖ ស្រុកព្រះនេត្រព្រះ យាយថែម ។

ដានី ៖ យាយថែម ហ្អី?

យឿក ៖ បាទ!ដឹបូងណាស ។

ដានី ៖ បាទ!

យឿក ៖ ដល់រយៈពេលក្រោយដែលតំបន់គេដោះដូរទៀតបាន យាយថែម ដូរតំបន់ ។

ដានី ៖ យាយថែម ឡើងតំបន់?

យឿក ៖ ក្រោយឡើងតំបន់ ឡើងតំបន់ហើយបានវៀតណាមចូលបណ្ដោយ ។

ដានី ៖ ចឹង ចុះ រិនទៅណាបាន យាយថែម ឡើងតំបន់?

យឿក ៖ បងរិនគេយកទៅវិញមិនដឹងយកទៅណាប៉ិនដល់ពេលក្រោយមកខ្ញុំឃើញគាត់នៅរស់ដែរ គាត់នៅរស់ទៅតស៊ូជាមួយយវៀតណាមដល់ក្រោយមកស្លាប់ ។

ដានី ៖ ហ្អស!

យឿក ៖ ប្អូនគាត់ តារម្យនៅដល់សព្វថ្ងៃ តារម្យយើងមិនដឹងឡើងស្អីទេឥឡូវ កងពលធំទេដឹង...

ដានី ៖ ហ្អឹងប្អូន តារិន ហ្អី?

យឿក ៖ ប្អូន!

ដានី ៖ គាត់ឈ្មោះអីគេ ឈ្មោះរម្យ?

យឿក ៖ ឈ្មោះរម្យ ។

ដានី ៖ តារម្យ ហ្អឹងគាត់នៅឯណាឥឡូវ?

យឿក ៖ នៅយើងអីណាសំពៅលូន ភ្នំព្រឹក ។

ដានី ៖ នៅភ្នំព្រឹកហ្អី តារម្យ ប្រពន្ធគាត់ឈ្មោះអី?

យឿក ៖ ទេ មិនដឹងទេ តែអានេះសាច់ទ័ពទេណាស មិនដឹងឥឡូវគេប្រែប្រួលយ៉ាងម៉េចយើងអត់ដឹងទេ ។

ដានី ៖ តែរម្យ ហ្អឹងនៅភ្នំព្រឹកហ្អី?

យឿក ៖ បាទ!មុននៅភ្នំព្រឹក ។

ដានី ៖ គាត់តួនាទីអីទៅ រម្យ ហ្អឹង?

យឿក ៖ ទេប្រធានទ័ពម៉ាំម៉ាំងអស់ ។

ដានី ៖ ឥឡូវហ្អឹងហ្អី?

យឿក ៖ ទេ ពីមុននោះណាស!

ដានី ៖ បាទ!ប៉ុន្តែឥឡូវគាត់?

យឿក ៖ ឥឡូវមិនដឹងដែរ ។

ដានី ៖ ចឹងចាំមើលពេលដែលគេចាប់ តាហ៊ីង តាវ៉ាល់អីហើយ តារិនគាត់មកគណៈតំបន់ហើយ តាពាល់ ហើយ តាយាន់ ហ្អឹងគាត់នៅប្រធានចល័តតំបន់ ។ ហើយពេលហ្អឹងត្រពាំងថ្មនៅតែធ្វើចឹង?

យឿក ៖ បាទ!គេចាប់ដែនការក្រោយទៀត ។

ដានី ៖ បាទ!

យឿក ៖ គេរៀបសារក្រោយទៀតគឺគេប្រមូលចល័ត អាហ្នឹងហើយដែលខ្ញុំបើកអង្ករ ។

ដានី ៖ ហ្អស!ពេលហ្នឹងពូចាប់ផ្ដើមឡើងប្រធានសេដ្ឋកិច្ចហើយ ។

យឿក ៖ ពីព្រោះឡើងកាលនោះឡើងដោយសារជញ្ជូនប៉ោតជញ្ជូនអីទៅគណៈតំបន់ តារិន ហ្នឹងគាត់ឃើញ ឃើញគាត់ហៅខ្ញុំមកសួរ ។ ដល់សួរទៅខ្ញុំថា«គាត់ដកខ្ញុំយូរណាស់ហើយឈប់ធ្វើការអីទាំងអស់ហើយ» ដល់គាត់សួរប្រវត្តិខ្ញុំអីអស់ហើយក៏ប្រជុំស្រុកប្រជុំអី ខ្ញុំទៅប្រជុំបានគេតែងតាំងខ្ញុំឲ្យដឹកជញ្ជូនឲ្យទៅចល័តបានខ្ញុំក្ដាប់បានថាក្នុងចល័តក្រោយនេះមានបីម៉ឺនពីរពាន់ ។

ដានី ៖ ចល័តក្រោយមានបីម៉ឺនពីរពាន់?

យឿក ៖ បាទ!បីម៉ឺនពីរពាន់នាក់ ហេតុនេះមួយថ្ងៃស៊ីបីកំប៉ុង ។ តារិន គាត់ខ្លាំងដែរនិយាយពីឲ្យស៊ីគឺថាមិនបាច់ទេ!មួយថ្ងៃស៊ីបីកំប៉ុងហើយគាត់ដាក់ផែនការ និយាយពីសេដ្ឋកិច្ចសិន!

ដានី ៖ បាទ!

យឿក ៖ គាត់ដាក់ផែនការឲ្យខ្ញុំធ្វើម៉េចឲ្យមានអង្ករនៅសល់មួយពាន់បាវនៅក្នុងឃ្លាំង ។ ដល់កាលដែលគេចាត់តាំងនោះមានគ្រប់ស្រុកដែរ ។ ស្រុកក៏ដោយត្រូវតែទាក់ទងខ្ញុំតែទៅយកផ្ដេសផ្ដាសអត់បានទេ ។

ដានី ៖ ចឹងពេលហ្នឹងគេតែងតាំងពូជាប្រធានសេដ្ឋកិច្ចតំបន់៥ ?

យឿក ៖ បាទ!

ដានី ៖ តំបន់៥ តែកាលនោះទីតាំងពូនៅកន្លែងណា?

យឿក ៖ ទីតាំងធំនៅត្រពាំងថ្ម ។

ដានី ៖ ទីតាំងធំនៅត្រពាំងថ្ម?

យឿក ៖ បាទ!ដល់ពេលក្រោយទៅទៀតច្រើនណាស់ តាំងពីស្រីស្នំ តាំងពីភ្នំលាបអីណាអីណី ចុះចល័តនៅពេញនោះហើយ ។

ដានី ៖ ចឹងចាប់ពីខែប៉ុន្មានទៅដែលពូត្រូវបានគេតែងតាំងជាប្រធាន...

យឿក ៖ មើល!ចាប់ពី ប្រហែលខែ១២ ។

ដានី ៖ ខែ១២ ឆ្នាំ?

យឿក ៖ ទេ ឆ្នាំ ចុងឆ្នាំ៧៧ ។

ដានី ៖ បាទ! ចុះ តារិន នៅឯណាកាលនោះ?

យឿក ៖ តារិន នៅតំបន់ នៅស្វាយ

ដានី ៖ នៅស្វាយ!ចុះគាត់មានដែលទៅអាងត្រពាំងថ្មទេ?

យឿក ៖ ហួស ទៅញាប់ណាស់ តារិន គាត់ទៅអត់មានឈប់ទេ ។

ដានី ៖ គាត់ទៅអត់មានឈប់ទេ?

យឿក ៖ បាទ!គាត់ទៅហើយតំបន់នោះមិនមែនតែខ្ញុំទេតំបន់នោះអ្នកណាក៏ដឹងដែរ តែទៅហើយ តារិន មិនដែលនៅស្ងៀមទេតែទៅហើយគឺចាប់ដងរែក ចប បន្ដិកាប់ដីតែម្ដង ។

ដានី ៖ កាប់ដីហ្អី?

យឿក ៖ បាទ!អ្នកដែលទៅរកតំបន់រកមិនឃើញទេ ពាក់មួកស្លឹកត្នោត អាវខ្មៅដូចតែគ្នាមិនដឹងអ្នកណាតំបន់ អ្នកណាពាស្រ្តទេ តារិន ហ្នឹងមិនដែលនៅស្ងៀមទេ ។

ដានី ៖ គាត់រែកដីដែរ?

យឿក ៖ រែកដីដែរ ។

ដានី ៖ គាត់គណៈតំបន់ហើយគាត់រែកដីដែរ?

យឿក ៖ គាត់រែកដី ។

ដានី ៖ តារិន កាលនោះគាត់ចំណាស់ណា?

យឿក ៖ គាត់ប្រហែលជាសែ សែតូច ។

ដានី ៖ សែតូច?

យឿក ៖ បាទ!ពីព្រោះគាត់បានប្រពន្ធកាលនោះគាត់ប្រាប់ខ្ញុំថាអាយុ៣១ ហ្នឹងហើយសែតូច ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី?

យឿក ៖ ហ៊ឺ...ប្រពន្ធគាត់ដូចចិន ។

ដានី ៖ គាត់សំបុរសំបកយ៉ាងម៉េច តារិន?

យឿក ៖ គាត់រាងមាឌដំបង ហើយសក់រាងរួញបន្តិចហើយសំបុររាងជ្រះដែរ ។

ដានី ៖ សំបុរជ្រះ?

យឿក ៖ បាទ!ហើយសំដីគាត់សុភាពណាស់ ។

ដានី ៖ សំដីរយ៉ាងម៉េច?

យឿក ៖ សុភាព ។

ដានី ៖ ពេលគាត់ទៅត្រពាំងថ្មហ្នឹងគាត់ទៅវិលល្ងាចឬក៏សំរាកនៅទីនោះ?

យឿក ៖ ជួនកាលសំរាក ប៉ុន្តែក្នុងចំណោមគណៈតំបន់ឃើញមានតែគណៈតំបន់មួយហ្នឹងដែលគិតថា មិនដឹងថាគាត់គិតរបៀបម៉េចណាស ។ ខ្ញុំនៅខាងសេដ្ឋកិច្ចតែយើងឃើញតំបន់ទៅតិចថា បើកអង្ករឲ្យពីរកំប៉ុងអីអត់បានដាច់ខាត បើថារបបចល័តមួយកំប៉ុងគឺមួយកំប៉ុង ។ ខ្ញុំរស់នៅជាមួយគាត់យូរបានខ្ញុំថា បានខ្ញុំមើលទៅអានេះយើងចេះដឹងតិចតួច គាត់នេះដូចត្រឹម ៨ ត្រូវ ។

ដានី ៖ ត្រឹមត្រូវ ។

យឿក ៖ បើថាកាប់គោវិញ ឡើងដល់ខ្ញុំជ្រើបទាំងពោះទាំងថ្លើមគឺចិញ្រ្ចាំឲ្យអស់កុំឲ្យដូចពាក្យគេថា គោអត់ថ្លើម គោអត់ពោះ ចិញ្រ្ចាំឲ្យអស់ហើយចែកទៅតាមកងទៀត ឲ្យថ្លឹងទៀតខ្ញុំប្រាប់ ។ បើសាច់គោថ្លឹងទៅបានប៉ុន្មានក្រាមឲ្យយើងគិតគុណនឹងចំនួនកងទៀតវាត្រូវបានម្នាក់ប៉ុន្មានគីឡូ ។ សូម្បីតែសំបកបាវត្រីអីនៅក្នុងឃ្លាំងគាត់ដើរទៅជជុះខ្លាចយើងនេះលាក់ទុកសំរាប់ស៊ីតែយើង ខ្លាំងណាស់ខ្ញុំដឹងថាខ្លាំងតែម្តងបើធ្វើបានដូចគាត់នោះវាអស្ចារ្យហើយ ។

ដានី ៖ តារិន ហ្នឹងហ្អី?

យឿក ៖ បាទ!អ្នកណាក៏សសើរគាត់ដែរ ប៉ុន្តែសរសើរហ្នឹងដោយសារអី? អ៊ីដែលគេធ្វើខុសនោះយើងអត់ដឹងទេប៉ុន្តែឃើញជាក់ស្តែងដែលថាគាត់មកចេះទៅគាត់ទៅយកអង្ករអីច្រើនទៅឲ្យគាត់ៗហៅទៅស្តីឲ្យ ។

ដានី ៖ ចឹងអាកន្លែងត្រពាំងថ្មហ្នឹង តារិន គាត់ទៅកាន់ផ្ទាល់?

យឿក ៖ បាទ!គ្រប់គ្រងផ្ទាល់ តាយាន់ តាពាល់ នេះក៏នៅប្រចាំការដែរ តែគាត់ចល័តទៅចល័តមកដែរពីព្រោះតំបន់គេកាត់ពីមង្គលបុរីមកណាស តំបន់៥កាត់ពីបវិលមកចូលតំបន់៥វិញ ហើយខ្ញុំក៏នៅធ្វើសេដ្ឋកិច្ចទីនោះទៅ ។

ដានី ៖ ចុះពូ ផែនការរបស់ តារិន កាលនោះគាត់មានដែលប្រជុំមានដែលនិយាយប្រាប់ទាក់ទងនឹងទំនប់ត្រពាំងថ្មយ៉ាងម៉េចដែរទៅ?

យឿក ៖ កាលនោះនែ!ខ្ញុំដល់ទៅនៅខាងនោះមិនសូវបានទទួលផែនការដោយសារជួនកាលមួយខែគាត់មកពិនិត្យអង្ករដោយខ្លួនគាត់ម្តង ។ អង្ករចូលប៉ុន្មាន ចេញប៉ុន្មាន នៅសល់ប៉ុន្មាន ។

ដានី ៖ គាត់មកសរុបខ្លួនគាត់?

យឿក ៖ សរុបខ្លួនគាត់ ចឹងបានខ្ញុំថាអត់ដែលឃើញ ។

ដានី ៖ តែគាត់មាននិយាយទាក់ទងនឹងទំនប់ត្រពាំងថ្មអីយ៉ាងម៉េច? ខាងណាអីយើងត្រូវបញ្ចប់ហើយយើងទទួលផែនការណ៍ថ្នាក់លើអីយ៉ាងម៉េច?

យឿក ៖ ហ្អស!គាត់ទៅកន្លែងខ្ញុំគាត់និយាយដែរថាទំនប់នេះត្រូវតែធ្វើឲ្យ ហើយអាឆ្នាំដែលគាត់ទទួល នោះណាស បើមិនចប់ទេវាអាចពន្យាពេលដោយសារតែវាបន្ទាយពេលមិនបានព្រោះ វៀតណាមចូលមកទៅក៏គេចាប់គាត់មុនទៅ ។

ដានី ៖ ចុះលោកពូមានប្រសាសន៍មុនហ្នឹងថាចល័តមាន បីម៉ឺនពីរពាន់នាក់ហ្អី?

យឿក ៖ ក្រោយបីម៉ឺនពីរពាន់កាលមុនចល័តតំបន់មានប្រាំប៉ុលពាន់ តែក្នុងមួយស្រុកមានបួនពាន់ ចល័ត ដល់បួនចល័តគុណទៅវា១៦ពាន់ចល័តបូកចូលគ្នាទៅវាជាងពីរម៉ឺន ដល់មកក្រោយ បីម៉ឺនពីរពាន់ខ្ញុំកាន់ស្ថិតិហ្នឹង ។

ដានី ៖ បីម៉ឺនពីរពាន់ហ្នឹងតែកងចល័តតំបន់ឬក៏បូកជាមួយស្រុកដែរ?

យឿក ៖ ស្រុក ទាំងស្រុកទាំងអីទាំងអស់ហ្នឹងបើកអង្ករនៅម៉ាកន្លែង ។

ដានី ៖ បើកអង្ករម៉ាកន្លែង?

យឿក ៖ បាទ!ខាងស្រុកសេរីសោភ័ណ្ឌគេចាត់តាំងខាងសេដ្ឋកិច្ចមកជួបខ្ញុំកំលាំងមានប៉ុន្មានតែឲ្យ ខ្ញុំចុះទៅមើលអីវាមិនបានទេព្រោះមនុស្សសឹងតែ...បើគេឋានៈដល់ស្រុកដែរគេមិនស្មោះ ត្រង់យើងទៅដឹងអី ។

ដានី ៖ បាទ!ប៉ុន្តែបើកអង្ករក្នុង៣២០០០ហ្នឹងបើកអង្ករម្នាក់បីកំប៉ុងក្នុងមួយថ្ងៃ?

យឿក ៖ បីកំប៉ុងក្នុងមួយថ្ងៃ ។

ដានី ៖ យើងគុណតាមហ្នឹងទៅ?

យឿក ៖ គុណតាមនោះ ប៉ុន្តែជិតនាន់នោះមិនសូវបានវាល់ទេថ្ងឹងហ្នឹង ថ្ងឹងមួយរយគីឡូ៤០០កំប៉ុង តែម្តង ។

ដានី ៖ ៤០០កំប៉ុងហ្អីមួយរយគីឡូ?

យឿក ៖ បាទ!

ដារ៉ា៖ ចុះពូពេលដែលនៅអាងត្រពាំងថ្មហ្នឹងមានចល័តតំបន់ដូចពូថាមិញហ្នឹងណាស៣២០០០ហ្នឹង ចុះមានប្រជាជនតាមសហករណ៍ឬក៏ចល័តសហករណ៍ទេ?

យឿក ៖ ហ្អស!មានព្រោះគេចង់និយាយថា យកទៅសរុបទាំងអស់ បានន័យថាបើកការហូបចុកពី តំបន់ បានន័យថាគេទុកដូចជាកំលាំងរបស់តំបន់មួយពេលនោះណាស ព្រោះស្រុកទៅទទួល រួមខ្លួនឯង ប៉ុន្តែមានមានតំបន់ទទួលពីលើនោះដែរ ។ ទាល់តែចប់ដែនការនោះដល់រដូវ វស្សាគេត្រូវរំសាយតាមស្រុកមកតាមស្រុកវិញអស់នៅតែចល័តតំបន់ទេ ។

ដារ៉ា ៖ ចឹងមានន័យថានៅក្នុងចំនួនចល័តតំបន់៣២០០០នាក់នេះរួមទាំង...

យឿក ៖ រួមទាំងស្រុក!

ដារ៉ា ៖ ចល័តសហករណ៍ទាំងអស់?

យឿក ៖ បាទ!សហករណ៍ទាំងអស់ តាមភូមិទាំងអស់បាទ ។ ដល់វាចប់ផែនការនោះទៅចល័តតំបន់នៅតែបួនពាន់នាក់ទេជំនាន់ តារិន ។

ដានី ៖ ហួស!ជំនាន់ តារិន ចឹងដល់ខែវស្សាហ្នឹងពូថារំសាយនៅសល់តែបួនពាន់នាក់ទេដែលប្រចាំនៅត្រពាំងថ្ម?

យឿក ៖ បាទប្រចាំ ប្រចាំទាំងជួសជុលធ្វើអីៗនៅក្នុងហ្នឹងទំនប់អាងនោះទាំងអស់ហើយហ្នឹងធ្វើស្រែប្រាំងស្រែអីទាំងអស់ ។

ដានី ៖ ចុះលោកពូ លោកពូថា តារិន ហ្នឹងគេដកទៅ ដកទៅពេលណាទៀត?

យឿក ៖ តារិន បែបដកឆ្នាំ៧៧...៧៧ហើយបើពួកនិរតីមកមិនដើមឆ្នាំ៧៧!

ដានី ៖ ពូថាគេចាប់ តាវ៉ាល់ មិញហ្នឹងខែ៦ ឆ្នាំ៧៧ ចាប់តាវ៉ាល់ ចាប់តាហ៊ីងឆ្នាំ៧៧?

យឿក ៖ បាទ!ប្រហែល...បងរិន យើងគិតថាវាមិនបានចាំទេ តែ បងរិន នេះចាប់គាត់ទៅប្រហែល ៧៨ ព្រោះចាប់គាត់ទៅអត់បានយូរទេ វៀតណាមចូលមកបណ្តោយ ។

ដានី ៖ ចាប់ទៅប្រហែលប៉ុន្មានខែ?

យឿក ៖ ប្រហែលជា...អស់ច្រើនប្រហែលជាប្រាំខែហើយមើលទៅ ។

ដានី ៖ តែ តារិន គេចាប់ទៅដែរ?

យឿក ៖ ទេ!ចាំមិនចាំមិនដឹងទេ តែគេហៅយកទៅដល់យកទៅគេមិនតំលើង យាយចែម ជាតំបន់!

ដានី ៖ ជាគណៈតំបន់ហ្អី?

យឿក ៖ បាទ!

ដានី ៖ ជាគណៈតំបន់៥ហ្នឹង?

យឿក ៖ គណៈតំបន់៥ ។

ដានី ៖ ចឹងពេលហ្នឹង យាយចែម ជាគណៈតំបន់៥?

យឿក ៖ បាទ!ប្តីគាត់គណៈស្រុកព្រះនេត្រព្រះ ។

ដានី ៖ ពីណាគេគណៈស្រុក? ប្តីគាត់ហ្អី? ប្តីគាត់ឈ្មោះអី?

យឿក ៖ ឈ្មោះតាញ៉ែន ។

ដានី ៖ ឈ្មោះ តាញ៉ែន ហ្អី?

យឿក ៖ បាទ!

ដានី ៖ ចឹងពេល យាយថែម គាត់ឡើងជាគណៈតំបន់៥ តាញ៉ែន ហ្នឹងគាត់ជាគណៈស្រុកព្រះនេត្រព្រះ? ចឹងពេល យាយថែម ឡើងធ្វើគណៈតំបន់ហើយត្រពាំងថ្មហ្នឹងនៅតែបន្តធ្វើទៀត?

យឿកៈ នែ!កំពុងតែរៀបចំផែនការបន្ត...

ដានី ៖ រៀបចំផែនការបន្ត?

យឿក ៖ ពីព្រោះពេលដែលគាត់ឡើងតំបន់គាត់មកជួបខ្ញុំដែរ ។

ដានី ៖ បាទ!

យឿក ៖ ជួបខ្ញុំគាត់ចង់សួរថាសេដ្ឋកិច្ចមានប៉ុន្មានកន្លែង ហើយមានមនុស្សប៉ុន្មាននាក់ ហើយកិនស្រូវមានរោងម៉ាស៊ីនណាខ្លះ យកស្រូវពីណាអីពីណីគាត់មកសួរណាស ដល់សួរមិនបានប៉ុន្មានផងក៏បែកគ្នាព្រាងព្រាតវៀតណាមអីមក បានន័យថា យាយថែម គាត់មិនទាន់បានទទួលការងារបន្តរឿងអាងត្រពាំងថ្មទេ ។ គាត់គ្រាន់តែទទួលរួចទៅក៏វៀតណាមវ៉ៃបណ្តោយ ។

ដានី ៖ ចឹងគាត់អត់មានបានមកពិនិត្យមើលបានមកធ្វើអីទេ?

យឿក ៖ អត់ទាន់បាន ។

ដានី ៖ ចុះកាលគាត់នៅជាគណៈស្រុកកាលនោះគាត់មានបានចុះទៅមើលត្រពាំងថ្មអីដែរទេ?

យឿក ៖ គាត់ទៅដែរ ប៉ុន្តែខាងមុខសញ្ញាគាត់ គាត់បន្តដឹកអាព្រែកពីកមួយខាងកើតភ្នំលាបណាសព្រោះគណៈស្រុកកាលនោះគាត់នៅភ្នំលាប គាត់បញ្ជរនៅភ្នំលាប តែព្រះនេត្រព្រះក៏គាត់នៅដែរ ហើយគេធ្វើអានោះឯងធ្វើអាង ហួស ធ្វើព្រែកដឹកបន្តមកដល់គាត់ឡើងតំបន់បានគាត់ជិះឡានមករកខ្ញុំ មកយកស្ថិតិមកយកអី មានម៉ាស៊ីនភ្លើងប៉ុន្មាន មានត្រាក់ទ័រប៉ុន្មានស្អីៗទៅណាស ពីព្រោះនៅក្នុងនោះឡានអីខ្ញុំដឹង មិនដឹងយ៉ាងម៉េចបើសេដ្ឋកិច្ចវាត្រូវដឹកជញ្ជូន ។

ដានី ៖ បាទ!ចុះលោកតា លោកតាមានប្រសាសន៍ថាពេលដែល យាយថែម គាត់ប្តូរទីតាំងពីភ្នំលាបទៅ...

យឿក ៖ គាត់ចល័ត ឥឡូវទៅជាចល័តវិញ តែបើការពិតគាត់ទៅដេកជាមួយប្តីគាត់ ប៉ុន្តែគាត់ចល័តទៅស្រុកនេះបន្តិច ស្រុកនោះបន្តិច ចុះគេតំបន់នោះ ។

ដានី ៖ បាទ!ចឹងគាត់អត់ទៅសេរីសោភ័ណ្ឌទេ?

យឿក ៖ មិនសូវឃើញនៅទេ ឬមិនដឹងថាយ៉ាងម៉េចទេព្រោះខ្ញុំវានៅដាច់ទៅ ដូនកាលឃើញគាត់មកម្តងទៅ ។

ដានី ៖ ចឹងកាលពូនៅធ្វើការជាមួយ យាយថែម កាលឆ្នាំ៧៨ហ្នឹង យាយថែម រាងយ៉ាងម៉េចទៅ? រាងរៅ សំបុរសំបក កំពស់កំព សំដីសំដៅអីយ៉ាងម៉េចទៅ?

យឿក ៖ យាយថែម មាឌល្អិត ខ្មៅប្រហែលគាត់នេះ!

ដានី ៖ ប្រហែលអ៊ំនេះ?

យឿក ៖ បាទ!រាងប្រហែលនេះ ហើយសំដី បើនិយាយទៅស្មើនឹងអ្នកដែលគេរៀនយោបាយជ្រៅជ្រះ ព្រោះគេនិយាយអីហាក់ដូចជានឹងន ដូចជាមិនភ្វាក់ផ្អើលអីផ្តេសផ្តាសណាស អានេះបើតាមខ្ញុំស្តាប់ ។ គាត់និយាយទៅស្តាប់ ព្រោះគេនិយាយវាមួយ ។

ដានី ៖ ចុះលោកពូនេះមួយទៀតទាក់ទងនឹងខ្ញុំជួប ពូឈួង ពីម្សិលណាស គាត់និយាយថាកាលនោះមានករណីមួយពេលដែលពូទៅតាម ពូឈួង ហើយឈ្មោះម៉ន ដែលត្រូវជាបងរបស់ហាត់ គណៈស្រុកណាស តើពូអាចរៀបរាប់កន្លែងហ្នឹងបានទេ?

យឿក ៖ ហ្អស!ចេះ ព្រោះពេលនោះព្រោះពេលដែលគេធ្វើអាជីវកម្មត្រីហ្នឹងខ្ញុំក៏ទៅចូលរួមផង ត្រូវយកអង្ករអីពីខ្ញុំ តែក៏យើងមិនដឹងថាប្អូនគេចាប់ទៅហើយបងក៏ប្រហែលគេមិនទុកទេណាស ។ ខ្ញុំក៏ទៅពីកន្លែង តាឈួង ខ្ញុំទៅយក តែទៅយកនោះគេប្រាប់ថាមិនមែនយកទៅណាទេឲ្យគាត់មកជួយការងារនៅខាងនេះវិញ ខាងភាគនិរតីនោះណាស ហើយខ្ញុំក៏ទៅ ។ ដល់ទៅ គាត់និងខ្ញុំវាត្រូវគ្នានោះចុះមានអី គាត់ក៏សួរខ្ញុំថា «មើលអញចង់សួរហ្អែងខ្លះ ដូចកូនទៅចុះ កេយកអញទៅហ្នឹងយកទៅសំលាប់ហ្អីយ៉ាងម៉េច?» ហ្អឹស!ពូអ្អើយ ខ្ញុំក៏មិនអាចដឹងដែរ ។ ពិបាកណាស់ពូអ៊ឺយ! ចុះតែពីរនាក់គាត់នោះកណ្តាលវាលបើគាត់ចង់រត់ក៏មិនដឹងធ្វើម៉េចគាត់ដែរ ហើយខ្ញុំក៏មិនដឹងថាសន្និដ្ឋានថាយ៉ាងម៉េចក៏យូរទៅបណ្តើរគ្នាដឹកកង់ទៅណាស ដល់និយាយទៅបានគាត់ថាខ្ញុំប្រហែលជាគេមិនទុកទេ បើប្អូនគេចាប់ទៅហើយ ។ ខ្ញុំថាមិនដឹងទេពូ ពូអ៊ឺយ!ឥឡូវមិនដឹងថាម៉េច ។ ខ្ញុំគេឲ្យមកយកពូឯងទៅ គេនិយាយថាទៅប្រជុំខ្ញុំមិនដឹងធ្វើម៉េច អ្នកផ្សេងមិនប្រើគេមិនប្រើខ្ញុំ បើខ្ញុំធ្លាប់ស្គាល់គាត់ ធ្លាប់ដឹកស៊ីជុំគ្នាបើយើងទៅប្រាប់ខរត់ខ្លាចលវាមិនមែនបើគាត់រត់ខ្លួនឯងតែម៉ងយើងមិនដឹងធ្វើម៉េចបើដៃទទេរទាំងអស់គ្នាទៅធ្វើស្អី ។ ដល់ពីនោះទៅគាត់ថាល្ងាចហើយ ដល់ភ្នំស្រុកល្ងាចហើយក៏គាត់ថា ចេះទៅអាអន្ទិតអ៊ឺយ!ល្ងាចហើយចូលផ្ទះអញទៅ ទៅបាយទឹកទីនោះទៅហ្អា វាស្អីក៏ស្អីទៅ កុំភ័យពូមិនរត់ទេ ពូដឹងអាអន្ទិតឯងហើយ ពូស្រណោះណាស់ ។

ដល់ទៅក៏បាយទឹកគុណស្រ័យគាត់ដែរ មកចឹងអីសួរខ្ញុំថា បងអីយ!ពុកខ្ញុំនេះណាស! ខ្ញុំថាវាមិនដឹងយ៉ាង ។ មិត្តអីយ! ការពិតខ្ញុំក៏ក្រោមគេដែ ចុះមិនដឹងថាយ៉ាងម៉េច ប្រើឲ្យទៅយកគាត់នេះ...ខ្ញុំអ្នកចាត់តាំងឲ្យទៅព្រោះកាលនោះគេដាក់អន្ទង់ដាក់អីបាន គាត់នេះតែងតែមកនិយាយជាមួយខ្ញុំថា អាអន្ទិតអីយ!ហ្អែងជួយនិយាយប្រាប់គេទៅ ព្រោះរឿងដាក់អន្ទង់ដាក់អី អញចេះតើ អើកាលនោះបើយើងទៅធ្វើសេដ្ឋកិច្ចអីវាមានហូបមានចុកអីណាស ម្ល៉ោះហើយគាត់ចង់ឲ្យយើងជួយគាត់ ។ ដល់នេះទៅខ្ញុំក៏ទៅនិយាយជាមួយប្រធានចល័តតំបន់ បានប្រធានចល័តតំបន់ថាឲ្យគាត់ទៅ អញ្ចេះ!បានគេត្រូវឲ្យខ្ញុំនេះទៅយក ។ ដល់យកមកដល់បាយទឹកបាយអីរួចក៏ទៅ ដល់ទៅក៏ជួបនារីសេនាជន នារីទ័ពពីដើមមិញ នារីសេនាជនគេណាស!ដល់ទៅខ្ញុំក៏វាមិនដឹងរឿង ទៅល្ងាចទៅដើរដឹកកងទៅពីរនាក់ក៏គេសួរថា ពួឯងហ្អីឈ្មោះម៉ន? ថាបាទ! ដល់បានទៅដូចអារបៀបខ្សឹបខ្សៀវគ្នាអារបៀបអត់ស្រួលណាស!ចេញពីនោះមកគាត់អស់សង្ឃឹម គាត់ថាណ្ហើយអាអន្ទិតអីយ! អញដឹងតែគេចាប់ហើយ ចឹងខ្ញុំក៏ថាមិនដឹងយ៉ាងម៉េចទេពូ តោះអញទៅឲ្យដល់កន្លែម៉ងទៅ ។ មកដល់កន្លែងខ្ញុំហើយក៏បាយទឹកអី អើ!ចុះកន្លែងសេដ្ឋកិច្ចវាមានទៅអត់អី បបរក៏ឆ្អែតដែរទៅដេកបួបួនថ្ងៃណោះនៅជុំខ្ញុំ ។ គាត់ចេះតែនិយាយនឹងខ្ញុំ គាត់អស់សង្ឃឹមននឹងរស់ តែមិនដឹងរត់ទៅណា គាត់ថាស្លាប់ទៅចុះ ។ ដល់ពេលក្រោយ គេមកយកម៉ង ។ គេមកយកហ្នឹងបើតាមខ្ញុំដឹងគេយកទៅដាក់សន្តិសុខនៅក្នុងស្រុកដល់ក្រោយមកខ្ញុំដឹងណាស ពីព្រោះអ្នកមកយកនោះជួបខ្ញុំ ខ្ញុំសួរថា អ៊ឹម៉ន ថ្ងៃដែលគេមកយកៗទៅណា? ថាទេ!យកទៅដាក់នៅសន្តិសុខ បានខ្ញុំដឹងថាគេយកទៅដាក់នៅសន្តិសុខភ្នំស្រុក ព្រោះសន្តិសុខភ្នំស្រុកនោះមានមនុស្សច្រើនណាស់តាំងពីយោធាយោថាំងអីក៏នៅនោះច្រើនដែរ ។

ដានី : កាលនោះអ្នកណាបញ្ជាឲ្យពូទៅយក តាម៉ន?

យឿក : ហ្អស!បងយាន់ បងយាន់ ប្រធានគណៈតំបន់ ហ្អស!ប្រធានចល័តតំបន់ ។

ដានី : ប្រធានចល័តតំបន់ឲ្យទៅយក?

យឿក : បាទ! ថាមិត្តឯងទៅយកគាត់មក យកគាត់មកធ្វើការនៅនេះវិញ ។

ដានី : ថាចឹង?

យឿក : បាទ!

ដានី : ចុះកាលនោះម៉េចពូអ្នកទៅយក តាម៉ន មកវិញ? ចុះម៉េចបាន ពូឈួង មកជាមួយដែរ?

យឿក ៖ ហួស!កាលនោះ តាឈួន គាត់នៅទទួលអាជីវកម្មត្រីម្នោះហើយវាត្រូវតែមកវ៉ាយវ៉ាប់រឿងវ៉ាវអីទេដឹង ព្រោះខ្ញុំបានមកដល់នេះទៅមានបាននៅកន្លែងឯណាគ្រាន់តែផ្ដាំផ្ញើរដូចអូនឯងនៅនោះថា ដាំបាយដាំទឹកអីឲ្យគាត់ហូបផងខ្ញុំអត់នៅទេ ខ្ញុំក៏ចុះទៅមើលតាមកន្លែងមួយៗខ្វាចដាច់អន្តរដាច់អី ។

ដានី ៖ ចុះខែណាឆ្នាំណាដែរដែលពូទៅហៅ តាម៉ន មក?

យឿក ៖ ដូចក្ដាប់មិនបាន ប៉ុន្តែទៅហៅនោះជិតដល់រដូវភ្លៀងយ៉ាងម៉េចទេនេះ បើ តាឈួនអាចចាំមានសួរតាឈួនទេ?

ដានី ៖ បាទ!ឆ្នាំណាកាលនោះរដូវភ្លៀងឆ្នាំណា?

យឿក ៖ មានតែឆ្នាំ ប្រហែលជា...

ដានី ៖ កាលនោះចាប់ តាវ៉ាល់ ពូមានប្រសាសន៍ថាឆ្នាំ៧៧ ចឹងប្រហែលប្តូក៏មុន?

យឿក ៖ ក្រោយ!

ដានី ៖ ក្រោយយូរទេ?

យឿក ៖ ក្រោយយូរដែរហ្នឹង ចាប់តែគាត់ហើយមួយសន្ទុះហ្នឹងបែកហើយ ប្រហែល៧/៨នេះឯងបែបខែពីរ ខែបីហ្នឹង វាចុងឆ្នាំ៧/៨ហ្នឹង ។

ដានី ៖ ចឹងពូបន្ទាប់ពី តារិន យាយចែម អីហ្នឹងពូបានធ្វើការជាមួយ យាយចែម អីបានច្រើនទេ?

យឿក ៖ បានយូរដែរ ក្រោយមកក៏នៅ តាយាន់ តាពាល់ដល់ឥឡូវ តាយាន់ គេហៅទៅទៀត ។

ដានី ៖ បាទ!

យឿក ៖ នៅតែ តាពាល់ៗ នៅតាពាល់ ខ្ញុំក៏ធ្វើការជូនគាត់ហ្នឹងមកដល់វៀតណាមវៃមកទៅជុំគ្នាបណ្ដោយ ។

ដានី ៖ ចុះតាយន្ត បន្ទាប់ពីគេចាប់ តាវ៉ាល់ ទៅៗធ្វើប្រធានចល័តតំបន់រយៈពេលប៉ុន្មានទៅ?

យឿក ៖ ទេ ប្រហែលមិនដល់មួយឆ្នាំទេ វាប្រជិប្រជើយ ចាប់តែអីណោះហើយទៅនោះទៀតហើយដល់ តាយន្ត គាត់ទៅៗនៅ តាពាល់ៗ នៅតាពាល់ ហើយរួមជាមួយស្រុកដែរគេមានមុខនាទីត្រូវទៅនោះទៅបានក្រោយមក យាយចែម គាត់មកទទួលក្រោយនេះមិនបានប៉ុន្មានទេវៀតណាម ។

ដានី ៖ បាទ!មិនបានប៉ុន្មានទេគាត់ធ្វើគណៈតំបន់?

យឿក ៖ មិនបានទេ មិនបានយូរទេ ។

ដានី : អាចថាប៉ុន្មានខែដែរបើពូស្មានមើល យាយថែម?

យឿក : ទេ គាត់ទទួលពីខែវស្សាអីរួចទៅក៏ប្រាំងគេរើបណ្ដោយ ។

ដានី : យាយថែម កាលនោះគាត់ដាក់ផែនការអីយ៉ាងម៉េចដែរប្រុងធ្វើទំនប់ត្រពាំងថ្ម?

យឿក : មិនទាន់ទេ!

ដានី : អត់ទាន់ទេ?

យឿក : បាទ!អត់ទាន់ដាក់អីទេបើតាមខ្ញុំភ្លាប់ ព្រោះអានោះគេហៅថាគាត់តពីគេមកគាត់កំពុងសំរួលមានបញ្ហាជីវភាពតាមភូមិ ឃុំអីច្រើនណាស់ដោយសារតែមួយរយៈកន្លងមកវាទៅស៊ីបាយរួមនោះ!

ដានី : បាទ!ហើយពេលវៀតណាមចូលមកមានប្រជុំអីយ៉ាងម៉េចទៀតទេមុនហ្នឹងយើងរត់ពីស្រុកពីភូមិណាសមានប្រជុំ មានត្រូវជីករណ្ដៅកប់អី?

យឿក : អត់ អត់ ខ្ញុំមិនដឹងផងបើខ្ញុំដើរទៅផ្ទះខ្ញុំក៏បានដែលខ្ញុំទទួលសេដ្ឋកិច្ចនោះអង្ករឡើងរាប់ពាន់បាវ ហើយប្រជាជនមកហ៊ុកន្លែងខ្ញុំស្មាច់ ពរចានេះមកហ៊ុំវិហារ ចុះដាក់ក្នុងវិហារនោះ ហ៊ុំជិត ។ ខ្ញុំថា ចុយម្រាយហើយមនុស្សដែលមកហ៊ុំនោះក៏ខ្ញុំស្គាល់ដល់នេះខ្ញុំហៅ ហៅគាត់មកជួបនិយាយគ្នាអីថា ឥឡូវអីចេះ«បងអឹយ!មិនបាច់ហ៊ុំទេ ខ្ញុំអីណាទៅលីរួច តែទៅអស់ណាស់បួនដប់កំប៉ុង បងឯងធ្វើម៉េចធ្វើទៅតែកុំទាស់គ្នា»ខ្ញុំចង់និយាយអីចេះណាស កុំឲ្យខ្ញុំទៅផុតកាប់ចាក់គ្នាក៏មិនល្អដែរព្រោះខ្ញុំអ្នកបានបួសរៀនខ្លះដែរ ដល់នេះទៅគាត់ក៏ប្រកូកប្រកាសឲ្យអ្នកដែលមកហ៊ុំនោះនៅមួយកន្លែង ។

ដានី : បាទ!

យឿក : ខ្ញុំក៏រៀបចំចេញដែរ ព្រោះមានគេមកប្រាប់ដែរថាកុំឲ្យនៅ ។

ដានី : បាទ!

យឿក : ពូគេថាដូចខ្ញុំទៅប្រាប់អូនឯងថាឯងកុំនៅឆាប់មកតាមខ្ញុំមកស្អីៗចាំជួបគ្នាចាំនិយាយគ្នា ។

ដានី : បាទ!កាលនោះពេលវៀតណាមចូលមកលោកពូទៅជាមួយ យាយថែមដែរ?

យឿក : បាទ!

ដានី : ទៅជាមួយគ្នាក្រុមជាមួយគ្នាហ្នឹងហ្អី?

យឿក : ទាំងអស់ បាទ! ស្រុកភ្នំស្រុក ព្រះនេត្រព្រះ...

ដានី : បាទ!

យឿក : នេះទៅជុំគ្នា ។

ដានី ៖ ទៅដល់ណាទៅ?

យឿក ៖ ទៅរហូតដល់ដល់ទៅដងវែកដងអី ខ្ញុំធ្វើទ័ពនៅដងវែកដងអី ។ នៅតាមដងវែកនោះគ្រូន ចាញ់វាប់ចុយតែម្រាយ...

ដានី ៖ កាលនោះកពូមានប្រពន្ធប្តូនៅ?

យឿក ៖ នៅ!

ដានី ៖ អត់ទាន់មានទេ?

យឿក ៖ ខ្ញុំទើបតែបានប្រពន្ធ មិនឃើញកូនខ្ញុំមានកូនឯណានេះ សុទ្ធតែនៅរៀន ។

ដានី ៖ បាទ!ចុះពូមកធ្វើទ័ពនៅដងវែកជាមួយ យាយថែម អីទៀត?

យឿក ៖ បាទ!ធ្វើតើ ។

ដានី ៖ ពូនៅជាមួយ យាយថែម ដល់ពេលណាបានបែកគ្នា?

យឿក ៖ បែកនៅចុងឆ្នាំ៨០ ហួស!មើលទេចុង៧៩ ហ្អឹ៨០ទេ ប្រហែលចុង៧៩ ។ ដើម៨០នោះ អានេះបើមិនខែ១២ទេខែ១ ។

ដានី ៖ បាទ!

យឿក ៖ ព្រោះខ្ញុំចាកចេញពីគាត់នេះដោយសារទ័ពដែលនៅជាមួយខ្ញុំវាមិនសូវចង់នៅ ព្រោះអី ណោះវាអត់សេរីណាស អីព្រៃមាន់ ភ្នំឆ័ត្រអីគេសេរីមានមាសមានអីយកទៅលក់ទៅដូរ បានស៊ីចុកតាមចិត្តណាស ។

ដានី ៖ បាទ!

យឿក ៖ ដល់អីណោះអត់មានថៃមានអីទេ គឺនៅជាប់នឹងព្រៃទៅ ចង់ស៊ីដូងទៅបេះដូងទៅ ហើយ ហ្នឹងការពារវ៉ៃចំរ៉ូងបុកចំរ៉ូង ។

ដានី ៖ បាទ!

យឿក ៖ ដល់នេះខ្ញុំរត់ពីដងវែក នាំទ័ពរត់មក រត់មកគាត់មកតាមដែរតើ មកតាមនិយាយគ្នា ។ខ្ញុំថា អត់ទេបងអើយ!ព្រោះមកដល់នេះហើយខ្ញុំខ្ជិលទៅវិញណាស់ ។

ដានី ៖ អីចឹង? យាយថែម គាត់តាមមកនិយាយជាមួយពូដែរ?

យឿក ៖ បាទ!ព្រោះក្រោយមកវាអស់ទ័ព ខ្ញុំមកទ័ពមកអស់ ។

ដានី ៖ ហើយគាត់យ៉ាងម៉េច? គាត់ទៅណាទៅ?

យឿក ៖ ទេ សព្វថ្ងៃនៅតើ នៅទីប្រឹក្សាឃុំហ្អឹ...

ដានី ៖ ទីប្រឹក្សាឃុំហ្អឹ?

យឿក ៖ បាទ!

ដានី ៖ ប៉ុន្តែមិនបែកជាមួយពូនៅដើមឆ្នាំ៨០ ហ្អីដូចពូមានប្រសាសន៍ចឹង តែពូមកខាងភ្នំឆ័ត្រដែលថាទ័ពមានសេរីភាពអាចដូរអង្ករ មានមាសអីយើងចាយដោះដូរគ្នាបានណាស?

យឿក ៖ បាទ!

ដានី ៖ ចឹងយាយបែម គាត់ទៅណាវិញទៅ?

យឿក ៖ យាយបែម គាត់ទៅនៅភូមិភាគខត្តរជុំ តាសឿន ។

ដានី ៖ បាទ?

យឿក ៖ ទៅនៅជុំ តាសឿនភូមិភាគខត្តរ ។

ដានី ៖ ភូមិភាគខត្តរនៅឯណាទៅកាលនោះ?

យឿក ៖ ខត្តនៅខាងខត្តមានជ័យ ហួសគោកមន អំពិលអីណោះណាស កន្លែងដែលគេវៃគ្នាព្រះវិហារអីណោះណាស!

ដានី ៖ ហួស!អាកន្លែងគេវៃគ្នារាល់ថ្ងៃហ្នឹងហ្អី?

យឿក ៖ បាទ!

ដានី ៖ កន្លែងគោកមន កន្លែងប្រាសាទតាក្របី ប្រាសាទតាមាន់?

យឿក ៖ បាទ!នៅម្តុំហ្នឹង ។

ដានី ៖ នៅម្តុំហ្នឹងវិញ ហើយពូមកខាងភ្នំឆ័ត្រនេះខាងខ្មែរក្រហមដែរឬយ៉ាងម៉េច?

យឿក ៖ ខ្មែរក្រហមដូចគ្នា ។

ដានី ៖ បាទ!ហើយយ៉ាងម៉េចទៀតទៅលោកពូ?

យឿក ៖ ទេ!ដល់មកដល់នេះទៅខ្ញុំមិនទៅក៏...ព្រោះយាយបែម នេះគេចង់ឲ្យគាត់មកភ្នំឆ័ត្រដែរ តែដល់យ៉ាងម៉េចទេគាត់អត់មកក៏វាទៅជាអត់ទៅ ហើយខ្ញុំក៏នៅនេះទៅមិនដែលបានទៅវិញទេខ្ញុំខ្ជិល ។

ដានី ៖ ពូនៅភ្នំឆ័ត្រដល់ពេលណាទៅ?

យឿក ៖ ទេ!នៅទាល់តែដល់៨៤ ៨៤បានវៃគ្នា វៀតណាមវៃបែកទៅបានខ្ញុំទៅម៉ាឡៃ ទៅអីក្លូក់អីណោះណាស ។

ដានី ៖ បាទ!ជំរុំក្លូក់!

យឿក ៖ ហ្នឹងហើយ!នៅក្លូក់ ។

ដានី ៖ នៅក្លូក់រហូតដល់ពេលណាទៅ?

យឿក ៖ ដល់មាតុភូមិ!

ដានី ៖ មាតុភូមិនិវត្តិឆ្នាំ៩៧?

យឿក ៖ អត់ទេកាលនោះ៩៣ ។ ខ្ញុំគេហៅទៅធ្វើទ័ពនៅនោះហើយមកធ្វើទ័ពនៅនេះដែរ ។

ដានី ៖ ធ្វើទ័ពនៅឯណា?

យឿក ៖ នៅដងរែកនោះណាស!

ដានី ៖ បាទ!

យឿក ៖ នៅថ្មដូន នៅអានក្បាលលាវ ប៉ុន្តែក្រោយមកប្រពន្ធខ្ញុំមានកូនទៅក៏នៅមើលទៅ នៅមើលថែគ្នាទៅក៏មាតុភូមិបណ្តោយ ។

ដានី ៖ បាទ!ចុះកាលនោះពូមកធ្វើទ័ពនៅអានក្បាលលាវខាងអីនេះទ័ពខ្មែរក្រហម ឬប៉ារ៉ា?

យឿក ៖ ទ័ពខ្មែរក្រហម!

ដានី ៖ ខ្មែរក្រហមដដែល? តួនាទីអីទៅ?

យឿក ៖ ទេ!ខ្ញុំគ្រាន់តែនៅជាមួយកងពលណាស ដូចថាគេប្រើអីម៉េចៗយើងចេះតែទៅៗ ។

ដានី ៖ យើងជាឋានៈកងពលដែរឬយ៉ាងម៉េច?

យឿក ៖ ទេ!អត់ទេ ។

ដានី ៖ អត់ទេ?

យឿក ៖ បាទ!អានេះបានន័យថាវាគ្រាន់តែយើងជាមនុស្សស្មោះត្រង់ម្នាក់ដែលនៅក្នុងនោះ ។ ដូចថានៅក្នុងកងពលមួយមិនមែនចេះតែយកមនុស្សមកក៏គេប្រាជ្ញដែរ ។

ដានី ៖ ទីប្រឹក្សាឬក៏ជា...?

យឿក ៖ ទេ!ខ្ញុំមិនមែនទីប្រឹក្សាអីទេ ។ ឧបមាថា គេចុះទៅក្នុងអីចេះគេឲ្យខ្ញុំទៅជុំដូចអូនឯងខាងវរៈសេនាធំណាស ខ្ញុំទៅជាមួយទៅ ដូចអូនឯងមានបញ្ហាអីពិភាក្សាគ្នាទៅ ។

ដានី ៖ បាទ!

យឿក ៖ ខ្ញុំជាពិសេសខ្ញុំនៅជុំ តាស៊ូនេះ!

ដានី ៖ តាស៊ូ!ព្រំស៊ូនេះហ្អី?

យឿក ៖ បាទ!

ដានី ៖ ចុះពូរៀបការជាមួយមីងឆ្នាំណា?

យឿក ៖ ទេមិនដឹងប៉ែតប៉ុន្មាន ៨២ហ្អី? ហ្អស!៨២ ថា៨២ហ្នឹងទៅ ។

ដានី ៖ បាទ! ហើយរៀបការអីចឹងមីងគាត់ទៅនៅជុំរុំហើយពូមកធ្វើកងទ័ពនៅខាងអាងក្បាល លាវក្បាលអីនេះទៅ?

យឿក ៖ បាទ!ជួរគោកមកអីនេះ ។

ដានី ៖ បាទ!រហូតដល់៩៣បានធ្វើមាតុភូមិនិវត្តិមកនៅភូមិវិញមក?

យឿក ៖ ខ្ញុំដល់ក្រោយមកខ្ញុំថាទៅជុំរុំដល់អត់អន្តរកាលនោះគេមិនឲ្យមានមនុស្សប្រុសឯណា ឲ្យតែមនុស្សស្រី ខ្ញុំដល់ក្រោយមកទៅប្រឡងធ្វើគ្រូធ្វើអីទៅ ធ្វើគ្រូបង្រៀនទៀត ។

ដានី ៖ បាទ!

យឿក ៖ ដល់ទៅធ្វើគ្រូបង្រៀនគ្រូអីទៅក៏កងពលទៅតាមខ្ញុំដែរ តែខ្ញុំថាបើគ្រួសារអត់សូវស្រួលដែរ ហើយក៏ថានៅសិនៗទៅក៏ខ្ញុំចេះតែបង្រៀនកូនក្មេងយកអន្តរស៊ីទៅ បានតែអន្តរស៊ីហ្នឹងទៅ ។

ប្រុញ ៖ អត់ទោសពូខ្ញុំសុំសួរមួយសំនួរ!

យឿក ៖ បាទ!

ប្រុញ ៖ កាលពូនៅធ្វើខាងសេដ្ឋកិច្ចនោះពូបានបើកអន្តរឲ្យគេក្នុងគណៈតំបន់ហ្នឹងបីម៉ឺនពីរពាន់នាក់ពូហ្អី?

យឿក ៖ បាទ!

ប្រុញ ៖ បីម៉ឺនពីរពាន់នាក់ហ្នឹងសុទ្ធតែអ្នកទៅធ្វើនៅត្រពាំងថ្មទាំងអស់ហ្អីពូ?

យឿក ៖ បាទ!និយាយរួមអ្នកដែលទៅរួមចំណែកក្នុងការធ្វើប្រព័ន្ធអាងនោះ និយាយអីចេះណាស បានន័យថាអាប្រព័ន្ធអាងវាដូចជារចនាសម្ព័ន្ធ អាប្រឡាយណាដែលត្រូវពាក់ព័ន្ធក្នុងអាងនោះគឺកំលាំងធ្វើទាំងអស់ ។

ប្រុញ ៖ បើនិយាយសរុបទៅបានន័យថាត្រពាំងថ្មហ្នឹងធ្វើគ្នាបីម៉ឺនពីរពាន់នាក់ហ្នឹងឬយ៉ាងម៉េច?

យឿក ៖ បាទ!មិននៅទីនោះទាំងអស់ទេ ខ្លះធ្វើអាប្រឡាយព្រែកជីកទៅធ្លាក់ទៅឯព្រែកនោះ អាខ្លះធ្វើធ្លាក់ទៅស្ទឹង អាហ្នឹងតាមគេទៅណាស អាមួយនោះក៏ទៅបិទស្ទឹងស្ពានស្រែងណោះ ។ ស្ទឹងស្ពានស្រែងមានដែលទៅដល់ទេ?

ដានី ៖ ពុ តែខ្ញុំគង់តែទៅដល់ទេ ។

យឿក ៖ ទៅដល់ក្នុងស្រុកទៅចេះទៅ ទៅមើលម្តងទៅមើលម៉េចបានបិទស្ទឹង ។

ដានី ៖ បាទ!

យឿក ៖ កាលពីនោះស្ពាន គេហៅស្ពានបុរាន ស្ពានថ្មធំៗណាស់ ។ ដល់នេះគេយកដីទៅចាក់បណ្ដោយ...

ប្រុញ ៖ ចឹងពូបើពូស្នានគេធ្វើនៅត្រពាំងថ្មប្រហែលគ្នាប៉ុន្មានម៉ឺននាក់ទៅ?

យឿក ៖ ត្រពាំងថ្មនោះបើតាមខ្ញុំគិតពេលក្រោយមិនជាច្រើនទេ ដល់ក្រោយមកគេត្រូវចប់មួយវគ្គនោះកំលាំងគេត្រូវធ្វើអាព្រែកជីកនាំទឹកទៅណេះទៅណោះណាសហេតុនេះគេទុកតែកំលាំងថៃទេ ។

ប្រុញ ៖ ចុះដល់ពេលច្រើនបំផុតប្រហែលប៉ុន្មានទៅពូ?

យឿក ៖ ច្រើននៅអាងត្រពាំងថ្មបើតាមខ្ញុំគិតប្រហែលជាមួយពាន់ជាងដែលគេឲ្យនៅថែរក្សាសំរាប់កន្លែងណាដែលវាលេច វាហូរអីយ៉ាងម៉េចៗណាស ។ បើយើងទប់ទល់មិនឈ្នះទេ ឆាប់ប្រាប់ទៅគេ ។

ប្រុញ ៖ អត់ទេ! ពេលមនុស្សរាប់ម៉ឺននាក់ហ្នឹងប្រហែលអតិបរិមាប៉ុន្មានដែរដែលធ្វើនៅត្រពាំងថ្មអត់ទាន់រំសាយណាស?

យឿក ៖ ហួស! កាលមិនទាន់រំសាយនៅពេញតែម្ដង អត់មានខ្វះទេជំនាន់នោះ ។

ប្រុញ ៖ ប្រហែលបីម៉ឺនពីរពាន់នាក់ហ្នឹង?

យឿក ៖ បាទ! អត់មានផ្ដេសផ្ដាសបានទេ ។

ប្រុញ ៖ បាទ!

យឿក ៖ បើតាមពិតទៅមានអ្នកឈឺអ្នកអីវាធម្មតាទេ បើបាត់កំលាំងណាមួយសូម្បីតែនារីអីរត់ទៅសហករណ៍ហើយគេទៅតាមយើងមកវិញណាស អត់បានទេ ។

ប៊ុនថន ៖ ពូរបបបីកំប៉ុងមួយថ្ងៃពូហ្អ៎?

យឿក ៖ បាទ!

ប៊ុនថន ៖ បីពាន់...

យឿក ៖ បីម៉ឺនពីរពាន់!

ប៊ុនថន ៖ បាទ! ហើយមួយបាវហ្នឹមាន៤០០កំប៉ុង?

យឿក ៖ បាទ! មួយរយគីឡូ៤០០កំប៉ុង ។

ប៊ុនថន ៖ ចុះបីម៉ឺនជាងប៉ុន្មានបាវទៅ?

យឿក ៖ ដឹងប៉ុន្មានទេកាលនោះ ប៉ុន្តែកាលនោះគេចង់និយាយថាធ្វើអីឲ្យសល់មួយពាន់បាវនៅក្នុងឃ្លាំង ហើយឡានដឹកអង្ករនិងស្រូវវាប៉ុន្មានប៧ត្រាក់បីដណ្ដប់គ្រឿងទៀតនោះ ។

ដានី ៖ អង្ករហ្នឹងប្រមូលមកពីណា?

យឿក ៖ តាមសហករណ៍ តាមស្រុក ។

ប៊ុនថន ៖ ខ្ញុំគុណមិញហ្នឹងដូច២៨០ បាវតូ!

យឿក ៖ បាទ!

ប៊ុនថន ៖ ២៨០ បាវច្រើនណាស់តូ?

យឿក ៖ ច្រើនណាស់ណាស ។ យើងគិតមើលឡាន៧ដឹកទាំងព្រឹកទាំងយប់ ដឹកអត់មានឈប់ទេណាស ។

ដានី ៖ ចឹងអង្ករមកពីតាមសហករណ៍ផ្គត់ផ្គង់គ្រាន់ដែរ?

យឿក ៖ អត់គ្រាន់ទេ មានដាច់ដែរតើ ។

ដានី ៖ តែដាច់យើងយកពីណាវិញ?

យឿក ៖ ដាច់ តំបន់គេស៊ីញេឲ្យហើយទៅយកនៅហ្នឹងឃ្លាំងមង្គលបុរី យកប៉ុន្មានប្រាំពាន់បាវ ឡានតំរាបគ្នាដឹកប៉ុន្តែយើងចង់និយាយថាបើកំប៉ុងក្នុងនោះត្រូវសំរេចផែនការដូចបីខែអីទេណាស ដល់ក្រោយមកគេរំសាយពីផែនការបើកំប៉ុងមកនៅជួនកាលមួយកំប៉ុងកន្លះដែរ ។ ជួនកាលបើវានេះខ្លាំងទៅវាស្របប្រហាក់ប្រហែលនឹងសហករណ៍ដែរ ។

ដានី ៖ កន្លះកំប៉ុង?

យឿក ៖ បាទ!

ដានី ៖ ម៉ាដៃកន្លះកំប៉ុង?

យឿក ៖ បាទ!អានោះអត់មានសំរុកអីទេណាស!

ដានី ៖ បាទ!អាហ្នឹងយើងអត់សូវធ្វើការអីកន្លះកំប៉ុង?

យឿក ៖ បាទ!

ប្រុញ ៖ អត់ទោសពូថា ឈ្មោះល្មៀមហ្អី?

យឿក ៖ ល្មៀម!

ប្រុញ ៖ ពូថាខ្មែរគាត់ធំៗពីណាខ្លះទៅពូ?

យឿក ៖ ទេ មិនដឹងពីណាទេ តែយើងដឹងថាការខុសសីលធម៌ ម៉ាវយនាក់មានតែម្នាក់ពីរនាក់ទេដែលអាចមានជីវិតរស់រានណាស ប៉ុន្តែបើថាខ្មែរតូចខ្ញុំថាដូចអត់នៅ មិនបានអីក៏ដាប់សន្តិសុខដាប់អីដែរ ។

ប្រុញ ៖ ចុះពូថាគាត់ធ្លាប់បានទៅជួបខៀវ សំផនអីដែរ?

យឿក ៖ ហ្អស! ប៉ុន្តែអានេះយើងពុតាមរយៈគេខ្វះណាស ថាគាត់ធ្លាប់នៅជុំខៀវ សំផន លឿមនោះ ។ នៅបែបនៅបាយទឹកបំរើអីទេដឹងបានក្រោយមកគាត់ត្រូវមកកាន់ការនេះ ។ វាក៏ជារឿងមិនពិតដែរ ពីព្រោះអ្វីដែលយើងមិនបានឃើញនឹងភ្នែកណាស ការពុតាមគេ ប៉ុន្តែបើយើងនិយាយពីរឿងប្រវត្តិសាស្ត្របើមិនជឿតាមគេទេមិនដឹងទាល់តែស្លាប់ឬយ៉ាង ម៉េចបានឃើញ បើតាំងពីថ្មអន្តរវត្តលូកដៃក្រហ៊ូៗ ។

ដានទី ៖ មានអ្នកណាមានសំនួរសួរគាត់ទៀត?

យឿក ៖ បាទ!សួរមក!

ដារ៉ា៖ ពូស្គាល់ ពូឈុំ សេង និង ឡូត សួយទេ?

យឿក ៖ សួយ ស្គាល់ ប៉ុន្តែឥឡូវវាចង់ភ្លេចទៅទៀតណាស!

ដារ៉ា ៖ ពូសួយ ហ្នឹងធ្វើអីកាលនោះ?

យឿក ៖ កងតូចអីទេ!

ដារ៉ា៖ នៅត្រពាំងថ្មដែរ?

យឿក ៖ បាទ!សេង សេងហ្នឹងនៅពន្លៃដល់ឥឡូវបែកគ្នាយូរហើយមិនដឹងយ៉ាងម៉េចទេ ។

ដារ៉ា ៖ សេងហ្នឹងធ្វើអី?

យឿក ៖ ធ្វើសុទ្ធតែកង ប្រធានកងប្រធានអីហ្នឹង ។

ដារ៉ា ៖ នៅទំនប់ត្រពាំងថ្មដែរ?

យឿក ៖ បាទ!

ដារ៉ា ៖ ពូសេង ខ្ញុំបានជួបគាត់ម្សិលមិញនៅតាវេង ។

យឿក ៖ ហ្អស!ហ្នឹងហើយសេងបែនៅតាវេង បើអាសួយ ដូចនៅពន្លៃហ្នីត្រង់ណាទេនាក...

ដារ៉ា ៖ ពូសួយ នៅប្រាសាទត្បែង បន្ទាយឆ្មារ ។

យឿក ៖ ហ្អស!ហ្នឹងហើយ...

ដារ៉ា ៖ ខ្ញុំបានជួបម្សិលមិញដែរ!

យឿក ៖ ពួកនោះជួបក៏ស្គាល់ខ្ញុំដែរ ពីព្រោះកាលមុន ចុះខ្ញុំធ្វើសេដ្ឋកិច្ចអ្នកណាមិនស្គាល់!

ដារ៉ា ៖ ចឹងបានខ្ញុំមកជួបពូហ្នឹងណាស!

យឿក ៖ មិនថាម៉េចទេ ស្រីៗអីស្គាល់ទាំងអស់ ជួនកាលឧបមាថាសុំច្បាប់គេបីថ្ងៃ បីថ្ងៃវាត្រូវយ៉ាង ម៉េច អង្ករគេមួយថ្ងៃម៉ាកំប៉ុងកន្លះវាត្រូវប៉ុន្មាន? ឧបមាថាត្រូវបានអង្ករប៉ុន្មាន? ប៉ុន្តែពួក

នោះមិនដែលខ្លាចខ្ញុំទេ ។ តែនេះឡើង...គេទៅជួបម៉ែឪគេឲ្យគេតែប៉ុណ្ណឹង! ខ្ញុំថាតែ! មិនមែនអន្ករខ្ញុំទេណាស អន្ករទាំងអស់គ្នាប្រយ័ត្នតែអត់ អត់ទាំងអស់គ្នា! ទៅដល់បាយក ។

ដានី : លោកពូអឺ! ពួកខ្ញុំដូចជាអស់សំនួរអីសួរនាំលោកពូទៀតហើយ...

យឿក : បាទ!

ដានី : អីចឹងលោកពូមានអីចង់បន្ថែមលើអ្វីដែលពួកខ្ញុំអត់ទាន់បានសួរលោកពូទេ?

យឿក : ទេ! ខ្ញុំនែ បើនិយាយរួមទៅជាចុងក្រោយបំផុតនេះ ខ្ញុំចង់ថា...ចង់និយាយពីអាផែនការដែលប្អូនទាំងអស់គ្នាមកសួរខ្ញុំ តែចង់និយាយថាលទ្ធផលនោះនឹងចេញទៅជាយ៉ាងណា ឬក៏សួរដើម្បីយ៉ាងម៉េច? ខ្ញុំចង់និយាយអីចេះឬក៏នឹងគិតថាស្អីពីព្រោះឥឡូវវាពិបាកដែរបើតាមខ្ញុំគិតទេណាស ពីព្រោះខ្លះគ្នាមានប្រវត្តិតិចតួចគ្នាខ្លាចដែរ ប៉ុន្តែខ្ញុំៗមិនខ្លាចទេចំណាស់នេះហើយអាណាយកទៅធ្វើអីធ្វើទេ! ប៉ុន្តែអ្វីដែលការពិតគឺខ្ញុំនិយាយការពិត ។

ដានី : បាទ! លោកពូដូចខ្ញុំបានជំរាបពីមុនអីចឹង ពួកខ្ញុំធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងធ្វើការទាក់ទងនឹងការចងក្រង ការប្រមែប្រមូលឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ណាសលោកពូ! ហើយលោកពូនេះជាមនុស្សម្នាក់ដែលពូមានបទពិសោធន៍ ពូមានការទាក់ទងនឹងតំបន់៥ពិសេសនៅកងចល័តនិងនៅអាងត្រពាំងថ្ម ហើយពួកខ្ញុំទាំងអស់នេះចង់សសេរពីរឿងរ៉ាវនៅអាងត្រពាំងថ្ម ហើយការសំភាសជាមួយលោកពូនេះគឺយើងយកទៅសសេរ យកទៅចុះនៅក្នុងទស្សនាវដ្ដីស្វែងរកការពិតយកទៅផ្សព្វផ្សាយឲ្យអ្នកសិក្សាអ្នកស្រាវជ្រាវ ក្មេងៗជំនាន់ក្រោយឬក៏អ្នកណាក៏ដោយឲ្យតែគេចង់ដឹង គេចង់ស្រាវជ្រាវទាក់ទងរឿងហ្នឹងគេអាចអាន...ដួនកាលគេអាចទាក់ទងជាមួយលោកពូទៀតដោយសារតាមរយៈពួកខ្ញុំដែលមកជួប មកសួរនាំលោកពូនេះណាស!

យឿក : បាទ!

ដានី : គេអាចមកសួរនាំបន្ថែមពីពូទៀត ។

យឿក : បាទ! វាមិនអីទេចឹង ព្រោះខ្ញុំធ្លាប់មើលសៀវភៅខ្លះដែលគេចងក្រងដែរ តាមទស្សនាវដ្ដីតាមអីណាស ប៉ុន្តែគេក៏និយាយមានការអះអាងច្រើនដែរនៅក្នុងទស្សនាវដ្ដីដែរណាស ប៉ុន្តែខ្ញុំអ្វីដែលគេថាតូចតាច យើងមិនអាចដឹងរឿងអីជ្រៅបានទេ ។

ដានី : បាទ! ចឹងលោកពូខ្ញុំអគុណច្រើនដែលចំណាយពេលសំភាសជាមួយពួកខ្ញុំ ជិតបីម៉ោងហើយវាពីរម៉ោងសែសិបនាទីជាងហើយលោកពូ!

យៀក ៖ បាទ!

ដានី ៖ បាទ!អគុណលោកពូច្រើនៗ

ធានី ៖ ចឹងលោកពូខ្ញុំសុំថតរូបលោកពីហើយថតសំឡេងបានទេលោកពូ?

យៀក ៖ ចុះថតទៅមានអី!

«ចប់»